ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

# សទ្ទានុក្រម
# ភាសាវិទ្យា និង អក្សរសិល្ប៍
## ខ្មែរ-អង់គ្លេស-បារាំង

# LEXICON OF LINGUISTICS AND LITERATURE
## Khmer-English-French

ក្រុមប្រឹក្សាជាតិភាសាខ្មែរ

គណៈកម្មការភាសាវិទ្យា និង អក្សរសិល្ប៍

ឆ្នាំ ២០១៣

អាសយដ្ឋាន: មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ
ទូរសព្ទ: [illegible], អ៊ីមែល: info@nckl.gov.kh, គេហទំព័រ: www.nckl.gov.kh

# **អារម្ភកថា**

ដើម្បីធ្វើសទ្ទានុក្រមដែលដាក់ពាក្យតាមលំដាប់អក្ខរក្រមដោយបានចម្លងពាក្យដែលគណៈកម្មាធិការជាតិភាសាខ្មែរ(គ.ជ.ភ.ខ.)និងក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)បានអនុម័តដោយផ្អែកលើពាក្យគន្លឹះនិងចុះផ្សាយក្នុងព្រឹត្តិបត្ររួចមក យើងបានសង្កេតឃើញថាពាក្យខ្លះដែលត្រូវដាច់ចេញពីពាក្យគន្លឹះ មានការពិបាកយល់ ហើយ ពាក្យខ្លះទៀតមិនទាន់បានពន្យល់ឲ្យគ្រប់ជ្រុងជ្រោយឬឲ្យបានសមស្របនៅឡើយ ៖ ដូច្នេះហើយ យើងបានបង្គ្រប់បន្ថែមដើម្បីឲ្យសទ្ទានុក្រមមានលក្ខណៈសមស្របនិងងាយយល់ ។ ការបង្គ្រប់បន្ថែមទាក់ទងនឹងកាឡាសូរ, កាឡារូប និង ការបំបែកនាម ជាដើម។ ម្យ៉ាងទៀត គួបញ្ជាក់ផងដែរថា ដើម្បីបន្ធូរបន្ថយការរង្វះបន្តិចបន្តួច យើងបានសម្រេចចិត្តប្រើថវិកាបានពីសប្បុរសជនដើម្បីបោះពុម្ពសទ្ទានុក្រមនេះ។

យើងសង្ឃឹមថា សទ្ទានុក្រមភាសាវិទ្យានិងអក្សរសិល្ប៍លេខ១នេះ មានប្រយោជន៍ដល់អ្នកស្នេហាភាសាខ្មែរ ត្រឹមកម្រិតណាមួយមិនខាន។ សូមសាធារណជនទទួលយកសទ្ទានុក្រមលេខ១នេះទៅប្រើសិនទម្រាំមានចេញលេខបន្ទាប់ៗនៅពេលក្រោយ។

ក្រុមប្រឹក្សាជាតិភាសាខ្មែរនិងសេនាធិការអម ត្រូវការចំណាយថវិកាជាច្រើន។ អង្គភាពនេះមិនអាចដំណើរការបានរលូនទេ បើគ្មានការយកចិត្តទុកដាក់ខ្ពស់ព្រមទាំងការផ្តល់ថវិកាជាហូរហែពីសម្តេចបណ្ឌិតសភាចារ្យអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងជាគុរុគណនៃក.ជ.ភ.ខ. និង ពីឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានកិត្តិយសនៃក.ជ.ភ.ខ.។

អាស្រ័យហេតុនេះ ក្នុងនាម ក.ជ.ភ.ខ.ទាំងមូល ខ្ញុំសូមថ្លែងអំណរគុណព្រមទាំងកតញ្ញូតាយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំខាងលើ ដែលជាអាណាព្យាបាលនៃក.ជ.ភ.ខ.យើង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

រាជធានីភ្នំពេញ, ថ្ងៃ...អង្គារ...ទី...៨...ខែ...តុលា...ឆ្នាំ២០១៣

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ ព្រំ ម៉ល់

# បុព្វកថា

ពាក្យស្នើចេញពីគណៈកម្មការផ្សេងៗដែលគណៈកម្មាធិការជាតិភាសាខ្មែរ (បច្ចុប្បន្នក្រុមប្រឹក្សាជាតិភាសាខ្មែរ)បានអនុម័ត ជាពាក្យផ្អែកលើពាក្យគន្លឹះ ទោះពាក្យគន្លឹះនោះកើតចេញពីអក្សរណាក្នុងអក្ខរក្រមក៏ដោយ។ ការរៀបពាក្យបែបនេះបានជួយសមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ(គ.ជ.ភ.ខ.) និងក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) ឱ្យស្រួលតាមដានក្នុងការអនុម័តពាក្យ ប៉ុន្តែសាធារណជនមានការពិបាករកពាក្យដែលគេត្រូវការយល់ន័យ ហើយ មានតែសទ្ទានុក្រមទេទើបជួយសម្រួលពួកគេបាន ពីព្រោះបច្ចេកសព្ទត្រូវបានរៀបតាមលំដាប់អក្ខរក្រម។

ដើម្បីធ្វើសទ្ទានុក្រមនៃមុខវិជ្ជាមួយដែលមានរាប់ពាន់ពាក្យ អ្នកធ្វើកិច្ចការត្រូវចំណាយពេលច្រើនឆ្នាំ(ចំពោះតែមុខវិជ្ជាមួយ): ដោយគ.ជ.ភ.ខ.និងក.ជ.ភ.ខ.ត្រូវអនុម័តពាក្យទាក់ទងនឹងមុខវិជ្ជាជាច្រើនបន្តបន្ទាប់គ្នា សទ្ទានុក្រមនៃមុខវិជ្ជានីមួយៗមិនអាចគ្របដណ្តប់លើពាក្យទាំងអស់ក្នុងរយៈពេលពីរបីឆ្នាំបានទេ : ក.ជ.ភ.ខ.ដែលបន្តកិច្ចការពី គ.ជ.ភ.ខ. ត្រូវបោះសទ្ទានុក្រមទាក់ទងនឹងវិជ្ជានីមួយៗជាបន្តៗគ្នារហូតបានចំនួនពាក្យច្រើនក្រាស់ក្រែល។

សូមសាធារណជនទទួលយកសទ្ទានុក្រមទី១នៃភាសាវិទ្យានិងអក្សរសិល្ប៍នេះទៅប្រើបណ្តើរៗទម្រាំមានចេញលេខបន្ទាប់ៗ ហើយ សូមជ្រាបថា បញ្ហាចម្រូងចម្រាសក្នុងភាសាខ្មែរត្រូវបានដោះស្រាយបានមួយភាគហើយក្នុងសទ្ទានុក្រមទី១នេះ។

រាជធានីភ្នំពេញ, ថ្ងៃទី......០២......ខែ......10......ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និង ជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ សុខ អាន

# បច្ចេកសព្ទភាសាវិទ្យា
# ដែល
# គណៈកម្មាធិការជាតិភាសាខ្មែរ / គ.ជ.ភ.ខ.
# (បច្ចុប្បន្ន ក្រុមប្រឹក្សាជាតិភាសាខ្មែរ / ក.ជ.ភ.ខ.)
# បានអនុម័ត

| | |
|---|---|
| **១- កម្ម**<br>អ. complement<br>បារ. complément<br>( m. ) | បញ្ញត្តិនេះត្រូវបានគេសម្គាល់ដោយពាក្យផ្សេងៗគ្នា តាមអ្នកវេយ្យាករណ៍ គឺ :<br>- កម្មរង[1]<br>- កម្មបទ[2]<br>- បទកម្ម[3]<br>- កម្ម[4]<br>គណៈកម្មការភាសាវិទ្យានិងអក្សរសិល្ប៍បាន សម្រេចជ្រើសរើសយកពាក្យ **កម្ម** និង កំណត់ន័យដូចតទៅ :<br>**កម្ម**ជាពាក្យរណបសម្រាប់បង្គ្រប់សេចក្ដីឱ្យពាក្យដែលខ្លួនជារណប។ កម្មអាចជាកម្មរបស់កិរិយា-សព្ទ ឬ កម្មរបស់នាមសព្ទ( សូមមើល *ការបំបែកនាមសព្ទ* )។ តាមធម្មតា ចំពោះកិរិយាសព្ទ **កម្ម**ជា |

[1]- ពូវ អ៊ុម , វេយ្យាករណ៍ខ្មែរ បណ្ណាគារ គីម សេង ភ្នំពេញ ឆ្នាំ១៩៥៥ ទំព័រ៣២។

[2]- កេង វ៉ាន់សាក់ , មូលភាពនៃការបង្កើតពាក្យថ្មី , មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ ភ្នំពេញ ឆ្នាំ១៩៦៤ ទំព័រ៣៨១។

[3]- អ៊ុយ ជួន , *វេយ្យាករណ៍ពិសេស* រោងពុម្ព គឹម គី បណ្ណាគារលេខ៤៤ វិថីតេជោដំឌិន ភ្នំពេញ ឆ្នាំ១៩៥៨ ទំព័រ ២៤៣ និង ចូ ធន, *វេយ្យាករណ៍អក្ខរាវិរុទ្ធ* បណ្ណាគារ ឃុន ថៃស៊ាង ក្រចេះ ឆ្នាំ១៩៧១ ទំព័រ ១១៧។

[4]- ក្រសួងអប់រំ , វេយ្យាករណ៍ ថ្នាក់ទី៥ រោងពុម្ពរណសិរ្ស ភ្នំពេញ ឆ្នាំ១៩៨៣ ទំព័រ ១១៨។

| | |
|---|---|
| | ពាក្យឬកន្សោមពាក្យចាំបាច់សម្រាប់ពាក្យជំពូកនេះ ដែលប្រើជាប្រណាប់ប្រធាន[5]/បម្រាប់ប្រធាន ដើម្បីធ្វើឱ្យល្បះមានវេយ្យាករណភាព (មានលក្ខណៈស្របនឹងក្បួនវេយ្យាករណ៍), ឧទាហរណ៍ :<br>- គោស៊ី*ស្មៅ*,<br>- ខ្ញុំបានឱ្យ*សៀវភៅមួយក្បាល ទៅកូនប្រុសខ្ញុំ*,<br>- រឿង "កុលាបប៉ៃលិន" ត្រូវបាននិពន្ធ*ដោយលោក ញ៉ុក ថែម*។<br>គេចែក**កម្ម**របស់កិរិយាសព្ទជា កម្មបទផ្ទាល់ ឬមិនផ្ទាល់ (complément d'objet direct ou indirect), កម្មទេសកាល(complément circonstanciel), កម្មភ្នាក់ងារ (complément d'agent)។ |
| **២-កម្មទេសកាល**<br>អ. circumstantial complement<br>បារ. complément circonstanciel | កម្មប្រើសម្រាប់សម្គាល់ ពេលវេលា, ទីកន្លែង, មធ្យោបាយ, ... ឧទាហរណ៍ :<br>- ម្សិលមិញ ខ្ញុំបានទិញត្រីរស់មួយគីឡូ (*ម្សិលមិញ* ជាកម្មទេសកាលសម្គាល់ពេលវេលា)។<br>- គាត់ធ្វើការ នៅក្រសួងអប់រំ (*នៅក្រសួងអប់រំ* ជាកម្មទេសកាលសម្គាល់ទីកន្លែង)។ |

[5]- ពាក្យ *ប្រណាប់* មកពីពាក្យ *ប្រាប់* (ប្រាប់ > ប្រណាប់) ត្រូវបានបង្កើតឡើងតាមគំរូ *ទ្រាប់* > *ទ្រនាប់*។ *ប្រណាប់ប្រធាន* គឺជាគ្រឿងដែលប្រាប់ប្រធាន។ ចំណែក *បម្រាប់ប្រធាន* វិញគឺជាការប្រាប់ប្រធានឬគឺជាលទ្ធផលនៃការប្រាប់ប្រធាន។

| | |
|---|---|
| | - ខ្ញុំបានធ្វើដំណើរ តាមរថភ្លើង ( *តាមរថភ្លើង* ជាកម្មទេសកាលសម្គាល់មធ្យោបាយ )។ |
| **៣- កម្មបទ**<br>អ. object ( complement )<br>បារ. complément d'objet | កម្មប្រើជាមួយកិរិយាសកម្ម ដើម្បីឱ្យល្បះមានវេយ្យាករណភាព។ គេចែកកម្មបទ ជាពីរក្រុម :<br>- កម្មបទផ្ទាល់<br>- កម្មបទមិនផ្ទាល់<br>ឧទាហរណ៍ :<br>- គោស៊ីស្មៅ ( *ស្មៅ* ជាកម្មបទផ្ទាល់ )<br>- ខ្ញុំបានឱ្យសៀវភៅមួយទៅកូនប្រុសខ្ញុំ ( *ទៅកូនប្រុសខ្ញុំ* ជាកម្មបទមិនផ្ទាល់ )។ |
| **៤- កម្មភ្នាក់ងារ**<br>អ. agent<br>បារ. complément d'agent | កម្មប្រើសម្រាប់សម្គាល់អ្នកធ្វើអំពើ នៅក្នុងល្បះកម្មវាចកៈ, ឧទាហរណ៍ :<br>រឿង"សូផាត" ត្រូវបាននិពន្ធដោយលោក រីម គីន ( *ដោយលោក រីម គីន* ជាកម្មភ្នាក់ងារ )។ |
| **៥- កាឡារូប**<br>អ. allomorph<br>បារ. allomorphe ( m. ) | រូបតា[6]ដែលមានរូប[7]ផ្សេងគ្នា( ច្រើនតែស្រដៀងគ្នា )បណ្តាលមកពីបរិបទ ប៉ុន្តែរូបផ្សេងៗនោះ នៅតែសម្គាល់បញ្ញត្តិតែមួយដដែល ដូចជាកាឡារូបសម្គាល់ពហុវចនៈនៃនាមសព្ទអង់គ្លេសឬកាឡារូបសម្គាល់ន័យបដិសេធន៍( négation )នៃគុណនាម |

---

[6]- សូមមើលនិយមន័យពាក្យ *រូបតា* ដែលនៅតាមលំដាប់អក្ខរក្រមក្នុងសទ្ទានុក្រមនេះ។

[7]- "រូប" ជាសូរ (ពីព្រោះភាសាជាសូរ)។ ចំពោះអក្សរ "s" ដាក់នៅខាងចុងនាមសព្ទបារាំងជាច្រើននោះ វាគ្រាន់តែជាវត្ថុសិប្បនិម្មិត( objet artificiel )សម្រាប់ភ្នែក ព្រោះភាសាជាសូរៈ បើគេសរសេរពាក្យ "tables" ជាដើម វាមានសូរ [tabl] ដូចឯកវចនៈ ហើយទាល់តែគេដាក់ déterminants (les/des/mes/ces,…) ឱ្យទៅជា[letabl], [detabl], [metabl], [setabl],… នៅខាងឆ្វេង ទើបគេស្តាប់ដឹងថា វាជាពហុវចនៈ។

បារាំង ជាដើម, ឧទាហរណ៍ :

- ពហុវចនៈនៃនាមសព្ទអង់គ្លេសដែលមានកាឡូរូបដល់ទៅបី :
  - [-s ] ក្នុងពាក្យ [buk**s**] ( book**s** < book ), [tɔp**s**] ( top**s** < top ),...
  - [-z ] ក្នុងពាក្យ [dɔg**z**] ( dog**s** < dog ), [snɔb**z**] ( snob**s** < snob ),...
  - [-iz ] ក្នុងពាក្យ [bɔksiz] ( box**es** < box ), [kis**iz**] ( kiss**es** < kiss ), [bʌziz] ( buzzes < buzz ), ...។

*បញ្ជាក់* : *ដូចគ្នានឹងករណីសទ្ទតានិងកាឡូសូរដែរ ដែលគេចាត់ទុកកាឡូសូរនីមួយៗជាចំណែកមួយនៃសទ្ទតាមួយ(គេដាក់សទ្ទតានៅចន្លោះបន្ទាត់ទ្រេតពីរ និង កាឡូសូរនៅចន្លោះឃ្នាបពីរ) គេក៏ដាក់កាឡូរូបនៅចន្លោះឃ្នាប និង រូបតានៅចន្លោះបន្ទាត់ទ្រេតដូច្នោះដែរ: ដូច្នេះ រូបតា* /-s / មាន *កាឡូរូប* [-s ], [-**z** ], [-**iz** ] ។

*កំណត់សម្គាល់*

- [-s ] *ពីព្រោះរូបតាបន្តភ្ជាប់នឹងព្យញ្ជនៈអឃោសៈ* ;
- [-**z** ] *ពីព្រោះរូបតាបន្តភ្ជាប់នឹងព្យញ្ជនៈឃោសៈ* ;
- [-**iz** ] *ពីព្រោះព្យញ្ជនៈខាងចុងនៃពាក្យពាក់ព័ន្ធ ជាព្យញ្ជនៈ* [ x ], [s ] & [ **z** ] *ហើយកាឡូរូប* [-s ] *ឬ* [-z ] *មិនអាចបន្លឺសូររបស់ខ្លួនឱ្យដាច់ចេញពីព្យញ្ជនៈទាំងបីខាងលើនេះទេ។*

| | |
|---|---|
| | • ន័យបដិសេធន៍របស់គុណនាមបារាំងដែលមានរូបផ្សេងគ្នា(កាឡូរូប) បណ្ដាលមកពីបរិបទ ប៉ុន្តែរូបផ្សេងៗនោះនៅតែសម្គាល់បញ្ញត្តិតែមួយដដែល (គឺន័យបដិសេធន៍), ឧទាហរណ៍:<br>- [ɛ̃-] ក្នុងពាក្យ [ɛ̃kɔrɛk] (incorrect), [ ɛ̃prɔpr ] (impopre);<br>- [il-] ក្នុងពាក្យ[ilizibl] (illisible), [ilegal ] (illégal);<br>- [ir-] ក្នុងពាក្យ [iregylje] (irrégulier), [irevɛrsibl] (irréversible) ។<br>*<u>បញ្ជាក់</u> : ដូចករណីកាឡូរូបនៃពហុវចនៈរបស់នាមសព្ទអង់គ្លេសដែរ គេដាក់កាឡូរូបនានាសម្គាល់ន័យបដិសេធន៍នៅចន្លោះឃ្នាប និង រូបតានៅចន្លោះបន្ទាត់ទ្រេត: ដូច្នេះ រូបតា /ɛ̃-/ មានកាឡូរូបបី: [ɛ̃-], [il-], [ir-]* [8] ។<br><br>*<u>កំណត់សម្គាល់</u>*<br>*-គេប្រើ [ ɛ̃-] សម្រាប់ព្យញ្ជនៈស្ទើរតែទាំងអស់នៃអក្ខរក្រមបារាំង;*<br>*-គេប្រើ [il-]សម្រាប់ព្យញ្ជនៈ " l ";*<br>*-គេប្រើ [ir-]សម្រាប់ព្យញ្ជនៈ " r " ។* |

[8] ក្នុងចំណោមកាឡូរូបទាំងបី គេជ្រើសរើសយកកាឡូរូប [ɛ̃-] សម្រាប់តាងរូបតា ពីព្រោះកាឡូរូប [ɛ̃-] នេះមាន ច្រើនលើសលប់ ប៉ុន្តែក្នុងករណីដែលគ្មានកាឡូរូបណាមានចំនួនច្រើនជាងគេ យើងអាចជ្រើសរើសយកកាឡូរូបណាមួយក៏បានដែរដើម្បីតាងរូបតា។ ក្នុងករណីកាឡូរូបសម្គាល់ពហុវចនៈនៃនាមសព្ទអង់គ្លេស យើងបានជ្រើសរើសយកកាឡូរូប [-s] សម្រាប់តាងរូបតា ពិតមែនតែកាឡូរូប [-s] និងកាឡូរូប [-z] មានចំនួនប្រហាក់ប្រហែលគ្នា ពីព្រោះ [-s] ជាកាឡូរូបផងនិងជាព្យញ្ជនៈប្រើក្នុងអក្ខរាវិរុទ្ធសម្រាប់សម្គាល់ពហុវចនៈនៃនាមសព្ទផង។

| | |
|---|---|
| **៦- កាឡាសូរ**<br>អ. allophone<br>បារ. allophone<br>(m.) | សូរពីរប្លែកគ្នារបស់សទ្ទតាតែមួយដែលអាចជាបដិកាឡាសូរ គឺកាឡាសូរដែលចែកទីតាំងគ្នាក្នុងពាក្យ (allophones en distribution complé-mentaire) ឬ អាចជាកាឡាសូរជំនួសគ្នាបាន/កាឡាសូរសេរី(allophones en variation libre/variante libre), ឧទាហរណ៍ :<br>• ក្នុងភាសាបារាំង តំបន់ខាងត្បូង<br>[o] & [ɔ]ជាកាឡាសូរចែកទីតាំងគ្នា :<br>- [o] សម្រាប់ព្យាង្គបើក ៖ la chaux [ʃo]<br>- [ɔ] សម្រាប់ព្យាង្គបិទ ៖ la chose [ʃɔz] ;<br>•ក្នុងភាសាបារាំងស្តង់ដា ស្រៈ[ɑ]ខ្លី និងស្រៈ[ɑ:] វែង ជាកាឡាសូរសេរី ពីព្រោះទោះគេអានពាក្យ «pâte» ជាពាក្យខ្លី[pɑt]ក្តីឬជាពាក្យវែង[pɑ:t]ក្តី អំណានទាំងពីរនៅតែសម្គាល់វត្ថុដដែល[9]ផ្ទុយពីក្នុងភាសាអង់គ្លេសដែលស្រៈខ្លីនិងស្រៈវែងជាសទ្ទតាពីរផ្សេងគ្នា : ឧ. [ʃi:p](< sheep) គឺជាសត្វចៀម ≠[ʃip](< ship) គឺជាកប៉ាល់។<br><br>_បញ្ជាក់_ : *ក្នុងភាសាបារាំង [ɑ] (ខ្លី)និង[ɑ:] (វែង)ជាកាឡាសូរសេរី/បន្ទាស់ប្តូរសេរី រីឯក្នុងភាសាអង់គ្លេសវិញ [i] (ខ្លី)និង [i:] (វែង)ជាសទ្ទតាពីរផ្សេងគ្នា។* |
| **៧- ការបំបែក<br>កិរិយាសព្ទ** | ដំណើរបំបែកកិរិយាសព្ទដោយប្រើភាគខាងចុងប្លែកៗគ្នាទៅតាមបទមាលា(mode) តាមកាល |

[9]- សព្វថ្ងៃ បារាំងមានទំនោរអានពាក្យ "pâte"ដូចពាក្យ"patte" គឺ[pat]។

**អ.** conjugation
**បារ.** conjugaison (f.)

(temps) និងតាមបុរិស:(personne),ឧទាហរណ៍ : កិរិយាសព្ទបារាំង *marcher* ក្នុង mode indicatif, temps présent ត្រូវគេបំបែក ដូចតទៅ :

| បុរស | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បុរសទី១ | je marche | nous marchos |
| បុរសទី២ | tu mrches | vous marhez |
| បុរសទី៣ | il/elle marche | ils/elles marchent |

**៨- ការបំបែកនាម**
**អ.** declension
**បារ.** déclinaison (f.)

ដំណើរបំបែកនាមដោយប្រើភាគខាងចុងផ្សេងៗគ្នា ទៅតាមមុខងាររបស់វា។

នៅក្នុងវេយ្យាករណ៍បាលី វិភត្តិរបស់នាម មាន៨គឺ :

| វិភត្តិ | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បឋមាវិភត្តិ | បុរិសោ | បុរិសា |
| ទុតិយាវិភត្តិ | បុរិសំ | បុរិសេ |
| តតិយាវិភត្តិ | បុរិសេន | បុរិសេហិ, បុរិសេភិ |
| ចតុត្ថីវិភត្តិ | បុរិសស្ស, បុរិសាយ, បុរិសត្ថំ | បុរិសានំ |
| បញ្ចមីវិភត្តិ | បុរិសស្មា, បុរិសម្ហា, បុរិសា | បុរិសេហិ, បុរិសេភិ |
| ឆដ្ឋីវិភត្តិ | បុរិសស្ស | បុរិសានំ |
| សត្តមីវិភត្តិ | បុរិសស្មឹ, បុរិសម្ហិ, បុរិសេ | បុរិសេសុ |
| អាលបនៈ | បុរិស | បុរិសា |

**១.បឋមាវិភត្តិ**( ត្រូវនឹងវិភត្តិឡាតាំង nominatif ) សម្រាប់មុខងារជាប្រធាន, ឧទាហរណ៍:

១.ក. ឯកវចនៈ  បុរិសោ គេហំ គច្ឆតិ = បុរសម្នាក់ទៅ( កាន់ )ផ្ទះ។

១.ខ. ពហុវចនៈ បុរិសា គេហំ គច្ឆន្តិ = បុរសទាំងឡាយទៅ( កាន់ )ផ្ទះ។

**២-ទុតិយាវិភត្តិ**( ត្រូវនឹងវិភត្តិឡាតាំង accusatif ) សម្រាប់មុខងារជាកម្មបទផ្ទាល់( complément d'objet direct ), ឧទាហរណ៍:

២.ក. ឯកវចនៈ  អហំ បុរិសំ បស្សាមិ = ខ្ញុំឃើញ( នូវ )បុរសម្នាក់។

២.ខ. ពហុវចនៈ  អហំ បុរិសេ បស្សាមិ = ខ្ញុំឃើញ( នូវ )បុរសទាំងឡាយ។

**៣.តតិយាវិភត្តិ**( ablatif d'agent et ablatif d'instrument ) សម្រាប់មុខងារជាកម្មភ្នាក់ងារ, កម្មមធ្យោបាយ, ... ឧទាហរណ៍:

៣.ក. ឯកវចនៈ  អហំ បុរិសេន គេហំ គច្ឆាមិ = ខ្ញុំទៅ( កាន់ )ផ្ទះជាមួយនឹងបុរសម្នាក់។

៣.ខ. ពហុវចនៈ  អហំ បុរិសេហិ គេហំ គច្ឆាមិ = ខ្ញុំទៅ( កាន់ )ផ្ទះជាមួយនឹងបុរសទាំងឡាយ។

**៤.ចតុត្ថីវិភត្តិ**( ត្រូវនឹងវិភត្តិឡាតាំង datif ) សម្រាប់មុខងារជាកម្មសម្បទានប្រាប់សេចក្ដីទទួល ( complément d'attribution ), ឧទាហរណ៍:

៤.ក. ឯកវចនៈ  អហំ បុរិសស្ស ឱទនំ ទេមិ = ខ្ញុំជូន( នូវ )បាយដល់បុរសម្នាក់។

៤.ខ. ពហុវចនៈ  អហំ បុរិសានំ ឱទនំ ទេមិ = ខ្ញុំជូន( នូវ )បាយដល់បុរសទាំងឡាយ។

**៥.បញ្ចមីវិភត្តិ** សម្រាប់មុខងារជាកម្មអបាទាន ប្រាប់សេចក្ដីឃ្លាតចាក (ablatif de séparation), ឧទាហរណ៍:

៥.ក. ឯកវចនៈ  អហំ បុរិ<u>សស្មា</u> ឱទនំ គណ្ហាមិ = ខ្ញុំយក(នូវ)បាយ <u>ពីបុរសម្នាក់</u>។

៥.ខ. ពហុវចនៈ  អហំ បុរិ<u>សេហិ</u> ឱទនំ គណ្ហាមិ = ខ្ញុំយក(នូវ)បាយ <u>ពីបុរសទាំងឡាយ</u>។

**៦.ឆដ្ឋីវិភត្តិ** (ត្រូវនឹងវិភត្តិឡាតាំង génitif) សម្រាប់មុខងារជាកម្ម របស់នាម, ឧទាហរណ៍:

៦.ក. ឯកវចនៈ  អហំ បុរិ<u>សស្ស</u> ហត្ថំ បស្សាមិ = ខ្ញុំឃើញ(នូវ)ដៃ <u>របស់បុរសម្នាក់</u>។

៦.ខ. ពហុវចនៈ  អហំ បុរិ<u>សានំ</u> ហត្ថំ បស្សាមិ = ខ្ញុំឃើញ(នូវ)ដៃ <u>របស់បុរសទាំងឡាយ</u>។

**៧.សត្តមីវិភត្តិ**(locatif) សម្រាប់មុខងារជាកម្មទេសកាលសម្គាល់ ទីកន្លែង, ឧទាហរណ៍:

៧.ក. ឯកវចនៈ  ផលំ បុរិ<u>សស្មឹ</u> បតតិ = ផ្លែឈើធ្លាក់<u>លើបុរសម្នាក់</u>។

៧.ខ. ពហុវចនៈ  ផលានិ បុរិ<u>សេសុ</u> បតន្តិ = ផ្លែឈើទាំងឡាយធ្លាក់ <u>លើបុរសទាំងឡាយ</u>។

**៨.អាលបនៈ** (ត្រូវនឹងវិភត្តិឡាតាំង vocatif) សម្គាល់ការហៅរក (appellation), ឧទាហរណ៍:

៨.ក. ឯកវចនៈ  បុរិ<u>ស</u> កុហំ គច្ឆសិ = <u>ម្នាលបុរស</u>! អ្នកអញ្ជើញ ទៅណា?

៨.ខ. ពហុវចនៈ បុរិសា កុហំ គច្ឆថ = ម្នាលបុរសទាំងឡាយ! អ្នកទាំងឡាយអញ្ជើញទៅណា?

នៅក្នុងវេយ្យាករណ៍ឡាតាំង វិភត្តិរបស់នាមមាន៦ គឺ :

| វិភត្តិ/cas | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| **Nominatif** | **rosă** | **rosae** |
| **Vocatif** | **rosă** | **rosae** |
| **Accusatif** | **rosăm** | **rosās** |
| **Génitif** | **rosae** | **rosārŭm** |
| **Datif** | **rosae** | **rosīs** |
| **Ablatif** [10] | **rosā** | **rosīs** |

ឧទាហរណ៍នៃការប្រើប្រាស់នាមសព្ទទៅតាមcasរបស់វា :

(១)- Nominatif : សម្រាប់មុខងារប្រធាន (sujet), ឧទាហរណ៍ :

- In hortis crescet rosă.
- La rose pousse dans le jardin.
- ផ្កាកូលាបដុះក្នុងសួន។

(២)- Vocatif : សម្រាប់ហៅរក(Apostrophe, interpellation), ឧទាហរណ៍ :

- Rosă quam pulchra es.
- Rose, que tu es belle.
- ផ្កាកូលាបអើយ, ឯងស្អាតមែន!

(៣)- Accusatif : សម្រាប់មុខងារជាកម្មបទផ្ទាល់ (Complément

[10]- វិភត្តិឡាតាំង ablatif មានមុខងារជាកម្មទេសកាលច្រើនយ៉ាង។

d´objet direct), ឧទាហរណ៍ :

- Rosăm admiramini.

- Admirez la rose.

- សូមគយគន់ផ្កាកូលាប!

(៤)- Génitif : សម្រាប់មុខងារជាកម្មរបស់នាមសព្ទ (complément du nom), ឧទាហរណ៍ :

- Rosae pulchritudo.

- La beauté de la rose.

- សោភ័ណភាព(នៃ)ផ្កាកូលាប។

(៥)- Datif : សម្រាប់មុខងារជាកម្មសម្បទាន ប្រាប់សេចក្ដីទទួល (Complément d´attribution), ឧទាហរណ៍ :

- Rosae laudem tribuite.

- Donnons des louanges à la rose.

- សូមថ្លែងការសរសើរដល់ផ្កាកូលាប។

(៦)- Ablatif : សម្រាប់មុខងារជាកម្មទេសកាលប្រាប់មធ្យោបាយ, បែប, ប្រភព,...(Complément circonstanciel de moyen, de manière, d´origine,...), ឧទាហរណ៍ :

- Rosā florum fasciculus delectat.

- Ce bouquet séduit par sa rose.

- បាច់ផ្កានេះទាក់ចិត្តដោយសារផ្កាកូលាប។

*បញ្ជាក់* :

(១)- *ក្នុងភាសាឡាតាំង មុខងារនីមួយៗដែលសម្គាល់ដោយវិភត្តិហៅថា* cas, ឧ. cas nominatif, cas vocatif, ...

(២)- *ការបំបែកនាម*(déclinaison nominale)*មានច្រើនបែបទៅតាមក្រុមវា ប៉ុន្តែ យើងបង្ហាញតែការបំបែកនាមមួយបែប ដើម្បីឱ្យដឹងថា ភាសាឡាតាំង (ដូចភាសាបាលី) មានការបំបែកនាមទៅតាមមុខងាររបស់វា។*

(៣)- *ការបំបែកពាក្យ* (Déclinaison) *ក៏ទាក់ទងនឹងសព្វនាម*, *គុណនាម*, ... *ផងដែរ។*

| | |
|---|---|
| ៩- **កិរិយាសព្ទ**<br>អ. verb<br>បារ. verbe ( m. ) | ពាក្យដែលមានមុខងារសំខាន់ជាប្រណាប់ប្រធាន/បម្រាប់ប្រធាន ហើយ ដែលគេអាចដាក់ឱ្យទៅជាទម្រង់បដិសេធបាន,ឧទាហរណ៍ : ពាក្យ *ដើរ*, *ហូប*, *អាន*, *ទៅ*, *ដឹក*, *ហៅ*,... ជាកិរិយាសព្ទ។ |
| ១០- **កិរិយាវិសេសន៍ / គុណកិរិយា**<br>អ. adverb<br>បារ. adverbe ( m. ) | ពាក្យប្រើសម្រាប់សម្តែងលក្ខណៈឱ្យកិរិយាសព្ទ គុណនាម ឬ កិរិយាវិសេសន៍គ្នាឯង, ឧទាហរណ៍ :<br>- *ទឹកភ្នែកនាងហូរ**សស្រាក់**។*<br>- *ទីនេះងងឹត**ណាស់**។*<br>- *ឯងកុំដើរលឿន**ពេក**!* |
| ១១- **ខ្សែសំឡេង**<br>អ. vocal cords<br>បារ. cordes vocales ( f. ) | បន្ទះសាច់ដុំយឺតមួយគូដែលនៅក្នុងឡារ៉ាំង (larynx)។ នៅពេលបន្លឺសូរព្យញ្ជនៈ ខ្សែសំឡេងអាចញ័រ ឬ មិនញ័រ ៖ បើខ្សែសំឡេងញ័រ ព្យញ្ជនៈនោះជាព្យញ្ជនៈឃោសៈ ( voisée/ sonore ), បើខ្សែសំឡេងមិនញ័រ ព្យញ្ជនៈនោះជាព្យញ្ជនៈអឃោសៈ( non-voisée/sourde )។ ចំពោះការបន្លឺសូរស្រៈវិញ ខ្សែសំឡេងតែងតែញ័រជានិច្ច។ |

| | |
|---|---|
| **១២- គុណនាម**<br>អ. adjective<br>បារ. adjectif<br>( m. ) | ពាក្យអាស្រ័យនឹងនាម ហើយ ជាធាតុនៃកន្សោមនាម។ គេចែកគុណនាមជាពីរក្រុម :<br>- គុណនាមប្រក្រតី,<br>- គុណនាមកំណត់។<br>គុណនាមប្រក្រតីមានតែមួយប្រភេទទេ ប៉ុន្តែគុណនាមកំណត់មានច្រើនប្រភេទ គឺ :<br>- គុណនាមចង្អុល,<br>- គុណនាមចំនួន ( សំខ្យាសព្ទ ),<br>- គុណនាមមិនច្បាស់,...។<br>ពាក្យ *ខ្ពស់, ធំ , នេះ, នោះ, ពីរ, បី, ទាំងឡាយ, នានា* ... ជាគុណនាម។ |
| **១៣- គុណនាម ចង្អុល**<br>អ.demonstrative adjective<br>បារ. adjectif démonstratif | គុណនាមប្រើសម្រាប់ចង្អុលបង្ហាញមនុស្ស សត្វ វត្ថុ ឬ រុក្ខជាតិ ឱ្យឃើញច្បាស់លាស់ថានៅទីជិត ឬទីឆ្ងាយពីអ្នកនិយាយ, ឧទាហរណ៍ :<br>សៀវភៅ<u>នេះ</u>ជារបស់ខ្ញុំ,<br>សៀវភៅ<u>នោះ</u>ជារបស់ឯង។<br>ពាក្យ នេះ, នោះ, ទាំងនេះ, ទាំងនោះ,... ជាគុណនាមចង្អុល។ |
| **១៤- គុណនាម ចំនួន/សំខ្យាសព្ទ**<br>អ. numeral adjective | គុណនាមចំនួន ឬ សំខ្យាសព្ទ ជាពាក្យដែលប្រើសម្រាប់បញ្ជាក់ចំនួនឬលំដាប់។<br>គុណនាមចំនួន មានគុណនាមចំនួនសម្រាប់រាប់ និង គុណនាមសម្រាប់សម្គាល់លំដាប់, ឧទាហរណ៍: |

| | |
|---|---|
| បារ. adjectif numéral | -គុណនាមចំនួនសម្រាប់រាប់(បកតិសំខ្យា) : តុមួយ, ស្លាបព្រាមួយ ,...<br>-គុណនាមចំនួនសម្គាល់លំដាប់(បូរណសំខ្យា) : តុទី១, ស្លាបព្រាទី១ ...។<br>*<u>សង្កេត</u> : ចំពោះគុណនាមចំនួនសម្រាប់រាប់ បើគេដាក់គុណនាមនេះនៅមុខនាម វាមានន័យមួយយ៉ាង ហើយ បើគេដាក់វានៅក្រោយនាម វាមានន័យមួយយ៉ាងទៀត, ឧទាហរណ៍ :*<br>- *ផ្ទះមួយ សម្គាល់ចំនួនផ្ទះ,*<br>- *មួយផ្ទះ សម្គាល់ចំនួនមនុស្សដែលរស់នៅក្នុងផ្ទះណាមួយ។* |
| **១៥- គុណនាមប្រក្រតី**<br>អ. qualificative adjective<br>បារ. adjectif qualificatif | គុណនាមប្រក្រតីជាពាក្យមួយប្រភេទដែលអាស្រ័យនឹងនាម បញ្ជាក់លក្ខណៈឱ្យនាម ដូចកម្មរបស់នាមដែរ។<br>កម្មរបស់នាមអាចជានាមឬជាកិរិយាសព្ទ ប៉ុន្តែគុណនាមប្រក្រតីមានលក្ខណៈប្លែកពីកម្មរបស់នាម ដូចមានឧទាហរណ៍ខាងក្រោម :<br>១-ការបញ្ជាក់លក្ខណៈឱ្យនាម (ដូចកម្មរបស់នាមដែរ), ឧទាហរណ៍ :<br>១.១- ផ្ទះល្អ (*ល្អ* គុណនាមដែលមានមុខងារជាគុណបទ (épithète)របស់ *ផ្ទះ*),<br>១.២- ផ្ទះថ្ម (*ថ្ម* នាមដែលមានមុខងារជាកម្មរបស់ *ផ្ទះ*), |

| | |
|---|---|
| | ១.៣- ផ្ទះដួល ( *ដួល* កិរិយាសព្ទដែលមានមុខងារជាកម្មរបស់ *ផ្ទះ*),<br>គេអាចថា : *ផ្ទះដ៏ល្អ* ប៉ុន្តែគេមិនអាចថា :<br>**ផ្ទះដ៏ថ្ម* ឬ **ផ្ទះដ៏ដួល* បានឡើយ។<br>២-គេអាចដាក់គុណនាមប្រក្រតី *ល្អ* ឱ្យទៅជាវិសេសគុណនាម ឬ ជាអតិវិសេសគុណនាម ប៉ុន្តែកម្មរបស់នាមដែលជានាមឬជាកិរិយាសព្ទនោះ គេមិនអាចដាក់វាឱ្យទៅជាវិសេសគុណនាម ឬ អតិវិសេសគុណនាម បានទេ , ឧទាហរណ៍ :<br>២.១-*ផ្ទះល្អ* អាចដាក់ទៅជាវិសេសគុណនាម : *ផ្ទះនេះល្អជាងផ្ទះនោះ*<br>២.២-*ផ្ទះល្អ* អាចដាក់ទៅជាអតិវិសេសគុណនាម : *ផ្ទះនេះល្អណាស់ /ល្អពេក ,...*<br>រីឯ *ផ្ទះថ្ម* , *ផ្ទះដួល* វិញ គេមិនអាចដាក់វាឱ្យទៅជាវិសេសគុណនាម ឬ អតិវិសេសគុណនាមទេ, ឧទាហរណ៍ :<br>២.៣- **ផ្ទះនេះថ្មជាងផ្ទះនោះ,*<br>**ផ្ទះនេះដួលជាងផ្ទះនោះ,...*<br>២.៤- **ផ្ទះនេះថ្មណាស់,*<br>**ផ្ទះនេះដួលណាស់,...*<br>៣-គុណនាមប្រក្រតី អាចមានទម្រង់បដិសេធ (ដូចកិរិយាសព្ទដែរ ផ្ទុយពីនាមដែលជាកម្ម |

| | |
|---|---|
| | របស់នាមគ្នាឯង), ឧទាហរណ៍ :<br>៣.១- គុណនាមប្រក្រតី ៖ *ផ្ទះល្អ* > *ផ្ទះមិនល្អ*<br>៣.២- នាមដែលជាកម្មរបស់នាម :<br>*ផ្ទះថ្ម* > * *ផ្ទះមិនថ្ម។* |
| **១៦- គុណនាមមិនច្បាស់**<br>អ. indefinite adjective<br>បារ. adjectif indéfini | គុណនាមប្រើសម្រាប់បង្ហាញមនុស្ស សត្វ ឬ វត្ថុ ដោយមិនបញ្ជាក់ច្បាស់លាស់, ឧទាហរណ៍ :<br>- *និស្សិត<u>ណា</u>ដែលមិនបានប្រឡងថ្ងៃនេះ ត្រូវមកប្រឡងនៅពេលក្រោយ។*<br>- *សមាជិក<u>ទាំងអស់</u>ត្រូវមកជួបជុំគ្នានៅពេលរសៀល។*<br><br>ពាក្យ *ណា*, *ណាមួយ*, *ណាម្នាក់*, *ទាំងឡាយ*, *ទាំងពួង*, *ទាំងអស់*,... ជាគុណនាមមិនច្បាស់។ |
| **១៧- គុណបទ**<br>អ. epithet / attributive<br>បារ. épithète (f.) | មុខងារវេយ្យាករណ៍[11] (fonction grammaticale) របស់គុណនាម ដែលប្រើផ្ទាល់ជាមួយនាមសព្ទ, ឧទាហរណ៍ :<br>- ផ្ទះ<u>**ធំ**</u>នេះ សង់ជិតផ្លូវពេក។<br>- ខ្ញុំមិនចូលចិត្តមនុស្ស<u>**ចាស់**</u>ដែលខ្វះខន្តីទេ។ |
| **១៨- គុណប្រធាន**<br>អ. attribute | មុខងារវេយ្យាករណ៍របស់ពាក្យដែលបញ្ជាក់លក្ខណៈរបស់ប្រធាន, ឧទាហរណ៍ : |

[11]- មុខងារវេយ្យាករណ៍ គឺជាតួនាទីរបស់ឯកតាភាសា (សទ្ទតា, រូបតា, ពាក្យ, កន្សោមពាក្យ,...) ក្នុងការផ្គុំពាក្យជាកន្សោម ជាឃ្លា ជាល្បះ។

| | |
|---|---|
| បារ. attribut (du sujet) | ឪពុកខ្ញុំជាគ្រូបង្រៀន ( *គ្រូបង្រៀន* ជាគុណ-ប្រធានរបស់ *ឪពុកខ្ញុំ* ។)<br><br>*<u>សង្កេត</u> : បន្ទែករវាងគុណប្រធាននិងកម្មបទផ្ទាល់ នៅត្រង់ថា គុណប្រធានឥតរងអំពើដូចកម្មបទផ្ទាល់ទេ។* |
| **១៩-ឃោសៈ**<br>អ. voiced<br>បារ. voisée/ sonore ( f. ) | ព្យញ្ជនៈដែលនៅពេលបន្លឺ មានលំញ័រខ្សែសំ-ឡេង។ ព្យញ្ជនៈ / l /, / d /, / b /,... ជាព្យញ្ជនៈឃោសៈ។ |
| **២០- ឈ្នាប់**<br>អ. conjunction<br>បារ. conjonction ( f. ) | បញ្ញត្តិនេះក៏ត្រូវបានគេសម្គាល់ដោយពាក្យផ្សេងៗគ្នា ដូចជា :<br>- និបាតសព្ទ [12]<br>- សន្ធានសព្ទ [13]<br>- ឈ្នាប់ [14]<br>- ចំណង [15]<br><br>គណៈកម្មការភាសាវិទ្យានិងអក្សរសិល្ប៍ បានសម្រេចជ្រើសរើសយកពាក្យ *ឈ្នាប់* ហើយកំណត់ន័យ ដូចតទៅ : |

[12]- វចនានុក្រមខ្មែរ , ពុទ្ធសាសនបណ្ឌិត្យ , ឆ្នាំ១៩៦៨ , ទំព័រ៥១១។

[13]- តិប យក់ & ថាវ គន្ធ : វចនានុក្រមបារាំង-ខ្មែរសង្ខេប , បណ្ណាគារភ្នំពេញ, ឆ្នាំ១៩៦៧ , ទំព័រ២៣៤។

[14]- វេយ្យាករណ៍ថ្នាក់ទី៦, ក្រសួងអប់រំ , ឆ្នាំ១៩៨២ , ទំព័រ៤២។

[15]- ឃឹន សុខ : វេយ្យាករណ៍ភាសាខ្មែរ , រាជបណ្ឌិត្យសភាកម្ពុជា , ឆ្នាំ២០០៧ , ទំព័រ៣៨៧។

| | |
|---|---|
| | ឈ្នាប់ជាពាក្យដែលគេប្រើសម្រាប់ភ្ជាប់ពាក្យទៅនឹងពាក្យ , កន្សោមពាក្យទៅនឹងកន្សោមពាក្យ ឬ ល្បះទៅនឹងល្បះ។<br>ពាក្យ *និង, ឬ, ប៉ុន្តែ, ពីព្រោះ, ព្រោះ, បើ,....* ជាឈ្នាប់។<br>គេចែកឈ្នាប់ជាពីរបែប គឺ ឈ្នាប់ចង និង ឈ្នាប់ឃ្លា។ |
| **២១- ឈ្នាប់ឃ្លា**<br>អ. subordinating conjunction<br>បារ. conjonction de subordination | ឈ្នាប់ប្រើសម្រាប់ភ្ជាប់ល្បះរណបទៅនឹងល្បះច្បង, ឧទាហរណ៍ :<br>- ខ្ញុំលើកទ័ព **ពីព្រោះ**ខ្ញុំឮត្លុមវាយស្គរ [16]។<br>- គាត់នឹងបង្ហើយកិច្ចការនេះ **បើ**គាត់ត្រឡប់មកវិញ។ |
| **២២- ឈ្នាប់ចង**<br>អ.coordinating conjunction<br>បារ. conjonction de coordination | ឈ្នាប់ប្រើសម្រាប់ភ្ជាប់ធាតុពីរដែលមានមុខងារដូចគ្នាក្នុងល្បះ, ល្បះពីរដែលមានប្រភេទដូចគ្នា , ឧទាហរណ៍ :<br>- ខ្លា**និង**ស្វា បបួលគ្នាទៅជួបនឹងទន្សាយ[17]។<br>- ក្នុងគ្រានេះ, ខ្ញុំលៃពេលម៉ោង( ... ), បានដកស្រង់យកកាព្យ ( ... ),សុភាសិត**និង**ភាសិត |

[16]- ប្រជុំរឿងព្រេងខ្មែរ ភាគទី១ ទំព័រ២៣។
[17]- ប្រជុំរឿងព្រេងខ្មែរ ភាគទី១ ទំព័រ៣៥។

| | |
|---|---|
| | បុរាណខ្លះ <u>និង</u> កាព្យរបស់ខ្ញុំខ្លះ[18] (...), (វចនានុក្រមពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧, និទាន, ទំព័រ ង)។<br>- ឯងត្រូវការទឹកឬកាហ្វេ ?<br>- គាត់ធ្វើការនៅរាជបណ្ឌិត្យសភាកម្ពុជា <u>**ឯ**</u> ប្រពន្ធគាត់ធ្វើការនៅក្រសួងអប់រំ។<br>- ប្រជាជនយើងរស់នៅទីកន្លែងផ្សេងៗគ្នា។ អ្នកខ្លះរស់នៅស្រុកទន្លេ ខ្លះរស់នៅស្រុកភ្នំ ខ្លះរស់នៅស្រុកស្រែ <u>**និង**</u> ខ្លះទៀតរស់នៅទីក្រុង។ |
| **២៣- ទីបន្លឺ**<br>អ. place of articulation<br>បារ. point (m.) d'articulation | ចំណុចនៅផ្នែកខាងលើនៃគុហាមាត់ (ធ្មេញលើ ជើងធ្មេញលើ ក្រអូម រនាំងក្រអូម ចុងរនាំងក្រអូម/កន្លើត...) ដែលអណ្ដាតធ្វើចលនាទៅប៉ះ ដើម្បីបង្កើតសូរណាមួយ។ |
| **២៤- ធនិត**<br>អ. aspirated<br>បារ. aspirée (f.) | ព្យញ្ជនៈដែលមានសូរ [h] ផ្សំជាមួយ។ ក្នុងភាសាបាលី សំស្រ្កឹត ព្យញ្ជនៈធនិតមាន ៖ [ក្ខ/kh] , [គ្ឃ /gh] ,[ច្ឆ /ch] , [ជ្ឈ /jh] , [ដ្ឋ / ṭh] , [ឌ្ឍ /ḍh] , [ត្ថ /th] , [ទ្ធ /dh] , [ប្ផ /ph] , [ព្ភ/bh]។ |

[18] - ចំពោះការដកឃ្លា (ដំណកឃ្លា)សូមអានអត្ថបទ *ពិនិត្យពិចារណាលើការប្រើប្រាស់សញ្ញាប្រយោគមួយចំនួន ក្នុងភាសាខ្មែរបច្ចុប្បន្ន* ដោយ ព្រុំ ម៉ល់ , បទអន្តរាគមន៍ក្នុងសន្និសីទជាតិ លើកទី២ រៀបចំដោយវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៥ និង ចុះជាឧបសម្ព័ន្ធ ក្នុងវេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប ភាគ២ ឆ្នាំ២០០៦, ទំព័រ៦៣-៧៦។

| | |
|---|---|
| **២៥- ធ្នាក់**<br>អ. preposition<br>បារ. préposition<br>(f.) | បញ្ញត្តិនេះត្រូវបានគេសម្គាល់ដោយពាក្យផ្សេងៗគ្នា :<br>- អាយតនិបាត [19]<br>- និបាតសព្ទ[20]<br>- ធ្នាក់ [21]<br>- ស្នៀត [22]<br>គណៈកម្មការភាសាវិទ្យានិងអក្សរសិល្ប៍បានសម្រេចជ្រើសរើសយកពាក្យ **ធ្នាក់** និង កំណត់ន័យ ដូចតទៅ :<br>ធ្នាក់ជាពាក្យប្រើជាមួយនឹង នាម កន្សោមនាម ឬ កន្សោមកិរិយា ដើម្បីបង្កើតកន្សោមធ្នាក់ (កន្សោមមានធ្នាក់) , ឧទាហរណ៍ :<br>- វិទ្យាស្ថានភាសាជាតិ **នៃ**រាជបណ្ឌិត្យសភាកម្ពុជា។<br>- **ក្នុង**ផ្ទះ , **ក្រៅ**ផ្ទះ ។<br>ពាក្យ *នៃ លើ ក្នុង ក្រៅ ជាមួយ ពី អំពី ដល់ ដោយ* ... ជាធ្នាក់។ |

[19]- វចនានុក្រមខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៨, ទំព័រ១៧៤៤ និង ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ , បណ្ណាគារ គឹម សេង , ភ្នំពេញ , ១៩៥៨។

[20]- កេង វ៉ាន់សាក់ : មូលភាពនៃការបង្កើតពាក្យថ្មី , មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ ភ្នំពេញ ឆ្នាំ១៩៦៤ ទំព័រ៣៨៣។

[21]- វេយ្យាករណ៍ថ្នាក់ទី៦, ក្រសួងអប់រំ, ឆ្នាំ១៩៨២ , ទំព័រ៤១។

[22]- ឃីន សុខ : វេយ្យាករណ៍ភាសាខ្មែរ , រាជបណ្ឌិត្យសភាកម្ពុជា , ឆ្នាំ២០០៧ , ទំព័រ៣៥៧។

| | |
|---|---|
| ២៦-**ន័យ**<br>អ. sense/ meaning<br>បារ. sens (m.) | ន័យរបស់ពាក្យណាមួយជាអ្វីដែលពាក្យនោះស្តែងឡើង។ *ន័យ* ប្លែកពី *ន័យកម្ម* ត្រង់ថា ន័យឥតមានអរូបីយភាពខ្លាំងដូចន័យកម្មទេ ពីព្រោះន័យ ឋិតនៅក្នុងប្រព័ន្ធទម្លាប់វាចា (ទម្លាប់នៃការប្រើប្រាស់ភាសា)។ ន័យក៏មិនអាចមានវង្វង់ធំធេងដូចន័យកម្មដែរ ពីព្រោះវាលំឱនទៅតាមបរិបទ។ តាមធម្មតា វចនានុក្រមឱ្យត្រឹមតែន័យចំរបស់ពាក្យដែលគេហៅថា *អត្ថានុរូប(sens propre)*។ រីឯន័យធៀប គេត្រូវបញ្ជាក់បន្ថែមតាមលំហៅថា *អត្ថបដិរូប(sens figuré)*, ឧទាហរណ៍ :<br><br>**សេតវិមាន**<br>១. កាលពីឆ្នាំទៅ ពេលដែលឪពុកមាខ្ញុំទៅលេងសហរដ្ឋអាម៉េរិក គាត់បានថតរូបនៅមុខ**សេតវិមាន**។<br>២. **សេតវិមាន**បានសម្រេចបញ្ជូនកងទ័ពទៅវាយលុកផ្តួលរំលំរដ្ឋាភិបាលរបស់លោកសាដាំ ហ៊ូសេន នៅឆ្នាំ២០០២។ |
| ២៧- **ន័យកម្ម**<br>អ. signification<br>បារ. signification (m.) | ជាបញ្ញត្តិដែលមានវិសាលភាពគ្របដណ្តប់លើន័យទាំងឡាយរបស់ឯកតាភាសាមួយ។ ន័យកម្មជាផលវិភាគនៃភាសាវិទ្យា។ សព្វថ្ងៃ មិនទាន់មានវចនានុក្រមណាបានស្វែងរកជាទូទៅនូវន័យកម្មបែបនេះនៅឡើយ។ |

**២៨- ន័យកម្មវិទ្យា**
អ. semiology
បារ. semiologie
( f. )

វិជ្ជាសិក្សាអំពីន័យកម្មត្រឹមកម្រិតដែលអាចធ្វើបាន ដូចជា ឯកតាន័យ (unité de sens), ទំនាក់ទំនងន័យ (relation sémantique) ជាដើម។

ការបំបែកពាក្យជាន័យតា មានដូចខាងក្រោម (សូមមើលការពន្យល់អំពីន័យតា)។ ការសិក្សាអំពីទំនាក់ទំនងន័យដែលមានក្នុង បដិសព្ទ, វេវចនសព្ទ, សទិសសព្ទ ជាដើម ត្រូវផ្អែកលើន័យតាដើម្បីឱ្យការសិក្សាមានរូបីភាព ងាយយល់ ដូចមានឧទាហរណ៍ទាក់ទងនឹងបដិសព្ទ ខាងក្រោម :




**២៩- ន័យករ**
អ. signifier
បារ. signifiant
( m. )

ទម្រង់សូរដែលយើងស្ដាប់ឮ កាលណាសូរសព្ទ-ភាសាត្រូវបានបន្លឺឡើង ប៉ុន្តែគប្បីយើងបញ្ជាក់បន្ថែមថា តាមលោក Saussure ន័យករ មិនមែនជាសូរនិច្ចល[23]( inerte ) ដូចសូរធម្មតាទេ: ន័យករហាក់ដូចជាមានចរន្តអ្វីមួយមកដាស់សតិអារម្មណ៍យើងកាលណាយើងរៀបប្រើ ឬ កាលណាយើងស្ដាប់ឮសូរសព្ទភាសាណាមួយ ពីព្រោះ ន័យករនៃ

[23] - ពាក្យ និច្ចល ( និច-ចល់ ) ត្រូវនឹងពាក្យបារាំង *inerte* ខ្ចីពីវចនានុក្រមបារាំង-ខ្មែររបស់លោក តិប យក់ & ថាវ គន្ធ បណ្ណាគារ ប៊ុត នាង ភ្នំពេញ ឆ្នាំ១៩៦២។

| | |
|---|---|
| | សូរសព្ទភាសានីមួយៗ តែងតែជិតដោយអនុស្សាវរីយ៍និង connotation ជានិច្ច។<br>ដំបូងឡើយ ទំនាក់ទំនងរវាងន័យករ និង ន័យបញ្ញត្តិ ជាជម្រើសសេរី : គេអាចយកន័យករណាមួយទៅសម្គាល់ន័យបញ្ញត្តិណាមួយក៏បានដែរ (លើកលែងតែចំពោះន័យបញ្ញត្តិនៃសូរសព្ទភាសាណាដែលជាប់ផៅសន្តានជាមួយនឹងសូរសព្ទភាសាឯទៀតរួចទៅហើយ)។ |
| **៣០- ន័យតា**<br>អ. component<br>បារ. sème (m.) | ពាក្យ **ន័យតា** ជាបម្រែនៃពាក្យ "sème" របស់លោក ប៉ែរណា ប៉ូជេ (Bernard Pottier) ដែលភាសាវិទូអាម៉េរិកាំងហៅថា "component"។<br>ន័យតាជាបំណែកន័យ ដែលអាចវិភាគចេញពីវចនតា/ពីពាក្យទោលណាមួយ, ឧទាហរណ៍ :<br>• ចូល → + ក្នុង<br>+ កិរិយាសព្ទ<br>- កម្មបទ (C.d'objet)<br>+ ចលនា<br>• ចេញ → - ក្នុង<br>+ កិរិយាសព្ទ<br>- កម្មបទ (C.d'objet)<br>+ ចលនា |
| **៣១- ន័យបញ្ញត្តិ**<br>អ. signified | សញ្ញាណ/បញ្ញត្តិ ដែលមាន **ន័យករ** ជាទម្រសូរព្ទមកក្រៅ កាលណាសូរសព្ទភាសាត្រូវបានគេបន្លឺ |

| | |
|---|---|
| បារ. signifié (m.) | ឡើង។ ដូចយើងបានឃើញស្រាប់ **ន័យបញ្ញត្តិ** អាចចាត់ទុកជាទំព័រម្ខាងនៃសូរសព្ទភាសាដែល អាចប្រៀបបាននឹងក្រដាស១សន្លឹក ហើយ **ន័យ-បញ្ញត្តិ**នេះមិនអាចបំបែកចេញបានពី**ន័យករ**ដែល ជាទំព័រម្ខាងទៀតនោះឡើយ។ |
| ៣២- **ន័យវិទ្យា**<br>អ. semantics<br>បារ. sémantique (f.) | វិជ្ជាសិក្សាអំពីន័យដែលបានស្ថាបនានៅក្នុង បរិបទផ្សេងៗ ដូចមានឧទាហរណ៍ខាងលើស្រាប់ (សូមមើលការពន្យល់អំពី*ន័យ*)។ |
| ៣៣- **នាម**<br>អ. noun<br>បារ. nom (m.) | ពាក្យសម្រាប់សម្គាល់ឈ្មោះ មនុស្ស, សត្វ, រុក្ខ-ជាតិ, ទីកន្លែង, វត្ថុ, ស្ថានភាព, សកម្មភាព ឬ គំនិតអ្វីមួយ និង អាចបំពេញមុខងារជាប្រធាន ឬ កម្ម នៅក្នុងល្បះ។ នាមជាធាតុចាំបាច់នៃកន្សោម នាម។<br>ពាក្យ *ពូសុខ តុ គោ ដំណើរ ឈ្មួញ រដ្ឋាភិបាល* ... ជានាម។ |
| ៣៤- **បច្ច័មបទ/ផ្នត់ចុង**<br>អ. suffix<br>បារ. suffixe(m.) | អក្ខាសបទ/ផ្នត់មួយបែបដែលគេដាក់នៅខាងចុង នៃពាក្យ ដើម្បីបង្កើតពាក្យកម្លាយ។<br>-ក្នុងភាសាអង់គ្លេស បច្ច័មបទ/ផ្នត់ចុង ly ភ្ជាប់នឹង គុណនាម slow បង្កើតបានជាកិរិយាវិសេសន៍ slowly ។<br>- ក្នុងភាសាបារាំង បច្ច័មបទ/ផ្នត់ចុង ment ភ្ជាប់ នឹងគុណនាម lent បង្កើតបាន ជាកិរិយាវិសេសន៍ |

| | |
|---|---|
| | lentement ។<br>- តាមមតិទូទៅ ភាសាខ្មែរសុទ្ធគ្មានបច្ឆិមបទ/ផ្នត់-ចុងទេ។ ប៉ុន្តែពាក្យខ្មែរដែលកើតពីជាតុបាលី-សំស្ក្រឹតមានប្រើបច្ឆិមបទ/ផ្នត់ចុង ដូចជា :<br>- ពល + ករ > ពលករ,<br>- នគរ + ឧបនីយកម្ម > នគរូបនីយកម្ម។ |
| **៣៥- បដិសព្ទ**<br>អ. antonym<br>បារ. antonyme<br>( m. ) | ពាក្យទាំងឡាយដែលមានន័យផ្ទុយគ្នា ,<br>ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>• ពាក្យ **ញី** ជាបដិសព្ទរបស់ពាក្យ **ឈ្មោល**,<br>• ពាក្យ **ទិញ** ជាបដិសព្ទរបស់ពាក្យ **លក់** ,...<br>- <u>ក្នុងភាសាបារាំង</u> :<br>• ពាក្យ mâle ជាបដិសព្ទរបស់ពាក្យ femelle,<br>• ពាក្យ acheter ជាបដិសព្ទរបស់ពាក្យ vendre,...<br><br>បដិសព្ទមានព្រំដែនមិនដាក់លាក់ ព្រោះវាអាចជា ៖<br>-បដិសព្ទសម្គាល់ភាពប្រៀបធៀប( opposition ):<br>តូច និង ធំ ,...<br>-បដិសព្ទសម្គាល់ប្រតិភាព ឬ ទៅវិញទៅមក ( réciprocité ) : ទិញ និង លក់ ,<br>ប្ដី និង ប្រពន្ធ ,... |

| | |
|---|---|
| | -បដិសព្ទសម្គាល់ភាពដៃគូនឹងគ្នា (complé-mentarité) : រស់ និង ស្លាប់ ,... |
| **៣៦- បុព្វបទ / ផ្នត់ដើម**<br>អ. prefix<br>បារ. préfixe (m.) | អក្ខរាសបទឬផ្នត់មួយបែបដែលគេដាក់នៅខាងដើមពាក្យ ដើម្បីបង្កើតពាក្យកម្លាយ , ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>បុព្វបទ/ផ្នត់ដើម [ប´ញ-] + ចូល > បញ្ចូល,<br>បុព្វបទ/ផ្នត់ដើម [លំ-] + នៅ > លំនៅ,...<br>- <u>ក្នុងភាសាបារាំង</u> :<br>បុព្វបទ/ផ្នត់ដើម in + correct > incorrect,<br>បុព្វបទ/ផ្នត់ដើម dé + former > déformer,... |
| **៣៧- បូរណសព្ទ**<br>អ. lexis<br>បារ. lexie (f.) | មូលតា (វចនតា និង រូបតា) ជាកំណាត់ ក្នុងខ្សែសម្ដីដែលងាយសម្គាល់តាមរយៈន័យអប្បបរមារបស់វា ប៉ុន្តែ អ្នកប្រើប្រាស់ភាសាឥតមានលទ្ធភាពផ្គុំវាដោយសេរី ជាទូទៅទេ។ តំណរវាងមូលតាខ្លះត្រូវភាសាបង្ខំឱ្យអ្នកប្រើប្រាស់ទទួលយកតែម្ដង។ តំណដែលភាសាបង្ខំឱ្យអ្នកប្រើប្រាស់ទទួលយកនេះ ត្រូវបានបែរណា ប៉ូជេ (Bernard Pottier) ហៅថា lexie ដែលយើងប្រែថា បូរណសព្ទ។<br>តាមគាត់ បូរណសព្ទ ជាកំណាត់ទោល ដូច cheval ឬ ជាកំណាត់ល្បាយ ដូច cheval-vapeur ឬ cheval marin ដែលមានឯកភាព |

| | |
|---|---|
| | មិនអាចកាត់តបែបណាទៀតបានទេ ហើយ ដែលយើងត្រូវប្រើទាំងស្រុង។ បូរណសព្ទ មាន ពាក្យ-ទោល (mots irréductible), ពាក្យកម្លាយ(mots dérivés), ពាក្យសមាស (mots composés), វាចាវិលាស[24](locutions),ពាក្យកាត់(sigle)។ល។<br><br>យើងតែងតែពិបាកសម្គាល់បន្លែករវាងបូរណ-សព្ទ និង កន្សោមេសរី កើតពីការផ្គុំពាក្យតាមសេចក្ដីត្រូវការដើម្បីបញ្ចេញមតិ។ ដើម្បីដោះ-ស្រាយបញ្ហានេះ ភាសាវិទូមួយក្រុម[25] បានបង្កើតតេស្ត(test) បួនបែបផ្អែកលើលក្ខណៈវិនិច្ឆ័យរូប-និយម (critères formels) ដែលអាចឱ្យគេសម្គាល់បន្លែករវាង បូរណសព្ទ និង កន្សោមសេរីនេះបាន[26]។ |

24- វាក្យសព្ទខ្ចីពីវចនានុក្រមបារាំង-ខ្មែរ របស់លោក តិប យក់ &ថាវ គន្ធ, បណ្ណាគារ ប៊ុត នាង ភ្នំពេញ ឆ្នាំ១៩២៦។

25 - សូមអាន Jean-louis CHISS et alli, Initiation à la linguistique structurale, tome 1, p. 154, Hachette 1981.

26 - ដើម្បីយល់ច្បាស់អំពីការប្រើប្រាស់តេស្តទាំងនោះ សូមអាន មូលដ្ឋាននៃន័យកម្មវិទ្យា ដោយ ព្រុំ ម៉ល់ ផ្សព្វផ្សាយដោយអ្នកនិពន្ធ ទំព័រ១៦-២០, ភ្នំពេញ ឆ្នាំ២០០៣។ ជាគោលៗ យើងសូមរាប់ឈ្មោះតេស្តទាំងនោះ ដូចតទៅ ៖ តេស្តដែក (test d'insertion), តេស្តកំណាត់ (test de répétition partielle), តេស្តដាក់កត្តារួម (test de mise en facteur commun)និង តេស្តដំណូរ (test de commutation)។

| | |
|---|---|
| **៣៨-ប្រណាប់ប្រធាន/ បម្រាប់ប្រធាន**<br>អ. predicate<br>បារ. prédicat (m.) | មុខងារនៃពាក្យក្នុងឈ្មោះ/ប្រយោគដែលតាមធម្មតា ជាមុខងាររបស់កិរិយាសព្ទ, ឧទាហរណ៍ :<br>-មាន់រងាវ។<br>-គោស៊ីស្មៅ។<br>កិរិយាសព្ទ *រងាវ*, *ស៊ីស្មៅ* ជាប្រណាប់ប្រធាន/ បម្រាប់ប្រធាន។ |
| **៣៩- ប្រធាន**<br>អ. subject<br>បារ. sujet (m.) | មុខងារនៃពាក្យក្នុងឈ្មោះ/ប្រយោគដែលតាមធម្មតា ជាមុខងារនៃនាមសព្ទឬសព្វនាម (ទោលឬមានរណប) ឈមនឹងមុខងារនៃកិរិយាសព្ទ ហៅថា ប្រណាប់ប្រធាន /បម្រាប់ប្រធាន , ឧទាហរណ៍ :<br>- មាន់រងាវ។<br>- មាន់ឈ្មោលរបស់ខ្ញុំកំពុងរងាវ។<br>- វាដាស់កសិករឱ្យក្រោកធ្វើការ។<br>នាមសព្ទទោលឬមានរណប *មាន់*, *មាន់ឈ្មោលរបស់ខ្ញុំ* និង សព្វនាម *វា* ជាប្រធាន។ |
| **៤០- ផ្លូវខ្យល់**<br>អ. air exit<br>បារ. sortie (f.) de l’air (m.) | ផ្លូវដែលខ្យល់ក្នុងសួតចេញមកក្រៅនៅពេលបន្លឺសូរ។ នៅពេលបន្លឺសូរ ខ្យល់ក្នុងសួតជាក់ចេញមកក្រៅ ហើយ រនាំងក្រអូមបិទ ឬ បើកចំហផ្លូវប្រមុះ។<br>- កាលណារនាំងក្រអូមបិទផ្លូវប្រមុះ ខ្យល់ចេញតែតាមមាត់។ សូរដែលកើតឡើង ជាសូរមាត់ឬមុខជៈ ដូចជា [p], [b], [f], [v], [s],...។ |

| | |
|---|---|
| | - កាលណារនាំងក្រអូមបើកចំហ ខ្យល់ចេញតាមមាត់ផង តាមច្រមុះផង។ សូរដែលកើតឡើងជាសូរច្រមុះឬនាសិកជៈ ដូចជា [m], [n], [ɲ], [ŋ],...។ |
| **៤១- ពាក្យ**<br>អ. word<br>បារ. mot (m.) | សព្វថ្ងៃ ក្នុងមជ្ឈដ្ឋានអ្នកចេះដឹង វចនតា "mot" នៃភាសាបារាំង (ដែលត្រូវនឹង វចនតា "ពាក្យ"[27] នៃភាសាខ្មែរ) ឈប់មានន័យថាជាផ្លាកឬសំណេរទៀតហើយ ដូច្នេះ គេចូលចិត្តយក "mot" មកប្រើវិញ ពីព្រោះវាមិនមែនជាកន្សោមពាក្យ ដូច "signe linguistique" ដែលជាខ្សែសម្ដីវែងអន្លាយ។ ប៉ុន្តែគេមានបញ្ហាក្នុងការកំណត់ព្រំដែន ពី "mot" មួយទៅ "mot" មួយ ក្នុងខ្សែសម្ដី : គេមិនអាចដឹងដោយងាយក្នុងខ្សែសម្ដី ថាតើ "mot" ណាចាប់ផ្ដើមពីត្រង់ណា ហើយ ត្រូវចប់នៅត្រង់ណាទេ។<br>វេយ្យាករណ៍បារាំងបានចែកពាក្យបារាំងជា៩ប្រភេទ គឺ articles, noms, pronoms, adjectifs, verbes, adverbes, prépositions, conjonctions & interjections ។ គេថា "les" ជាពាក្យមួយម៉ាត់ គឺជា "article" តែ "les pommes de terre" ក៏ជាពាក្យមួយម៉ាត់ដែរ |

[27]- ក្នុងស្មារតីខ្មែរភាគច្រើន វចនតា " ពាក្យ" នៃភាសាខ្មែរ ធ្វើឱ្យគេនឹកដល់ផ្លាកនៅឡើយ ជាពិសេសនឹកដល់ពាក្យសរសេរ ផ្ទុយពីសូរសព្ទភាសា។

| | |
|---|---|
| | (ពាក្យសមាស)។ ដូច្នេះ ឃើញថា យើងពិបាកសម្គាល់ព្រំដែនពាក្យបារាំងណាស់[28]។ ដោយ "signe linguistique" របស់លោក Saussure បានដោះស្រាយត្រឹមតែមិនឱ្យយល់ច្រឡំថា"mots" ជាសំណេរនិងដោយបញ្ហាសម្គាល់ព្រំដែននៃពាក្យនៅចោទដដែល លោក ប៊ែរណា ប៉ូដេ (Bernard Pottier) បានស្នើឱ្យប្រើ " lexie " វិញម្តង។ |
| **៤២- ពាក្យកម្លាយ**<br>អ. derivative word<br>បារ. mot (m.) dérivé | ពាក្យដែលកើតចេញពីវិធីកម្លាយ, ឧទាហរណ៍ :<br>ប្តឹង < ដឹង + [ប៉- ],<br>ឃ្នាប < គាប + [-ន-] ។ |
| **៤៣- ពាក្យក្លាយ**<br>អ. transformed word<br>បារ. mot (m.) transformé | ពាក្យដែលបានផ្លាស់ប្តូររូបសព្ទ ខុសប្លែកពីពាក្យដើម ដោយបានឆ្លងកាត់មួយរយៈពេលនៃការប្រើប្រាស់, ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>français > *បារាំងសែស* > *បារាំង*, *ភ្នំដូនពេញ* > *ភ្នំពេញ*,...។<br><br>- <u>ក្នុងភាសាបារាំង</u> :<br>*amir al-bahr* (mot arabe = " prince de |

[28]- ក្នុងការសម្គាល់ព្រំដែនពាក្យ ខ្មែរក៏មានបញ្ហាដែរ ហើយ មានតែលើសពីពាក្យបារាំងទៀតផង។

| | |
|---|---|
| | la mer " ) > frs *amiral*,<br>lat. *ego* > frs *je,*<br>lat. *pro* > frs moyen *por* > frs actuel *pur* ( orth. pour ). |
| **៤៤- ពាក្យគោល/ ពាក្យស្នូល**<br>អ. basic word<br>បារ. lexème de base | ពាក្យទោលដែលប្រើជាបង្អែកសម្រាប់បង្កើតពាក្យកម្លាយឬពាក្យផ្សំ/ពាក្យសមាស។<br>( ១ )- ឧទាហរណ៍សម្រាប់ពាក្យកម្លាយ :<br>ដូចមានក្នុងការពន្យល់អំពី *ពាក្យឫស* ។<br>( ២ )-ឧទាហរណ៍សម្រាប់ពាក្យផ្សំ/ពាក្យសមាស :<br>- ក្នុងភាសាខ្មែរ :<br>• ប្រមាត់ + ដី > ប្រមាត់ដី,<br>• ទឹក + ខ្មៅ > ទឹកខ្មៅ,...។<br>- ក្នុងភាសាបារាំង :<br>• brise + glace > brise-glace,<br>• porte + feuille > portefeuille,... |
| **៤៥- ពាក្យទោល/ អមិស្សសព្ទ**<br>អ. irreducible word<br>បារ. mot irré-ductible | ពាក្យតូចបំផុត (ឯកព្យាង្គឬពហុព្យាង្គ) ដែលនៅមានន័យ (បើគេបំបែកតទៅទៀត ន័យត្រូវបាត់បង់) គឺជាវចនតាដែលមិនមែនជាឫស,<br>ឧទាហរណ៍ :<br>- ក្នុងភាសាបារាំង : jardin, crayon, chaise, ...<br>- ក្នុងភាសាខ្មែរ : គាប, បារី, ក្រហម,...។ |
| **៤៦- ពាក្យសមាស/ ពាក្យផ្សំ** | ពាក្យដែលកើតឡើងពីការផ្សំចូលគ្នារវាងពាក្យនិងពាក្យ ចាប់ពីពីរពាក្យឡើងទៅ ហើយ សម្គាល់ |

| | |
|---|---|
| អ. compound word<br>បារ. mot composé | ន័យឬបញ្ញត្តិមួយច្បាស់លាស់។ ពាក្យផ្សំ/ពាក្យសមាសជាកន្សោមស្អិតដែលមានតម្លៃដូចពាក្យទោលមួយដែរ( ពាក្យទោលឯកព្យាង្គឬពាក្យទោលពហុព្យាង្គ ), ឧទាហរណ៍ :<br>- ក្នុងភាសាខ្មែរ ៖ ជីស, ទឹកខ្មៅ,...។<br>- ក្នុងភាសាបារាំង ៖ porte-monnaie, portefeuille, bon sens, pomme de terre, ...។ |
| **៤៧- ពាក្យសម្រាល/ ប្រិយសព្ទ**<br>អ. euphemism<br>បារ. euphémisme ( m. ) | ការប្រើពាក្យឬឈ្មោះដែលមានន័យមិនទ្រគោះដើម្បីជំនួសពាក្យឬឈ្មោះដែលមានន័យទ្រគោះ, ឧទាហរណ៍ :<br>- <u>ភាសាបារាំង</u> :<br>Pierre n'est pas très courageux ជាពាក្យសម្រាល (ដែលមានន័យមិនទ្រគោះ) សម្រាប់ជំនួស Pierre est un lâche ( ឈ្មោះដែលមានន័យទ្រគោះ ចំពោះ Pierre )។<br>- <u>ភាសាខ្មែរ</u> :<br>*មិនប្រក្រតី* ជាពាក្យសម្រាលជំនួសវិញ្ញត្តិដែលមានន័យទ្រគោះមួយចំនួនធំ,<br>*ស្រីមេអំបៅ/ស្រីប្រកបរបរផ្លូវភេទ/ស្រីរកស៊ីផ្លូវភេទ* ជំនួស ស្រីពេស្យា,...។ |

| | |
|---|---|
| **៤៨- ពាក្យឫស**<br>អ. root word<br>បារ. mot (m.)<br>racine | ពាក្យទោលដែលអាចទទួលវិធីកម្លាយ,<br>ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>ពាក្យឫស ដឹង + បុព្វបទ/ផ្នត់ដើម [ប៉- ]<br>> ប្ដឹង,<br>ពាក្យឫស គាប + អន្តបទ/ផ្នត់ដែក [-ន-]<br>> ឃ្នាប។<br>- <u>ក្នុងភាសាបារាំង</u> :<br>ពាក្យឫស jardin + បច្ឆិមបទ/ផ្នត់ចុង -ier<br>> jardinier,<br>ពាក្យឫស poli + បុព្វបទ/ផ្នត់ដើម im-<br>> impoli. |
| **៤៩- ព្យញ្ជនៈ**<br>អ. consonant<br>បារ. consonne<br>(f.) | សូរដែលបន្លឺឡើងដោយមានទំនប់តិចឬច្រើន អាស្រ័យទៅតាមរង្វះខ្យល់ដែលចេញពីសួត។<br>នៅពេលដែលខ្យល់ចេញពីសួតទៅប៉ះនឹងទំនប់រង្វះខ្យល់កម្រិតសូន្យ វាបង្កើតបានជាព្យញ្ជនៈស្ទះឬផ្ទុះ ដូចជា [p], [b], [t], [d], [k], [g], [m], [n],...។<br>កាលណារង្វះខ្យល់មានកម្រិតលើសពីសូន្យ វាបង្កើតបានជាព្យញ្ជនៈស្ទះត្រដុស ដូចជា [tʃ], [dʒ],...។<br>សូរព្យញ្ជនៈមិនអាចបន្លឺបានច្បាស់ទេ បើសិនជាគ្មានសូរស្រៈនៅអាស្រ័យជាមួយ។ |

| | |
|---|---|
| **៥០- មហាសព្ទ**<br>អ. superordinate<br>បារ. hyperonyme<br>(m.) | ពាក្យដែលមានន័យគ្របដណ្តប់លើពាក្យផ្សេងទៀតដែលជាអនុសព្ទ , ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>ពាក្យ *សត្វ* ជាមហាសព្ទ ព្រោះវាមានន័យគ្របដណ្តប់លើពាក្យ *ឆ្មា ឆ្កែ សេះ ខ្លា មាន់* ,... ។ ពាក្យ *ឆ្មា ឆ្កែ សេះ ខ្លា មាន់* ជាអនុសព្ទ។<br>ពាក្យ *រុក្ខជាតិ* ជាមហាសព្ទ ព្រោះវាមានន័យគ្របដណ្តប់លើពាក្យ *ស្វាយ ដូង ខ្នុរ ចេក*,...។ ពាក្យ *ស្វាយ ដូង ខ្នុរ ចេក* ជាអនុសព្ទ។<br>- <u>ក្នុងភាសាបារាំង</u> :<br>ពាក្យ *rouge* ជាមហាសព្ទ ឯពាក្យ *écarlate , cramoisi , vermillon, pourpre* ជាអនុសព្ទ។ |
| **៥១- មូលតា**<br>អ. morpheme<br>បារ. monème<br>(m.) | មូលតា ជាការបកប្រែពាក្យ "monème" ដែលលោក André Martinet បានកំណត់ន័យថា ជាឯកតាអប្បបរមាដែលមានន័យ[29] ដូច :<br>- <u>ក្នុងភាសាបារាំង</u> :<br>voilà ton père មានមូលតាចំនួនបី : voilà, ton, père,<br>embarquons មានមូលតាចំនួនបី : em- , -barqu-, -ons ។ |

[29]- André Martinet, Eléments de Linguistique générale, Armand Colin 1970, p.103 និង Georges Mounin, Clefs pour la Linguistique, Seghers 1971, p. 54។

| | |
|---|---|
| | - ក្នុងភាសាខ្មែរ :<br>ពាក្យ *ឆ្នាំ* មានមូលតាចំនួនពីរ : ចាំ និង អន្តែបទ/ផ្នត់ដែក [-ម-]។<br><br>ពាក្យ *ឃ្នាប* មានមូលតាចំនួនពីរ : គាប និង អន្តែបទ/ផ្នត់ដែក [-ន-]។<br><br>មូលតាអាចជា វចនតា ( lexème ) ឬ រូបតា ( morphème )។ |
| **៥២- រង្វះខ្យល់/ រង្វះបន្លឺ**<br>អ. aperture<br>បារ. aperture<br>( f. ) | រង្វះខ្យល់ដែលបិទ ឬ បើកចំហតូចឬធំ ក្នុងការបង្កើតសូរ។ គេចែករង្វះខ្យល់ជា៩កម្រិត គឺ :<br><br>( ១ )- រង្វះខ្យល់កម្រិតសូន្យ : ដំណើរខ្យល់ដែលចេញពីសួតត្រូវប៉ះខ្លាំងនឹងគ្រឿងប្រដាប់បន្លឺសំ-ឡេង បណ្តាលឱ្យមានបន្ទុះ, ដូច្នេះសូរដែលកើតឡើង ជាសូរផ្ទុះ/សូរស្ទះ គឺសូរ [p], [b], [t], [d], [k], [g], [m], [n], [ɲ], [ŋ], ...។<br><br>( ២ )- រង្វះខ្យល់កម្រិតកន្លះ : ដំណើរខ្យល់ត្រ-ដុសខ្លាំងនឹងផ្ទៃនៃគុហាមាត់, អណ្តាត, ធ្មេញ ( ត្រដុសខ្លាំងព្រោះរង្វះខ្យល់មានកម្រិតស្មើរសូន្យ ) ហើយ បង្កើតសូរផ្ទុះត្រដុស / ស្ទះត្រដុស ដូចជា [tʃ], [dʒ], ...។ |

| | |
|---|---|
| | (៣)- វង្វះខ្យល់កម្រិត១ : ដំណើរខ្យល់ត្រដុសនឹងផ្ទៃនៃគុហាមាត់, អណ្ដាត, ធ្មេញ ហើយ បង្កើតសូរត្រដុស ដូចជា [f], [v], [s], [z], ...។<br><br>(៤)- វង្វះខ្យល់កម្រិត២ : ដំណើរខ្យល់ស្ទើរតែមិនត្រដុសនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ទ្បើយ ហាក់បីដូចជាមានលំហូរ ហើយ បង្កើតសូរលំហូរ ដូចជា [l], [r], ...។<br><br>(៥)- វង្វះខ្យល់កម្រិត៣ : ចាប់ពីវង្វះនេះទៅ ដំណើរខ្យល់ឈប់ប៉ះនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ទៀតហើយ ហើយ គេបានសូរស្រៈកន្លះ ឬ ព្យញ្ជនៈកន្លះ គឺ [j], [w],...។<br><br>(៦)- វង្វះខ្យល់កម្រិត៤ : សូរដែលកើតទ្បើងគឺ សូរស្រៈបិទ ដូចជា [i], [y], [u],...។<br><br>(៧)- វង្វះខ្យល់កម្រិត៥ : សូរដែលកើតទ្បើងគឺ សូរស្រៈបិទកន្លះ ដូចជា [e], [ø], [ɘ], [o],...។<br><br>(៨)- វង្វះខ្យល់កម្រិត៦ : សូរដែលកើតទ្បើងគឺ សូរស្រៈបើកកន្លះ ដូចជា [ɛ], [œ], [ɔ], ...។<br><br>(៩)- វង្វះខ្យល់កម្រិត៧ : សូរដែលកើតទ្បើងគឺ សូរស្រៈបើក ដូចជា [a], [ɑ], ...។ |

| | |
|---|---|
| ៥៣- **ឫស**<br>អ. root<br>បារ. racine ( f. ) | វចនតាមួយបែបដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសា ដែលជាធាតុរួមនៃពាក្យមួយចំនួនក្នុងសន្តានជាមួយគ្នា។<br>តាមវចនានុក្រមភាសាវិទ្យារបស់លោក Jean Dubois & alii (Larousse), racine (ឫស) អាចមាន radical ច្រើន, ឧទាហរណ៍ ៖ ក្នុងភាសាបារាំង ឫស [vən] (មក) មាន radical ពីរ ៖ [vən-] (ven-) ដូចមានក្នុងពាក្យ [vənir] (venir), [vənɔ̃] (venons), ... និង [vjɛn-] (vienne) ដូចមានក្នុងពាក្យ [vjɛn] (vienne/ viennent), ...។<br>ការពន្យល់អំពី *ឫស* បានបង្ហាញឱ្យឃើញថា racine ខ្លះ អាចមាន radical ច្រើន ហើយ យើងបានប្រែពាក្យ *racine* ថា *ឫស* ។ ដោយផ្អែកលើប្រព័ន្ធ សូរ-កាឡាសូរ, រូបតា-កាឡារូប យើងអាចប្រែ radical ដែលជារូបផ្សេងៗនៃ racine ថា កាឡាឫស ។ |
| **៥៤- រូបតា**<br>អ. grammatical morpheme<br>បារ. morphème ( m. ) | មូលតាមួយបែបដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសា (លោក អៀវ កើស ហៅថា "កន្ទេចពាក្យ "[30]) សម្រាប់ភ្ជាប់ជាមួយពាក្យឫស ឬ ជាមួយឫស ដើម្បី : |

[30]- អៀវ កើស : ភាសាខ្មែរ , បណ្ណាគារ មិត្តសេរី , ភ្នំពេញ ១៩៦៧ , ទំព័រ ១៦៨។

| | |
|---|---|
| | - បង្កើតពាក្យ, ឧទាហរណ៍ :<br>•• ក្នុងភាសាខ្មែរ :<br>• ពាក្យឫស *ជួញ + [-ម-] > ឈ្មួញ* ,<br>• ពាក្យឫស *គាប + [-ន-] > ឃ្នាប* ,...។<br>•• ក្នុងភាសាបារាំង :<br>• ពាក្យឫស *jardin + ier > jardinier,*<br>• ឫស *all + er > aller,...*<br>- បំបែកពាក្យ, ឧទាហរណ៍ :<br>•• ក្នុងភាសាបារាំង :<br>• ឫស *all + ons > allons* ( បុ.១, ពហុ. ),<br>• ឫស *all + ez > allez* ( បុ.២, ពហុ. ),...<br>•• ក្នុងភាសាឡាតាំង :<br>• *rosă* ( nominatif, sg ),<br>• *rosăm* ( accusatif, sg ), ...។<br>•• ក្នុងភាសាបាលី :<br>• *បុរិសោ* ( បឋមាវិភត្តិ, ឯក. ),<br>• *បុរិសំ* ( ទុតិយាវិភត្តិ, ឯក. ) ,...។ |
| **៩៥- រូបសាស្ត្រ**<br>អ. morphology<br>បារ. morphologie ( f. ) | ទម្រង់របស់ពាក្យ ហើយ ដោយភាសាជាសូរ ទម្រង់នេះជាសូរដែលស្ដាប់ឮ ប៉ុន្ដែវាក៏អាចជារូបដែលគេមើលឃើញតាមរយៈសំណេរផងដែរ។<br>ក្នុងពាក្យកម្លាយឬពាក្យសមាស គេអាចវិភាគរូបសាស្ត្រជាចំណែកៗ, ឧទាហរណ៍ : |

| | |
|---|---|
| | - បញ្ចូល < [ ប់ញ-] + ចូល<br>- ពលកម្ម < ពល + កម្ម |
| **៥៦-ល្បះ/ប្រយោគ**<br>អ. sentence<br>បារ. phrase ( f. ) | ល្បះ/ប្រយោគជាបង្កុំពាក្យដែលមានន័យសេចក្តីពេញលេញ ស្តាប់បាន។ ល្បះ/ប្រយោគត្រូវមានកន្សោមនាមប្រធាន និង កន្សោមកិរិយា (ប្រណាប់ប្រធាន/បម្រាប់ប្រធាន ),ឧទាហរណ៍ :<br>- សិស្សានុសិស្សទៅសាលារៀន។<br>- គាត់បានជួបមិត្តសម្លាញ់របស់គាត់នៅក្នុងសុបិន។<br>ល្បះ/ប្រយោគមានច្រើនប្រភេទ គឺ :<br>- ល្បះប្រកាស/ប្រយោគប្រកាស( ល្បះបញ្ជាក់ ) ( phrase déclarative )<br>- ល្បះសំណួរ/ប្រយោគសំណួរ ( phrase interrogative )<br>- ល្បះបញ្ជា/ប្រយោគបញ្ជា ( phrase impérative )<br>- ល្បះឧទាន/ប្រយោគឧទាន ( phrase exclamative )។<br><br>១-ល្បះប្រកាស/ប្រយោគប្រកាស : ល្បះ/ប្រយោគដែលគេប្រើសម្រាប់អះអាងឱ្យដឹងរឿងអ្វីមួយ, |

| | |
|---|---|
| | ឧទាហរណ៍ :<br>- លោកគ្រូមកដល់ហើយ។<br>- លោកនាយកមិននៅទេ។<br><br>២- ល្បះសំណួរ/ប្រយោគសំណួរ : ល្បះ/ប្រយោគដែលគេប្រើសម្រាប់សួរចង់ដឹងអំពីអ្វីមួយ ដោយប្រើពាក្យសួរ (តើ..., ...ឬ, ...ឬទេ,...)ឬ លើកសំឡេងនៅខាងចុងល្បះ, ឧទាហរណ៍ :<br>- (ឯង)យល់ព្រមឬទេ?<br>- ថ្ងៃនេះ វាមិនទៅរៀនទេ (ឬ)?<br><br>៣- ល្បះបញ្ជា/ប្រយោគបញ្ជា : ល្បះដែលគេប្រើសម្រាប់បង្គាប់បញ្ជា ផ្ដល់ដំបូន្មាន ឬ ហាមប្រាម, ឧទាហរណ៍ :<br>- ចូរ(អ្នក)រៀបចំបន្ទប់ឱ្យបានស្អាត។<br>- (អ្នកទាំងអស់គ្នា)ត្រូវខិតខំរៀនសូត្រ។<br>- ហាមខាកស្ដោះ។<br>- កុំជក់បារី។<br><br>៤- ល្បះឧទាន/ប្រយោគឧទាន : ល្បះដែលគេប្រើសម្រាប់សំដែងអំណរ ការរំជួលចិត្ត កំហឹង ការកោតសរសើរ ការងឿងឆ្ងល់ ការភ្ញាក់ផ្អើល... ដែលកើតឡើងភ្លាមៗ, ឧទាហរណ៍ :<br>- ឃី! អស្ចារ្យណាស់! |

| | |
|---|---|
| | - វេងាណាស់!<br>- នាងឆ្លាតមែន! |
| **៥៧- ល្បះក្រង/ ប្រយោគក្រង**<br>អ. juxtapose sentence<br>បារ. phrase juxtaposée | ល្បះ/ប្រយោគដែលកើតឡើងពីល្បះ/ប្រយោគទោលច្រើននៅបន្តបន្ទាប់គ្នា ឬ ភ្ជាប់គ្នាដោយឃ្នាប់ចង, ឧទាហរណ៍ :<br>មាន់រងាវ សេះកញ្ជ្រៀវ គោរោទិ៍ ...។ |
| **៥៨- ល្បះទោល/ ប្រយោគទោល**<br>អ. simple sentence<br>បារ. phrase( f. ) simple | ល្បះ/ប្រយោគដែលមានតែមួយអនុប្រយោគ, ឧទាហរណ៍ :<br>- លោកគ្រូមកដល់ហើយ។<br>- លោកនាយកមិននៅទេ។<br>- ឯងទៅណា ?<br>- កុំដក់បារី។ |
| **៥៩- ល្បះបដិសេធ/ ប្រយោគបដិសេធន៍**<br>អ. negative sentence<br>បារ. phrase négative | ល្បះ/ប្រយោគដែលក្នុងនោះគេប្រើអវិជ្ជមានបទ (មិន....ទេ/ឡើយ, អត់....ទេ / ឡើយ,...) ដើម្បីសំដែងគំនិតអវិជ្ជមាន, ឧទាហរណ៍ :<br>- លោកនាយកមិននៅទេ។<br>- វាអត់ទៅសាលាទេ។ |
| **៦០- ល្បះល្បាយ/ ប្រយោគល្បាយ ឬ ល្បះផ្សំ/ប្រយោគផ្សំ**<br>អ. complex | ល្បះ/ប្រយោគដែលកើតឡើងដោយសារការផ្សំរវាងឃ្លានិងឃ្លា ដែលក្នុងនោះ មានឃ្លាគោលនិងឃ្លារណប។ " ឃ្លារណបភ្ជាប់នឹងឃ្លាគោលដោយសារឃ្នាប់ឃ្លា ", ឧទាហរណ៍ : |

| | |
|---|---|
| sentence<br>បារ. phrase complexe/phrase composée | - គាត់ខានមកធ្វើការអស់បីថ្ងៃ ពីព្រោះគាត់ឈឺ។<br>- បើគាត់ត្រឡប់មកវិញ គាត់នឹងបង្ហើយកិច្ចការនេះ។ |
| **៦១- ល្បះសង្កត់ន័យ/ប្រយោគសង្កត់ន័យ**<br>អ. emphazised sentence<br>បារ. phrase emphatique | ល្បះ/ប្រយោគដែលក្នុងនោះគេផ្តោតអារម្មណ៍លើជាតុណាមួយ (ប្រធាន, កម្មបទ, កម្មទេសកាល) នៃល្បះ/ប្រយោគ, ឧទាហរណ៍ :<br>- គឺសិស្សនេះហើយ ដែលចូលចិត្តអានសៀវភៅជាងគេ។ (ផ្តោតលើប្រធាន)<br>- មនុស្សនេះ ខ្ញុំស្អប់វាណាស់ ។ (ផ្តោតលើកម្មបទ)<br>- គឺទីនេះហើយ ដែលខ្ញុំធ្លាប់រស់នៅ កាលពីក្មេង។ (ផ្តោតលើកម្មទេសកាល) |
| **៦២- វចនតា**<br>អ. lexical morpheme<br>បារ. lexème[31] (m.) | មូលតាមួយបែបដែលជាពាក្យទោល ឬ ជាឫស/ជាធាតុនៃពាក្យក្នុងភាសាឥណ្ឌូអឺរ៉ុប, ឧទាហរណ៍ :<br>- វចនតាជាពាក្យទោល, ឧ. គាប, ធំ, កូន, crayon, jardin, chaise,...<br>- វចនតាជាឫស ក្នុងភាសាបារាំង, ឧ. all (ទៅ) ក្នុងពាក្យ aller,...។<br>- វចនតាជាធាតុ ក្នុងភាសាបាលី, ឧ. ទា (ឱ្យ) ក្នុងពាក្យ ទេតិ, ទាន, ...។ |

31- André Martinet, Ibid, p.119.

| | |
|---|---|
| | កាលណាគេយកពាក្យទោលទៅធ្វើមូលដ្ឋានក្នុងការបង្កើតពាក្យ ពាក្យទោលនោះត្រូវគេហៅថា ពាក្យឫស។ |
| **៦៣- វចនលេខន៍**<br>អ. lexicography<br>បារ. lexicographie (f.) | ការសរសេរ និង ការរៀបរៀង ចងក្រង វចនានុក្រម ដោយផ្អែកលើចំណេះដឹងខាងវចនវិទ្យា។ |
| **៦៤- វចនវិទ្យា**<br>អ. lexicology<br>បារ. lexicologie (f.) | ផ្នែកមួយនៃភាសាវិទ្យាដែលសិក្សាអំពីវាក្យសព្ទ ក្នុងនោះមាន ការបង្កើតពាក្យ, ការប្រើពាក្យ ជាដើម, ឧទាហរណ៍ :<br>- គាប + [-ន-] > ឃ្នាប,<br>- ប្រមោយ + ដំរី > ប្រមោយដំរី,...។ |
| **៦៥- វាចកៈ**<br>អ. voice<br>បារ. voix (f.) | ពាក្យប្រាប់នាទីឬដំណើររបស់កិរិយាសព្ទក្នុងសម្ព័ន្ធ។ វាចកៈមានពីរបែប គឺ :<br>- កត្តុវាចកៈ (voix active) គឺ ប្រធាននៃល្បះធ្វើអំពើ។<br>- កម្មវាចកៈ (voix passive) គឺ ប្រធាននៃល្បះរងអំពើ ហើយ កម្មបទ (C. d'objt) ជាអ្នកធ្វើអំពើ ហៅថា កម្មភ្នាក់ងារ។<br><br>ឧទាហរណ៍ក្នុងភាសាអង់គ្លេស :<br>- John <u>kills</u> the dog. (កត្តុវាចកៈ)<br>- The dog <u>is killed by</u> John. (កម្មវាចកៈ) |

| | |
|---|---|
| | ឧទាហរណ៍ក្នុងភាសាខ្មែរ :<br>- លោក នូ ហាច **<u>និពន្ធ</u>** រឿងផ្កាស្រពោន។ (កត្តុវាចកៈ)<br>- រឿងផ្កាស្រពោន (<u>ត្រូវបាន</u>)<u>**និពន្ធ** ដោយ</u> លោក នូ ហាច។ (កម្មវាចកៈ) |
| **៦៦- វាចាវិលាស**<br>អ. locution<br>បារ. locution<br>(f.) | កន្សោមពាក្យផ្សារជាប់ (ដូចពាក្យសមាសដែរ) ប៉ុន្តែ វេយ្យាករណ៍បុរាណបារាំង ប្រើសម្រាប់កន្សោមផ្សារជាប់ដែលសម្គាល់ប្រភេទពាក្យ, ឧទាហរណ៍ :<br>- <u>locutions verbales</u> :<br>prendre parole = parler,<br>mettre le feu = allumer.<br>- <u>locutions adverbiales</u> :<br>de manière lente = lentement,<br>avec rapidité = rapidement.<br>- <u>locutions prépositionnelles</u> :<br>à l'aide de = avec,<br>en dépit de = malgré , ...<br>យើងអាចនិយាយបានថា ភាសាខ្មែរក៏មានវាចា-វិលាសដែរ, ឧទាហរណ៍ :<br>- <u>វាចាវិលាសកិរិយា</u> :<br>ជ្រុលមាត់ = ជ្រុលសម្តី (និយាយខុស ហើយ |

| | |
|---|---|
| | ស្តាយក្រោយ),<br>ចូលចិត្ត = ពេញចិត្ត , ស្រឡាញ់, និយម,...<br>- <u>វាចាវិលាសកិរិយាវិសេសន៍</u> :<br>ដោយយកចិត្តទុកដាក់,យ៉ាងលឿន, ...។<br>(ប្រភព ៖ តឹប យក់ ថាវ គន្ធ ៖ វចនានុក្រម បារាំង-ខ្មែរ សង្ខេប, អាគារបោះផ្សាយវប្បធម៌, ឆ្នាំ១៩៨៩, ទំព័រ ៧៤៥។ ) |
| **៦៧- វិធីកម្លាយ**<br>អ. derivation<br>បារ. dérivation (f.) | វិធីមួយនៃការបង្កើតពាក្យចេញពីពាក្យឫស/ឫស តាមរយៈផ្នត់/អព្ភាសបទ, ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>[ប់ង-] + កប់ > បង្កប់,<br>ជួញ + [-ម-] > ឈ្មួញ,...<br>- <u>ក្នុងភាសាបារាំង</u> :<br>im- + poli > impoli,<br>jardin + -ier > jardinier,<br>all + -er > aller ; |
| **៦៨- វិភត្តិ**<br>អ. inflection<br>បារ. flexion (f.) | "ចំណែកប្រាប់ដំណើរបំបែកពាក្យ (នាមសព្ទ, កិរិ-យាសព្ទ,គុណនាម,..) ដើម្បីសម្គាល់មុខងារផ្សេងៗ ក្នុងវេយ្យាករណ៍នៃតន្តិភាសា មានភាសាសំស្ក្រឹត, បាលី, ឡាតាំង ជាដើម។ |
| **៦៩- វេវចនសព្ទ**<br>អ. synonym<br>បារ. synonyme (m.) | ពាក្យពីរម៉ាត់ឬវាចាវិលាស (locution) ពីរម៉ាត់ ឬក៏ ច្រើនម៉ាត់ ជាវេវចនសព្ទនឹងគ្នា កាលណាពាក្យឬវាចាវិលាសនោះមានប្រភេទដូចគ្នានិងអាច ជំនួសគ្នាបានក្នុងល្បះ ដោយឥតបណ្តាលឱ្យល្បះ |

| | |
|---|---|
| | មានន័យផ្សេង, ឧទាហរណ៍ :<br>- គាត់បាន<u>**លាចាកលោក**</u>ច្រើនឆ្នាំហើយ។<br>- គាត់បាន<u>**ទទួលមរណភាព**</u>ច្រើនឆ្នាំហើយ។<br>តាមធម្មតា ពាក្យពីរម៉ាត់ដែលជាវេវចនសព្ទនឹងគ្នា មិនមានន័យដូចគ្នាបេះបិទទេ :<br>គេមិនអាចប្រើវាជំនួសគ្នាបានគ្រប់ករណីទេ ឬ វាជំនួសគ្នាបាន ប៉ុន្តែសណ្ឋានភាសា (registres) មានកម្រិតខុសគ្នា, ឧទាហរណ៍ :<br><u>ករណីដែលគេមិនអាចជំនួសវេវចនសព្ទជាទូទៅបាន</u> :<br>- <u>ភាសាបារាំង</u> :<br>- Le bec aigu = Le bec pointu<br>(aigu = pointu)<br>- Le son aigu គ្មាន * le son pointu ជាវេវចនសព្ទទេ (aigu ≠ pointu)<br>- <u>ភាសាខ្មែរ</u> :<br>- ធ្វើការលឿន = ធ្វើការរហ័ស,<br>- រត់លឿន ≠ * រត់រហ័ស។<br><u>ករណីដែលវេវចនសព្ទមានសណ្ឋានភាសាខុសគ្នា</u> :<br>- *ប្តី* (សណ្ឋានភាសាធម្មតា), *ស្វាមី* (សណ្ឋានភាសាខ្ពស់)<br>- *ស៊ី* (សណ្ឋានភាសាទាប), *ហូប* (សណ្ឋាន |

| | |
|---|---|
| | ភាសាធម្មតា), *ពិសា* (សណ្ឋានភាសាខ្ពស់), ...។ |
| **៧០- សញ្ញាតាបន្លឺ**<br>អ. feature of articulation<br>បារ. trait articu-latoire (m.) | លក្ខណៈបន្លឺរបស់សទ្ទតា (ស្រៈ ព្យញ្ជនៈ)ដែលផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួន ដូចតទៅ ៖<br>-ផ្លូវខ្យល់<br>-រង្វះខ្យល់/រង្វះបន្លឺ<br>-ទីបន្លឺ<br>-មាន/គ្មានលំញ័រខ្សែសំឡេង(សម្រាប់ព្យញ្ជនៈ)<br>- ...<br>ឧទាហរណ៍ ៖<br>សញ្ញាតាបន្លឺរបស់ព្យញ្ជនៈ [d] គឺ<br>- សូរមាត់/មុខជៈ<br>- សូរស្ទះ/ផ្ទុះ<br>- សូរធ្មេញ/ទន្តជៈ<br>- ឃោសៈ/ឮ<br>សញ្ញាតាបន្លឺរបស់ស្រៈ [i] គឺ<br>- ស្រៈសូរមាត់<br>- ស្រៈបិទ<br>- ស្រៈមុខ<br>- ស្រៈបប្ញូរមាត់វែង។ |
| **៧១- សទ្ទតា**<br>អ. phoneme<br>បារ. phonème (m.) | ឯកតាសូរតូចបំផុតរបស់ភាសា ដែលមិនអាចបំបែកបាន គ្មានន័យក្នុងខ្សែសម្ដី និង មានមុខងារសម្រាប់ធ្វើឱ្យពាក្យពីរក្នុងបរិបទតែមួយ មានន័យប្លែកគ្នា។ |

| | |
|---|---|
| **៧២- សម្ព័ន្ធវិទ្យា**<br>អ. syntax<br>បារ. syntaxe ( f. ) | ផ្នែកមួយនៃវេយ្យាករណ៍ ដែលក្នុងនោះ សទ្ទតា-វិទ្យានិង វចនវិទ្យា ជាផ្នែកពីរទៀត។<br>សម្ព័ន្ធវិទ្យាសិក្សាអំពីវិធីចងក្រងពាក្យឱ្យទៅជាល្បះ ដែលក្នុងនោះប្រភេទពាក្យឥតមានលំដាប់ដូចគ្នាទេ ពីភាសាមួយ ទៅភាសាមួយ :<br>- ប្រភេទពាក្យនិងមុខងារវាក្នុងល្បះខ្មែរ មានលំ-ដាប់ប្រហាក់ប្រហែលនឹងលំដាប់ក្នុងល្បះនៃភាសាមួយចំនួន មាន បារាំង ឬ អង់គ្លេស ជាដើម,<br>ឧទាហរណ៍ :<br>ល្បះខ្មែរ : គាត់ស្រឡាញ់កញ្ញាបុប្ផា,<br>ល្បះបារាំង : Il aime Mademoiselle Bopha .<br>- ប្រភេទពាក្យនិងមុខងារវាក្នុងល្បះនៃភាសាម៉ាល់ហ្គាស (នៅក្នុងក្រុមភាសាឥណ្ឌូណេស៊ី) មានលំដាប់ដូចខាងក្រោម :<br>Miteny anglisy aho.<br>parle anglais je.<br>- ចំពោះភាសាមួយចំនួនទៀត ប្រភេទពាក្យមានលំដាប់និងមុខងារក្នុងល្បះផ្សេងៗគ្នា (ភាសាបាស្គ (basque) ប្លែកពីភាសាខ្លះទៀត, ... )។<br>បើគេពិនិត្យមើលសម្ព័ន្ធពីភាសាមួយទៅភាសាមួយ គឺគេសិក្សាអំពីសម្ព័ន្ធវិទ្យាទូទៅ។ បើគេសិក្សាអំពីសម្ព័ន្ធវិទ្យារបស់ភាសាណាមួយ សម្ព័ន្ធវិទ្យា |

| | |
|---|---|
| | មានឈ្មោះថា សម្ព័ន្ធវិទ្យានៃភាសានោះឯង។ ដោយសម្ព័ន្ធវិទ្យាសិក្សាអំពីឈ្លះនិងដោយឈ្លះមានច្រើនប្រភេទ ដូច្នេះ សម្ព័ន្ធវិទ្យាត្រូវសិក្សាអំពីប្រភេទឈ្លះអំពីវាចកៈ។ល។ |
| **៧៣- សព្វនាម**<br>អ. pronoun<br>បារ. pronom<br>( m. ) | ពាក្យដែលគេប្រើសម្រាប់ជំនួស នាម កន្សោម-នាម និង ឈ្លះ ដើម្បីចៀសការប្រើពាក្យច្រំដែល។ ក្នុងសម្ព័ន្ធ សព្វនាមបំពេញមុខងារដូចនាម និងកន្សោមនាមដែរ : សព្វនាមអាចជាប្រធានក្នុងឈ្លះ, អាចជាកម្មក្នុងឈ្លះ, ឧទាហរណ៍ :<br>- *<u>គាត់</u>ភ្ជួរស្រែ*, **គាត់** មានមុខងារជាប្រធាន,<br>- *អ្នកស្រុកស្គាល់<u>វា</u>ច្បាស់ណាស់*, **វា** មានមុខងារជាកម្មបទផ្ទាល់ ( កម្មបទផ្ទាល់ = complément d´objet direct )។<br>-*ពូសុខតែងតែខឹងប្រឡោត បើគាត់មិនខំកែខ្លួនទេ <u>វា</u>នឹងនាំមកដល់គាត់នូវសត្រូវជុំទិស។*<br><br>នៅក្នុងភាសាខ្មែរ គេចែកសព្វនាម ជា : សព្វ-នាមបុរិសៈ, សព្វនាមឈ្នាប់, សព្វនាមចង្អុល, សព្វនាមសំណួរ, សព្វនាមមិនច្បាស់។ |
| **៧៤- សព្វនាម ចង្អុល**<br>អ. demonstrative pronoun | សព្វនាមដែលប្រើសម្រាប់ចង្អុលបង្ហាញមនុស្ស សត្វ ឬ វត្ថុ ឱ្យឃើញច្បាស់លាស់ថា នៅទីជិត ឬ ទីឆ្ងាយពីអ្នកនិយាយ។ ពាក្យ *នេះ នោះ ,...* ជាសព្វនាមចង្អុល, ឧទាហរណ៍ : |

| | |
|---|---|
| បារ. pronom démonstratif | *<u>នេះ</u>ជាសៀវភៅរបស់ខ្ញុំ <u>នោះ</u>ជាសៀវភៅរបស់ឯង។* |
| **៧៥- សព្វនាមឈ្នាប់**<br>អ. relative pronoun<br>បារ. pronom relatif | សព្វនាមសម្រាប់ជំនួសនាមឬកន្សោមនាមដើម្បីបង្កើតឈ្នះរណប។<br>នៅក្នុងភាសាខ្មែរ សព្វនាមឈ្នាប់មានតែមួយ គឺ *ដែល* , ឧទាហរណ៍ :<br>- *ខ្ញុំបានជួបកុមារម្នាក់**<u>ដែល</u>**រៀនពូកែជាងគេក្នុងសាលារៀននេះ។*<br>- *តុ**<u>ដែល</u>**គេដាក់ថូផ្កានៅលើនោះ ជារបស់គាត់។* |
| **៧៦- សព្វនាមបុរិសៈ**<br>អ. personal pronoun<br>បារ. pronom personnel | សព្វនាមដែលតំណាងបុរិសទាំងបី។<br>ក្នុងភាសាខ្មែរ សព្វនាមបុរិសៈមាន :<br>- បុរិសៈទី១ ៖ *ខ្ញុំ អញ យើង ...*។<br>- បុរិសៈទី២ ៖ *ឯង អ្នក ...*។<br>- បុរិសៈទី៣ ៖ *វា គាត់ នាង ...*។ |
| **៧៧- សព្វនាមមិនច្បាស់**<br>អ. indefinite pronoun<br>បារ. pronom indéfini | សព្វនាមដែលគេប្រើជំនួសនាមឬកន្សោមនាមដែលស្ថិតក្នុងលក្ខណៈទូទៅ ដោយមិនបញ្ជាក់ច្បាស់ចំពោះនាមឬកន្សោមនាមណាមួយឡើយ។ ពាក្យ *នរណាម្នាក់ អ្នករាល់គ្នា នរណាមួយ* ... ជាសព្វនាមមិនច្បាស់, ឧទាហរណ៍ :<br>- *<u>អ្នករាល់គ្នា</u>ត្រូវទៅឡើងឡាននៅម៉ោង៦ព្រឹក។*<br>- *<u>នរណាម្នាក់</u>ស្ម័គ្រចិត្តចូលរួមសន្និសីទអាស៊ាន។* |

| | |
|---|---|
| **៧៨- សព្វនាមសំណួរ**<br>អ. interrogative pronoun<br>បារ. pronom interrogatif | សព្វនាមប្រើសម្រាប់សួររកប្រធាន ឬ សួររកកម្មបទរបស់កិរិយាសព្ទ។ សព្វនាមសំណួរ មានដូចជា ៖ *នរណា, អ្វី, នរណាមួយ, អ្វីមួយ,* ... ,<br>ឧទាហរណ៍ :<br>- <u>*នរណា*</u>*ដើរកាត់ទីនេះ*? (សួររកប្រធាន)<br>- *ឯងនិយាយអំពី<u>អ្វី</u>*? (សួររកកម្មបទមិនផ្ទាល់; កម្មបទមិនផ្ទាល់ = complément d'objet indirect),<br>- *គាត់ទិញ<u>អ្វី</u>*? (សួររកកម្មបទផ្ទាល់)។ |
| **៧៩- សទិសសព្ទ**<br>អ. homonym<br>បារ. homonyme (m.) | ពាក្យដែលមានន័យផ្សេងគ្នា តែមានរូបដូចគ្នា ឬមានសូរដូចគ្នា។ សទិសសព្ទ អាចចែកជាពីរក្រុមគឺ :<br>- សទិសលេខ (homographe) : ពាក្យដែលមានសំណេរដូចគ្នា ,<br>ឧ. *លិច* (ទិសខាងលិច) និង *លិច* (ថ្ងៃលិច)<br>- សទិសសូរ (homophone) : ពាក្យដែលមានសូរដូចគ្នា,<br>ឧ. *លិច* (ថ្ងៃលិច) និង *លេច* (លេចចេញ , លេចឡើង)<br>*គុន* (គុនដាវ, គុនដំបង) និង *គុណ* (គុណមាតាបិតា , គុណគ្រូ), ...។ |

| | |
|---|---|
| | <u>*កំណត់សម្គាល់*</u> : *សទិសសព្ទ អាចជាសទិសសូរផង អាចជាសទិសលេខផងទៀត។ ឧ. ភ្ញី (ភ្ញីស្រែ) និង ភ្ញី (ជំងឺភ្ញី), ...។* |
| **៨០- សិថិល**<br>អ. unaspirated<br>បារ. non-aspirée (f.) | ព្យញ្ជនៈដែលមិនមានសូរ [h] ផ្សំជាមួយ។ ក្នុងភាសាបាលី សំស្ក្រឹត ព្យញ្ជនៈសិថិលជាព្យញ្ជនៈទី១ និង ទី៣ ក្នុងវគ្គទាំង៥ រួមមាន១០តួ គឺ ក[k], គ[g] , ច[c] ជ[j] , ដ[t], ឌ[d] , ត[t], ទ[d] , ប[p], ព[b]។ |
| **៨១- សូរ**<br>អ. sound<br>បារ. son (m.) | អ្វីដែលត្រចៀកយើងស្តាប់ឮ បន្ទាប់ពីមានការប៉ះគ្នារវាងក្រដាសត្រចៀកនិងវត្ថុភ្ញោច(រលក) ដែលរសាត់តាមអាកាសចេញមកពីគ្រប់ទិសទី [(ដូចរលកលើទឹកដែលរាលធំទៅៗ កាលណាយើងចោលដុំថ្ម ឬ ដុំដី ទៅក្នុងទឹក) ហើយ រលកនោះត្រូវបានកើតចេញពីលំញ័រដែលកើតឡើងពីការប៉ះទង្គិចរវាងកម្លាំងអ្វីមួយ (ការទាញ/ការកូតចាប៉ី/ទ្រ), ការគោះ, ការផ្លុំ, ការជ្រុះ, ការបក់បោក,...) ទៅលើវត្ថុអ្វីមួយ(ខ្សែចាប៉ី/ទ្រ, ស្គរ, ខ្លុយ, កម្រាលឥដ្ឋ, ស្លឹកឈើ,...)]។ |
| **៨២- សូរក្រអូម**<br>អ. palatal<br>បារ. palatale (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅត្រង់ក្រអូម គឺខ្នងអណ្តាតទល់នឹងក្រអូម។<br>ព្យញ្ជនៈសូរក្រអូម មាន ៖ [ c ], [ ɟ ], [ ɲ ],...។ |

| | |
|---|---|
| **៨៣- សួរចន្លោះខ្សែសំឡេង**<br>អ. glottal stop<br>បារ. coup de glotte | សូរព្យញ្ជនៈដែលមានទីបន្លឺនៅចន្លោះខ្សែសំឡេង។ ព្យញ្ជនៈសូរចន្លោះខ្សែសំឡេង មាន : [ʔ], ...។ |
| **៨៤- សូរច្រមុះ / នាសិកជៈ**<br>អ. nasal<br>បារ. nasale (f.) | សូរព្យញ្ជនៈដែលពេលបន្លឺ រនាំងក្រអូមបើកចំហ ដើម្បីឱ្យខ្យល់ក្នុងសួត ចេញមកក្រៅតាមច្រមុះផង តាមមាត់ផង។ ព្យញ្ជនៈសូរច្រមុះ ឬ នាសិកជៈ មាន [m], [n], [ŋ], [ɲ],...។ |
| **៨៥- សូរជើងធ្មេញ/ សូរគន្លាក់ក្រអូម**<br>អ. alveolar<br>បារ. alvéolaire(f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅជើងធ្មេញ គឺចុងអណ្ដាតទល់នឹងជើងធ្មេញមុខ។<br>ព្យញ្ជនៈសូរជើងធ្មេញ មាន ៖ [t̪], [d̪],...។ |
| **៨៦- សូរដើមក** | សូរព្យញ្ជនៈដែលមានទីបន្លឺនៅដើមក។<br>ព្យញ្ជនៈសូរដើមក មាន : [h], ...។ |
| **៨៧- សូរត្រដុស**<br>អ. fricative<br>បារ. fricative (f.) | សូរព្យញ្ជនៈដែលពេលបន្លឺ ខ្យល់ដែលរត់ចេញពីសួត ត្រដុសនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ហើយ បង្កើតសូរត្រដុស ដូចជា ៖ [f], [v], [s], [z], ...។<br>ព្យញ្ជនៈសូរត្រដុសជាព្យញ្ជនៈ ដែលមានរង្វះខ្យល់កម្រិត១។ |

| | |
|---|---|
| **៨៨- សូរធ្មេញ / ទន្តជះ**<br>អ. dental<br>បារ. dentale (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅត្រង់ធ្មេញ គឺចុងអណ្ដាតទល់នឹងធ្មេញ។ ព្យញ្ជនៈសូរធ្មេញមាន : [t], [d], [n], ...។ |
| **៨៩- សូរបបូរមាត់/ ឱស្ឋជះ**<br>អ. labial<br>បារ. labiale (f.) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅបបូរមាត់គឺបបូរមាត់លើនិងបបូរមាត់ក្រោមប៉ះគ្នា។<br>ព្យញ្ជនៈសូរបបូរមាត់ មាន : [p], [b], [m], ...។ |
| **៩០- សូរផ្ទុះ/ សូរស្ទះ**<br>អ. plosive<br>បារ. occlusive (f.) | សូរព្យញ្ជនៈដែលបន្លឺឡើង ដោយមានដំណើរខ្យល់ចេញពីសួតមកប៉ះខ្លាំងនឹងគ្រឿងប្រដាប់បន្លឺសំឡេង បណ្ដាលឱ្យមានបន្ទុះ ដូចជា [p], [b], [t], [d], [k], [g], [m], [n], [ɲ], [ŋ], ជាដើម។ ព្យញ្ជនៈសូរផ្ទុះ ឬ សូរស្ទះ ជាព្យញ្ជនៈដែលមានវង្វះខ្យល់កម្រិតសូន្យ។ |
| **៩១-សូរផ្ទុះត្រដុស/ សូរស្ទះត្រដុស**<br>អ. affricative<br>បារ. affriquée(f.) | សូរព្យញ្ជនៈដែលបន្លឺឡើងដោយមានបន្សំចូលគ្នារវាងសូរផ្ទុះ/សូរស្ទះជាមួយនឹងសូរត្រដុស (fricative) ដូចជា :<br>- ព្យញ្ជនៈ [tʃ] ក្នុងពាក្យ [tʃaild] (child)<br>- ព្យញ្ជនៈ [dʒ] ក្នុងពាក្យ [dʒæm] (jam) នៃភាសាអង់គ្លេស ជាដើម។ |
| **៩២- សូរមាត់ / មុខជះ**<br>អ. oral | សូរព្យញ្ជនៈដែលពេលបន្លឺ នាំងក្រអូមបិទផ្លូវច្រមុះ ដើម្បីឱ្យខ្យល់ក្នុងសួតចេញមកក្រៅតែតាមមាត់។ |

| | |
|---|---|
| បារ. orale ( f. ) | ព្យញ្ជនៈសូរមាត់ ឬ មុខជៈ មាន [p], [b], [f], [v], [s], [k], [kh], [c], [t], [dh], [g],...។ |
| **៩៣- សូរមុខក្រអូម**<br>អ. pre-palatal<br>បារ. pré-palatale ( f. ) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅមុខក្រអូម គឺខ្នងអណ្ដាតទល់នឹងផ្នែកនៃគុហាមាត់ដែលស្ថិតនៅមុខក្រអូម។<br>ព្យញ្ជនៈសូរមុខក្រអូម មាន : [ ʃ ], [ ʒ ],...។ |
| **៩៤- សូររនាំងក្រអូម**<br>អ. velar/guttural<br>បារ. vélaire ( f. ) / gutturale ( f. ) | សូរព្យញ្ជនៈដែលមានទីបន្លឺនៅត្រង់រនាំងក្រអូម គឺអណ្ដាតក្រោយទល់នឹងរនាំងក្រអូម។<br>ព្យញ្ជនៈសូររនាំងក្រអូម មាន : [ k ], [ g ], [ŋ], ...។ |
| **៩៥- សូរលំហូរ/ សូរបង្ហូរ**<br>អ. liquid<br>បារ. liquide ( f. ) | សូរព្យញ្ជនៈដែលពេលបន្លឺ ខ្យល់ដែលរត់ចេញពីសួត ស្ទើរតែមិនត្រដុសនឹងផ្ទៃគុហាមាត់ អណ្ដាតធ្មេញ ឡើយ ហាក់បីដូចជាមានលំហូរ។ ព្យញ្ជនៈលំហូរ ជាព្យញ្ជនៈដែលមានរង្វះខ្យល់កម្រិត២។ ព្យញ្ជនៈលំហូរ មាន : [l], [r], ...។ |
| **៩៦- សូរសព្ទភាសា**<br>អ. linguistic sign<br>បារ. signe( m. ) linguistique | នៅក្នុងសៀវភៅ Cours de linguistique générale របស់គាត់ ភាសាវិទូឈ្មោះ Ferdinand de Saussure បានប្រើបច្ចេកសព្ទ 〝signe linguistique〞 ជំនួស 〝mot〞 ពីព្រោះនៅពេលនោះ គេយល់ថា 〝mot〞 ជាសំណេរ ឬ ជាផ្លាក |

(plaque /étiquette)មួយ សម្រាប់ដាក់លើវត្ថុ (objet)មួយ។ តាមគាត់ ការយល់បែបនេះជាការភាន់ច្រឡំទាំងស្រុង ពីព្រោះ "ពាក្យ" មិនមែនជាផ្លាកមួយសម្រាប់ដាក់លើវត្ថុមួយឬជាសហកម្ម (union) រវាងឈ្មោះមួយនិងវត្ថុមួយនោះទេ ប៉ុន្តែជាសហកម្មមិនអាចបំបែកបានរវាង "image acoustique" និង "concept"។

ក្រោយមក លោក Saussure ហាក់ដូចជាបារម្ភក្រែង "image acoustique" នាំគេឱ្យគិតទៅដល់គ្រឿងដែលទាក់ទាញភ្នែក ផ្ទុយពីអ្វីដែលគាត់ចង់ឱ្យគេយល់តាមគាត់ (ទោះមានពាក្យ "acou-stique" អមផងក៏ដោយ)[32]។ តាមគាត់ "image acoustique" ជាសូរសុទ្ធសាធ ជាទម្រសូរដែលយើងស្តាប់ឮ កាលណា "signe linguistique" ត្រូវបានគេបន្លឺឡើង[33]។

ដោយគាត់បារម្ភអំពីន័យមិនច្បាស់លាស់របស់ "image acoustique" នេះផង និង ដោយ "concept" ជាពាក្យធម្មតាដែលខ្វះ "បច្ចេកភាព" ផង ភាសាវិទូរូបនេះបានជំនួសពាក្យទាំងនេះ ជា

---

[32]- ជាពិសេស ចំពោះជនជាតិខ្មែរដែលអាចគិតទៅដល់ "រូបភាព"(image) ដែលជាគ្រឿងទាក់ទាញភ្នែកជាពិតប្រាកដ។

[33]- លោក Saussure បានបញ្ជាក់ថា " La langue est phonique et non graphique " (ភាសាជាសូរ គឺមិនមែនជាសំណេរទេ)។

| | |
|---|---|
| | លំដាប់លំដោយ ដោយ "signifiant" និង "signifié"។<br>បើយើងប្រែចំៗ ពាក្យមួយសងពាក្យមួយ យើងអាចប្រែ "signe linguistique" ថា "សញ្ញាភាសា" ប៉ុន្តែ ដោយក្នុងភាសាខ្មែរ "សញ្ញា" ច្រើនសម្គាល់គំនូស យើងសូមប្រែ "signe linguistique" ថា "សូរសព្ទភាសា" វិញ ដើម្បីឱ្យឃ្លាតឆ្ងាយពីគំនិតខុស ដែលយល់ថា "ពាក្យ" ជាសំណៅរនោះឯង។<br>ដូច្នេះ សូរសព្ទភាសា ជាសហកម្មមិនអាចបំបែកបានរវាង "signifiant" និង "signifié" *។ លោក Saussure តាងសូរសព្ទភាសា ដូចតទៅ ៖<br><br><br>*សេចក្ដីបញ្ជាក់* :<br>*សញ្ញាព្រួញសម្គាល់សហកម្មដ៏ស្អិតល្មួតរវាង* "signifiant" *និង* "signifié" : *បើគេគិតទៅ* "signifiant" *គេនឹងគិតភ្លាមជាស្វ័យប្រវត្តិទៅ* "signifié" *ផងដែរ*។<br>លោក Saussure អាចរក្សាទុកនូវពាក្យ "mot" ហើយគ្រាន់តែប្រកាសបញ្ជាក់ថា "mot" មិនមែនជាសំណៅរទេ (សំណៅរគ្រាន់តែជាការកត់ត្រា "mot" ដោយអក្សរប៉ុណ្ណោះ) ប៉ុន្តែ បើគាត់ធ្វើបែបនេះ គាត់មិនអាចកម្ចាត់គំនិតខុសបានឡើយ |

| | |
|---|---|
| | ពីព្រោះ ឱ្យតែឮ"mot"ភ្លាម គេគិតទៅដល់សំណេរភ្លាម។ ដោយសារការប្រើពាក្យ "signe linguistique" គាត់បានកម្ចាត់ការភាន់ច្រឡំថា "mot" ជាសំណេរបានដោយជោគជ័យ។<br>__*កំណត់សម្គាល់*__: *យើងប្រើ* "signifiant" *ថា "ន័យករ" និង* "signifié" *ថា "ន័យបញ្ញត្តិ" ជាលំដាប់លំដោយ។* |
| **៩៧- សូរសម្រួល**<br>អ. euphony<br>បារ. euphonie<br>( f. ) | សូរដែលកើតពីការប្រែប្រួលសូរណាមួយក្នុងពាក្យខ្លះ ដើម្បីឱ្យស្រួលត្រចៀកឬស្រួលអាន ច្រើនកើតមានឡើងក្រោមឥទ្ធិពលនៃការសម្រួលសូរនៃការសម្របសូរ ឬ នៃការបំប្លែកសូរ, ឧទាហរណ៍ :<br>- <u>ភាសាបារាំង</u> :<br>pendant [pãdã] > [pãnã],<br>une heure et demie [ynœredəmi] ><br>[ynœredmi] > [ynœre<u>n</u>mi],<br>- <u>ភាសាខ្មែរ</u> :<br>អាឯង > អាហ្អែង,<br>សង្ឃរាជ > សង្រ្គាជ, ...<br>*<u>បញ្ជាក់</u> : ពាក្យខាងក្រៅឃ្នាប សរសេរជាអក្ខរាវិរុទ្ធ ,*<br>*ពាក្យខាងក្នុងឃ្នាប សរសេរជាសញ្ញាសូរវិធី។* |
| **៩៨- សំនួន/វិញ្ញត្តិ**<br>អ. expression<br>បារ. expression<br>( f. ) | តាមន័យទូទៅ គឺជាពាក្យឬកន្សោមពាក្យដែលបញ្ជាក់គំនិតឬមនោសញ្ចេតនា ដើម្បីរំលេចន័យគន្លឹះក្នុងល្បះ។<br>*<u>បញ្ជាក់</u> : ក្នុងភាសាវិទ្យារបស់លោក* Louis Hjelmslev *ពាក្យ* expression *មានន័យពិសេស ផ្សេងពីន័យខាងលើ។* |

| | |
|---|---|
| **៩៩- ស្រះ**<br>អ. vowel<br>បារ. voyelle (f.) | សូរដែលបន្លឺឡើងដោយគ្មានទំនប់, ឧទាហរណ៍ : [ɑ], [ɑ:], [ɔ], [ɔ:], [a], [a:], [e], [e:], [o], [o:], |
| **១០០- អឃោសៈ**<br>អ. unvoiced<br>បារ. non-voisée/ sourde (f.) | ព្យញ្ជនៈដែលនៅពេលបន្លឺពុំមានលំញ័រខ្សែសំ-ឡេងទេ។<br>ព្យញ្ជនៈ / s /, / t /, / p /,...ជាព្យញ្ជនៈអឃោសៈ។ |
| **១០១-អឌ្ឍព្យញ្ជនៈ/ ព្យញ្ជនៈកន្លះ**<br>អ. semi- consonant<br>បារ. semi-consonne (f.) | សូរព្យញ្ជនៈដែលពេលបន្លឺ ខ្យល់ដែលរត់ចេញពីសួតមិនប៉ះនឹងផ្ទៃគុហាមាត់ អណ្ដាត ធ្មេញ ទេ។ អឌ្ឍព្យញ្ជនៈ/ព្យញ្ជនៈកន្លះ ជាព្យញ្ជនៈដែលមានរង្វះខ្យល់កម្រិត៣។ អឌ្ឍព្យញ្ជនៈ/ព្យញ្ជនៈកន្លះមាន : [j], [w], ...។<br>គេអាចហៅវាម្យ៉ាងទៀតថា អឌ្ឍស្រះ/ស្រះកន្លះ។ |
| **១០២- អតិសទ្ទតា**<br>អ. archiphoneme<br>បារ. archiphonème (m.) | សទ្ទតាពីរផ្សេងគ្នាដែលមានសូរប្រទ្បំគ្នាត្រង់ទី-តាំងសូរខ្លះ ក្នុងពាក្យ។<br>ឧទាហរណ៍ ៖ ភាសាអាល្លឺម៉ង់ មានសទ្ទតា /t/ , /d/ ប្លែកគ្នា ប៉ុន្តែក្នុងពាក្យ *rad* និង ពាក្យ *rat* , *d* និង *t* មានសូរប្រទ្បំគ្នា ទើបគេសន្មតយក [ᴛ] សម្រាប់តាង។ ដូច្នេះ ពាក្យ *rad* និង ពាក្យ *rat* តាងដោយ [raᴛ]។ |
| **១០៣- អន្តេបទ/ ផ្នត់ដែក**<br>អ. infix<br>បារ. infixe (m.) | អក្ខាសបទ/ផ្នត់មួយបែបដែលគេដាក់ជ្រៀតចូលក្នុងពាក្យ ដើម្បីបង្កើតពាក្យកម្លាយ , ឧទាហរណ៍ :<br>- ចាំ + [-ម-] > ឆ្មាំ,<br>- គាប + [-ន-] > ឃ្នាប, ...។ |

| | |
|---|---|
| | <u>*បញ្ជាក់*</u> :<br>*លោកគ្រូ នៅ ស៊ិន បានផ្ដល់យោបល់ថា "អន្តរ/អន្តរា" មានន័យដូច* "inter" *នៃភាសាបារាំង, ឧ. អន្តរជាតិ* = inter-national, *អន្តរក្រសួង* = inter-service,... *ដូច្នេះ ពាក្យសព្ទ "អន្តរាបទ" របស់លោក កេង វ៉ាន់សាក់ ត្រូវគ្នានឹង* "interfixe" *ដែលមានក្នុងភាសារុស្ស៊ី គឺមិនមែន* "infixe" *ទេ គប្បីយើងប្រែពាក្យ* "infixe" *ថា "អន្តេបទ" វិញ។* |
| **១០៤- អនុប្រយោគ/ឃ្លា**<br>អ. clause<br>បារ. proposition (f.) | អនុប្រយោគជាផ្នែកមួយនៃល្បះ/ប្រយោគដែលមានកិរិយាសព្ទស្នូលតែមួយ, ឧទាហរណ៍ :<br>- ខ្ញុំស្គាល់មនុស្សម្នាក់។<br>- ភ្នំពេញជារាជធានីប្រទេសកម្ពុជា។<br><br>អនុប្រយោគអាចជា អនុប្រយោគគោល (proposition principale) ឬ អនុប្រយោគរណប (proposition subordonnée)។<br>ឧ. ល្បះ "ខ្ញុំបានជួបបុរសម្នាក់ដែលជាអ្នកកាសែត។" មានពីរអនុប្រយោគ គឺ :<br>- អនុប្រយោគគោល ៖ "ខ្ញុំបានជួបបុរសម្នាក់"<br>- អនុប្រយោគរណប ៖ "ដែលជាអ្នកកាសែត"។ |
| **១០៥- អនុសព្ទ**<br>អ. hyponym<br>បារ. hyponyme | ពាក្យដែលមានន័យចំណុះឱ្យពាក្យមួយទៀតដែលជាមហាសព្ទ, ឧទាហរណ៍ :<br>- <u>ក្នុងភាសាខ្មែរ</u> :<br>ពាក្យ *ឆ្កែ* ជាអនុសព្ទ ធៀបនឹងពាក្យ *សត្វ* ដែលជាមហាសព្ទ, |

| | |
|---|---|
| | ពាក្យ *ម៉ូតូ* ជាអនុសព្ទ ធៀបនឹងពាក្យ *យានយន្ត* ដែលជាមហាសព្ទ ,...<br>- ក្នុងភាសាបារាំង :<br>ពាក្យ *écarlate* ជាអនុសព្ទ ធៀបនឹង ពាក្យ *rouge* ដែលជាមហាសព្ទ ,<br>ពាក្យ *chat* ជាអនុសព្ទ ធៀបនឹងពាក្យ *animal* ដែលជាមហាសព្ទ។ |
| **១០៦- អញ្ញាសបទ/ ផ្នត់**<br>អ. affix<br>បារ. affixe (m.) | បញ្ញត្តិនេះត្រូវបានគេសម្គាល់ដោយពាក្យផ្សេងៗគ្នា :<br>- បទភ្ជាប់ (អៀវ កើស , *ភាសាខ្មែរ* , បណ្ណាគារមិត្តសេរី , ១៩៦៧[34], ទំព័រ ១៦៨)<br>- អញ្ញាសបទ (កេង វ៉ាន់សាក់ , *មូលភាពនៃការបង្កើតពាក្យថ្មី* , រោងពុម្ពទេព , បណ្ណាគាររស្មីកម្ពុជា , ១៩៦៣ ,ទំព័រ ១៤៣)<br>- ផ្នត់ (ក្រសួងអប់រំ , *វេយ្យាករណ៍ថ្នាក់ទី៦* , មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា, ១៩៨២ , ទំព័រ ១)<br>គណៈកម្មការបច្ចេកសព្ទភាសាវិទ្យានិងអក្ស- |

[34]- សៀវភៅនេះត្រូវបានបោះពុម្ពច្រើនឆ្នាំក្រោយពីអ្នកនិពន្ធបានទទួលមរណភាព ៖ ដូច្នេះ ពាក្យ បទភ្ជាប់ ប្រើក្នុងសៀវភៅនេះ ទំនងជាបានបង្កើតឡើងមុនពាក្យ អញ្ញាសបទ របស់លោក កេង វ៉ាន់សាក់។ អ្នកនិពន្ធ អៀវ កើស បានដាក់ពាក្យបារាំង affixes ជាប់នឹងពាក្យ បទភ្ជាប់ ប៉ុន្តែ បទភ្ជាប់ ដែលគាត់បានស្រង់នោះ មានលក្ខណៈដូច affixes នៃភាសាបារាំងផង និង ដូច racines primaires របស់លោក Joseph Guesdon ផង។

| | |
|---|---|
| | សិល្ប៍ សម្រេចជ្រើសរើសយក អព្ភាសបទ/ផ្នត់ និង កំណត់និយមន័យដូចតទៅ :<br>រូបតាសម្រាប់ប្រើដើម្បីបង្កើតពាក្យកម្លាយ/កម្លាយលើកម្លាយ សម្រាប់ភ្ជាប់នឹង :<br>- ពាក្យឫស , ឧ. ដឹង + អព្ភាសបទ [ប៉-] > ប្ដឹង ,<br>- ពាក្យកម្លាយម្ដងហើយ , ឧ. ប្ដឹង + អព្ភាសបទ [-អ´ណ-] > បណ្ដឹង ,<br>- ឫស ក្នុងភាសាបារាំង , ឧទាហរណ៍ :<br>• all + អព្ភាសបទ *er* > aller ;<br>• form + អព្ភាសបទ [-sjɔ̃] ( -tion ) > [fɔrma̲sjɔ̃][35] ( forma̲tions ),..។<br><br>លោក កេង វ៉ាន់សាក់ ចែកអព្ភាសបទជា បុព្វ-បទ, អន្តរាបទ និង បច្ឆិមបទ។<br>ក្រុមអ្នកនិពន្ធនៃវេយ្យាករណ៍ក្រសួងអប់រំ ចែកផ្នត់ជា ផ្នត់ដើម, ផ្នត់ដែក និង ផ្នត់ចុង។ |
| **១០៧- អាគម**<br>អ. epenthesis | សទ្ទតាដែលឥតទាក់ទងនឹងជាតិសព្ទ កើតឡើងក្នុងពាក្យឬកន្សោមពាក្យខ្លះ ដើម្បីជាវិសាលសូរ ឬ |

[35]- សូរ [a] ក្នុងពាក្យ [fɔrma̲sjɔ̃] បានកើតឡើងដើម្បីសម្រួលអំណាន។

| | |
|---|---|
| បារ. épenthèse<br>( f. ) | ដើម្បីសម្រួលអំណាន , ឧទាហរណ៍ :<br>- ភាសាបរទេស :<br>lat. camera > frs chambre ( b ជាអាគម ),<br>lat. hibernum > it./port. inverno ( n ជាអាគម )។<br>- ភាសាខ្មែរ :<br>ជង់ > ជ្នង់ > ជ្រនង់ [crɔnɔŋ] ( [rɔ] ជាអាគម,<br>ចតុ + អង្គ > ចតុរង្គ ( រ ជាអាគម ),<br>ឆ + អភិញ្ញា > ឆឡភិញ្ញា ( ឡ ជាអាគម តាមឯកឧត្ដម ឈន អៀម )។ |
| **១០៨-ឯកតា**<br>អ. unit<br>បារ. unité ( f. ) | ភាគនៃខ្សែសម្ដីក្នុងភាសាដែលគេអាចវិភាគចេញពីគ្នា ដូចជា សទ្ទតា[36], ពាក្យទោល[37] ឬ ល្បះទោល[38]។ សទ្ទតា , ពាក្យទោល ឬ ល្បះទោល ជា ឯកតាភាសា[39]។ |

[36]- សូមមើលនិយមន័យសម្រាប់ សទ្ទតា។

[37]- សូមមើលនិយមន័យសម្រាប់ ពាក្យទោល។

[38]- សូមមើលនិយមន័យសម្រាប់ ល្បះទោល។

[39]- យកលំនាំតាម Dictionnaire de linguistique របស់លោក Jean Dubois & alii, Librairie Larousse, 1973, p.502។

# ប្រដាប់ដកដង្ហើម ប្រើជាប្រដាប់បន្លឺសូរ

## (ជាបង្អែកឱ្យងាយយល់បច្ចេកសព្ទនៃសូរវិទ្យានិងសទ្ទតាវិទ្យា)

ប្រដាប់ដកដង្ហើម ប្រើជាប្រដាប់បន្លឺសូរ

(គំនូរប្រៀបធៀប ការដកដង្ហើម ការបរិភោគ និង ការបន្លឺសូរ)




រូបសញ្ញាទី១ : ការដកដង្ហើម

រូបសញ្ញាទី២ : ការបរិភោគ

រូបសញ្ញាទី៣ : ការបន្លឺសូរនាសិកជៈ

រូបសញ្ញាទី៤ : ការបន្លឺសូរមុខជៈ

# បច្ចេកសព្ទអក្សរសិល្ប៍
# ដែល
# គណៈកម្មាធិការជាតិភាសាខ្មែរ / គ.ជ.ភ.ខ.
# (បច្ចុប្បន្ន ក្រុមប្រឹក្សាជាតិភាសាខ្មែរ / ក.ជ.ភ.ខ.)
# បានអនុម័ត

| | |
|---|---|
| **១-កវី/ កវីនិពន្ធ**<br>អ. poet<br>បារ. poète | អ្នកដែលចេះតែងឆន្ទ អ្នកពូកែខាងសម្ដីអ្នកនិពន្ធខាងកាព្យឃ្លោងដ៏ល្បីល្បាញ។<br>ឧ. ភិរម្យភាសា **អ៊ូ** ហៅ **ង៉ុយ** ព្រះបទុមត្ថេរ **សោម**,...។ |
| **២-កវីនិពន្ធន៍** | ការរៀបរៀង ការចងក្រង ការតែងឆន្ទរបស់កវី។<br>ឧ. *(...)ស្ដេចមានមហេសី នាមកែវកាកី*<br>*ល្អល្អះឥតហ្មង ឥតមានស្រីណា*<br>*សោភាផ្ទឹមផង សមសព្វកន្លង*<br>*កន្លោងអស់ស្រី។*<br>*កាយកើតអស្ចារ្យ អំពីផ្កាកា-*<br>*ណិកាសោភី ភក្ត្រាសោភ័ណ*<br>*ដូចចន្ទ្របូណ៌មី សក់ដូចភមរី*<br>*រលើបខ្មាញ់ខ្មៅ [40]។ (...)* |
| **៣-កាព្យរស** | តម្លៃរបស់អត្ថបទជាពាក្យកាព្យដែលមានសម្ផស្សចួន រណ្ដំ ណែងណង។ |

[40] ព្រះអង្គ ឌួង : ***រឿង កាកី***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ឆ្នាំ១៩៩៧, ទំព័រ៨។

| | |
|---|---|
| | ឧ. កាព្យរសនៃកំណាព្យរៀបរាប់អំពីអរុណោទ័យ ឬ អស្ដង្គតកាលនៃព្រះអាទិត្យ។ |
| **៤-កាមរូបារម្មណ៍** | រូបារម្មណ៍ដែលកើតឡើងតាមរយៈពាក្យពេចន៍ឃ្លាប្រយោគ ឬ សេចក្ដីក្នុងកំណាព្យ ក្នុងអត្ថបទពាក្យរាយ ដែលធ្វើឱ្យអ្នកអាន អ្នកស្ដាប់មានការរំភើប ស្រើបស្រាលទៅដោយកាមរាគ។<br>ឧ.*(...)នាងធ្វើជាធ្លាក់ រសាយសូកាក់ អំពីអង្សា ត្រុឌយល់សុដន់ ណែនក្ដន់ឧរា ព្រួចចិត្តចិន្ដា ស្រៀវស្រើបប្រតិព័ទ្ធ* [41]។*(...)* |
| **៥-ការផ្សំលោកិយសច្ចៈនិងអច្ឆរិយៈ** | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធលើកយករឿងពិតក្នុងសង្គមនិងរឿងអស្ចារ្យហួសពីការពិតមកបង្ហាញក្នុងស្នាដៃ។<br>ឧទាហរណ៍ទី១ : នៅក្នុងរឿងមហាវេស្សន្តរ ពរទី៥ ព្រះនាងសុបារសុប្បតីបានទទួលពរពីព្រះឥន្ទ្រមុននឹងព្រះនាងជាព្រះមាតារបស់ព្រះវេស្សន្តរ គឺ "*ពេលមានគភ៌ សូមឱ្យមានផ្ទៃពោះរាបស្មើល្អដូចប្រក្រតី*" [42]។<br>ឧទាហរណ៍ទី២ : នៅក្នុងរឿងរាមកេរ្តិ៍ កាលព្រះរាមយាងទៅដល់ក្នុងព្រៃដើម្បីបួសជាបស្វី |

[41] ព្រះអង្គ ឌួង : ***រឿង កាកី***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៤១, គ.ស. ១៩៩៧, ទំព័រ ១៧។

[42] ញ៉ុក ថែម : ***មហាវេស្សន្តរជាតក***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, គ.ស. ១៩៩៥ ទំព័រ ៣៣។

| | |
|---|---|
| | *"ព្រៃព្រឹក្សាប្រែសភាពពីក្តៅទៅត្រជាក់ ដើមឈើជ្រុះស្លឹកស្រពាប់ស្រពោនទៅជាលាស់ស្លឹកមានផ្លែផ្កាដង្កុំដង្គោល មើមឈើពុលប្រែក្លាយទៅជាសាបទទួលទានបាន រីឯសត្វកាចសាហាវប្រែក្លាយជាស្លូត"*[43]។ |
| **៦-កាលបរិច្ឆេទរឿង**<br>អ. composition date<br>បារ. date de la composition ? | ថ្ងៃ ខែ ឆ្នាំ នៃការនិពន្ធរឿង។<br>- អត្ថបទអក្សរសិល្ប៍ខ្មែរមួយចំនួន ពេលខ្លះកាលបរិច្ឆេទនេះមានរៀបរាប់ក្នុងអារម្ភកថាខាងដើម, ឧទាហរណ៍ :<br>- នៅក្នុងរឿងកាកី ការបង្ហាញកាលបរិច្ឆេទនៅដើមរឿង ៖<br>*«(...)ពុទ្ធសាសនំ អតិក្កន្តំ អដ្ឋបញ្ញាសតិសត ទ្វេសហស្សា មហាសករាជាឯកស័ប្តត្រីស័ប្ត*[44] *។(...)»*<br>- នៅក្នុងរឿងព្រេងនិទានខ្មែរ ការបញ្ជាក់កាលបរិច្ឆេទពុំមានឡើយ។ |
| **៧-កាយរូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយដែលកើតមកពីកាយិន្ទ្រិយ ដោយកវីនិពន្ធលើកយកកាយារម្មណ៍ផ្សេងៗមករៀបរាប់ ដូចជា រលើប |

[43] អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស : ***រឿងរាមកេរ្តិ៍ ខ្សែទី១,*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, គ.ស. ១៩៩៥, ទំព័រ ៦០-៦៣, ខ្សែទី២ ទំព័រ ១-១៩។

[44] ព្រះអង្គ ឌួង : ***រឿងកាកី*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, បោះពុម្ពគ្រាទី៦, ព.ស. ២៥៤១, គ.ស. ១៩៩៧, ទំព័រ២។

| | |
|---|---|
| | រលោង រៀវឆ្មារ ...។<br>ឧ. *(...)បងចាំកេសីបីខ្មៅញ្រាប់ ប្អូនក្រសោបចាប់ចង ចាផ្កា កែមចួតប្រួតមាលា អស់ផ្កាសាររពើភ្វី។ បងចាំនាថ្វាស បីដូចពពិលមាសមាននៃរស្មី ដូចជាព្រះចន្ទពេញដ៏បូណ៌មី លោកយល់ពន្លឺព្រៃ [45]។(...)* |
| **៨- កុសលរស**<br>អ. the good<br>បារ. le bien | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះលើកយកការអប់រំ ទូន្មាន ប្រៀនប្រដៅមកបង្ហាញតាមរយៈសកម្មភាពតួអង្គឬដំណើររឿង។<br>ឧទាហរណ៍ : នៅក្នុងច្បាប់ស្រីហិតោបទេស, គតិលោក...។ |
| **៩-កំណាព្យ** | អត្ថបទពាក្យចួន ផ្ទួន រណ្តំ ណែងណង ប្រកបដោយរូបារម្មណ៍រស់រវើក។<br>**ឧ.** គុកកាមកិលេសរបស់លោក កេង វ៉ាន់សាក់។ |
| **១០-កណ្ឌ** | វគ្គ ភាគ ខ្សែ ៖ រឿងក្នុងទសជាតកខ្លះមានចែកជាកណ្ឌ។<br>ឧ. រឿងវេស្សន្តរជាតក មាន១៣កណ្ឌ។ |

[45] អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស : ***រាមកេរ្តិ៍ខ្មែរ៤***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, គ.ស. ១៩៩៥, ទំព័រ ២៥។

| | |
|---|---|
| **១១- កន្សែសារពេជ្ជ** | ស្រីជាមហេសីឬភរិយារបស់ព្រះពោធិសត្វក្នុងបច្ឆិមជាតិ កាលនៅជាគ្រហស្ថ ឬ ដែលបានត្រាស់ហើយ។ |
| **១២-កម្មផល** | ទ្រឹស្តីកម្មផលដែលបង្ហាញពីចំណងនៃអំពើនិងផលដែលបុគ្គលបានសាងឡើង។<br>ឧ. ទ្រឹស្តីកម្មផលនេះមានបង្ហាញក្នុងរឿងក្រុងសុភមិត្រ។ |
| **១៣-កម្មពៀរ** | ផលអាក្រក់ដែលបុគ្គលបានទទួលដោយសារអំពើអាក្រក់ដែលបុគ្គលនោះបានប្រព្រឹត្តពីអតីតជាតិ (ពុទ្ធនិយម)។<br>ឧ. នាងពីរដណ្តប់បានចាប់ត្រីចង្វាដោតផ្លុះភ្នែក ពួកនាងក៏ត្រូវបានមេសន្ធមាយក្សខ្វេះភ្នែក។ |
| **១៤-កម្រងកែវ** | ពាក្យពេចន៍រំលេចដោយសំនួនសម្តីដែលអ្នកនិពន្ធឬកវីបានចងក្រងជាពាក្យរាយលាយចម្រុះដោយពាក្យចួនរណ្តំ។ ពាក្យកម្រងកែវច្រើនប្រើក្នុងសាស្ត្រាទេសន៍។<br>ឧ.*(...)មានព្រាហ្មណ៍ម្នាក់ឈ្មោះជូជក ព្រឹទ្ធាចារ្យ រូបអន្ធការ ស្គមប្រដោង ប្រមុះកោង ទ្រូងសឹងតែឆ្អឹង សក់រឹងក្រញាង ពោះធំកំប៉ោង លោងសំពៀត ដំបាត្រចៀក យុរយារក្រាស់ដូចយ្លង់ភ្លើង ជើងកោងដូចជើងសេក ភ្នែកស្រលៀងស្រលើ សាច់* |

| | |
|---|---|
| | *ពកដូចគេផ្ញើ វេដិបវេដុប យុរយារ ប៉ុនផ្លែក្រសាំង ផ្លែសម៉ ផ្ទេញស ក្បាលវែងតូចម្ខាងដូចផ្លែត្នោត*, ។[46] *(...)* |
| **១៥- ខន្តីបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះចន្ទកុមារបានបំពេញដោយការអត់ធ្មត់គ្របសង្កត់នូវសេចក្ដីក្រោធ។ |
| **១៦- គុណជាតិ** | គុណគ្រប់យ៉ាង មានសីល សមាធិ បញ្ញា ជាដើម។ |
| **១៧-ឃានរូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយ ដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគ ដែលរំលេចឱ្យដឹងអំពីក្លិន។<br>ឧ.*(...)កបកាយក្រអូប ទោះទាំងរាងរូប*<br>*ប្រហើរពុំបាច់ រកផ្កាគ្រឿងអប់*<br>*ឈ្ងុយឈ្ងប់សព្វសាច់ ពិដោរបណ្ដាច់*<br>*បណ្ដាលអស់ស្រី*[47] ។*(...)* |
| **១៨- ចលនា អក្សរសិល្ប៍ខ្មែរ**<br>អ. movement of khmer literature | ទម្រង់ផ្សេងៗគ្នានៃអក្សរសិល្ប៍ខ្មែរដែលស្ថិតនៅក្រោមឥទ្ធិពលនៃលទ្ធិឬលោកទស្សនៈណាមួយ។ ចលនាអក្សរសិល្ប៍ខ្មែរបែងចែកជា៖<br>- អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម,<br>- អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម, |

[46] ញ៉ុក ថែម : ***មហាវេស្សន្តរជាតក***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, ទំព័រ ១៧៣-៧៤។

[47] ព្រះអង្គ ឌួង : ***រឿង កាកី***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ឆ្នាំ១៩៩៧, ទំព័រ ១០។

| | |
|---|---|
| បារ. mouvement de la littérature khmère | - អក្សរសិល្ប៍ខ្មែរបែបខេមរនិយម,<br>- អក្សរសិល្ប៍ខ្មែរបែបបរទេសនិយម។ |
| **១៩-ចក្ខុរូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយ ដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគ ដែលរំលេចឱ្យឃើញអំពីរូបរាង។<br>ឧ.*(...)រីកូខ័នខែងមោះហិមា រូបរូបឦតា*<br>*ស្រមើងស្រមាក់ស៊ីមស្តែ។*<br>*សក្តិសួនជាអ្នកប្រើរព្រៃ ខ្លួនខ្មៅក្រៅវិស័យ*<br>*នូវផ្ញេញសស្មឹមភ្លែកប្រាល។*<br>*ខ្លួនខ្លោះខ្លាំងខែងពេញពាល ជាត់ជំមមារ*<br>*មមូរមមុលព្រឹក្សព្រៃ។*<br>*ជំក្លិនខ្លាំងឆ្មេះផ្កាបក្រៃ ដូចគ្នាតដ៏វិស័យ*<br>*សំបើមសម្បុរពោមា[48]។(...)* |
| **២០-ចេតនារូបារម្មណ៍** | រូបារម្មណ៍ដែលកវី អ្នកនិពន្ធ បង្កើតឡើង ហើយអធិប្បាយតាមរយៈការប្រើពាក្យពេចន៍ ឃ្លាប្រយោគ នៅក្នុងអត្ថបទពាក្យកាព្យ ពាក្យកម្រងកែវ ពាក្យរាយ ធ្វើឱ្យអ្នកអានមានចិត្តរំភើប ជឿស្លុងទៅដោយមនោសញ្ចេតនាទុក្ខព្រួយ សប្បាយ កំហឹង ភ័យខ្លាច ត្រេកត្រអាល សង្ឃឹម អស់សង្ឃឹម ស្រឡាញ់ |

[48] អ្នកអង្គម្ចាស់ វឌ្ឍាឆាយាវង្ស : ***រាមកេរ្តិ៍ ខ្សែ១***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, គ.ស. ១៩៩៥, ទំព័រ ៤២។

| | |
|---|---|
| | ស្អប់ឬការទទួលយកជំនឿណាមួយដោយពុំចាំបាច់ពិចារណាវែងឆ្ងាយឡើយ។<br>ឧ. *(...)ទុំស្រែកថាឱព្រះពាយផាត់*<br>*ទាវអើយបែកបាត់ជុំពិដោរ*<br>*ជាប់តែក្លិនក្លែបអែបគន្ធ-*<br>*រសរូបទាវចោរចើកចោលប្ដី។*<br>*ឱ្យនៅតែឯងតែអញសោះ*<br>*ទាវគ្មានស្រណោះកោតចិត្តស្រី*<br>*ចិត្តស្រស់ឥតញ្ញានគ្មានប្រណី*<br>*បានដួនជាប្ដីមិនខ្វីទុំ។*<br>*ឱ ! ទាវអើយទុក្ខបងចម្លែក*<br>*បងឡើងដល់ស្មែកទីត្បូងឃ្មុំ*<br>*ម្ល៉េះសមអរជូនគេគិតគុំ*<br>*ហៅភ្ញៀវជួបជុំសម្លាប់បង* [49] ។ *(...)* |
| **២១- ជាតក** | កម្រងនៃរឿងពីជាតិមុនៗ ដែលបុគ្គលណាមួយបានលុះញាណវិសេសសម្រាប់ដឹងជាតិ ហើយយករឿងនោះមកសម្ដែងប្រាប់អ្នកដទៃឱ្យបានដឹង។ |
| **២២-ជិវ្ហារូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគដែលរំលេចឱ្យដឹងអំពីរសជាតិ។ |

[49] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ,*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥១៤, ទំព័រ ៩៤-៩៥។

| | |
|---|---|
| | ឧ. *(...)ឆ្វាញ់ដាប់អណ្ដាត បាយគុកព្រហាត*<br>*នាំឱ្យរុកគួន រើសរកយប់ថ្ងៃ*<br>*ស្មាដៃនឹមនួន ឆ្វាញ់នៅពេញខ្លួន*<br>*មិនឆ្អែតសោះឡើយ*[50] *។(...)* |
| **២៣-ជីវរូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយ ដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគ ដែលរំលេចឱ្យដឹងពីជីវិត ពីចលនា ពីវិញ្ញាណ ពីចេតនារស់រវើក។<br>ឧ.*(...)មិនដឹងពេលម៉ោង មើលតាមប្រហោង*<br>*ឃើញតាមគំនិត មេឃាធំធេង*<br>*ល្វឹងល្វេងដូចចិត្ត មានសេរីសិទ្ធិ*<br>*តែតាមបំណង*[51]*។(...)* |
| **២៤- តថរស**<br>អ. the real<br>បារ. le réel | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះលើកយកបញ្ហា ឬ ព្រឹត្តិការណ៍ពិតមកបង្ហាញ។<br>ឧទាហរណ៍ : នៅក្នុងរឿងភូមិតិរច្ឆាន អ្នកនិពន្ធបានលើកយកតួអង្គ ព្រឹត្តិការណ៍ ទីកន្លែង ដែលមានពិតក្នុងសង្គមខ្មែរមកបង្ហាញ។ |
| **២៥-តួយ៉ាង** | បែប ឧទាហរណ៍ គំរូ តំណាង...។ |

[50] កេង វ៉ាន់សាក់ : **គុកកាមកិលេស** , ភ្នំពេញ, គ.ស.[?], ទំព័រ៤២។
[51] កេង វ៉ាន់សាក់ : **គុកកាមកិលេស** , ភ្នំពេញ, គ.ស.[?], ទំព័រ២៨។

| | |
|---|---|
| **២៦- តួអង្គ**<br>អ. character<br>បារ.personnage<br>( m. ) | មនុស្ស អមនុស្ស សត្វ វត្ថុ រុក្ខជាតិ ដែលមានសកម្មភាពនៅក្នុងរឿង។<br>ឧទាហរណ៍ :<br>- នៅក្នុងរឿងធនញ្ជ័យ តួអង្គមាន ធនញ្ជ័យ សេដ្ឋី ស្ដេច ។ល។<br>-នៅក្នុងរឿងអ្នកតាទឹកអ្នកតាភ្នំ តួអង្គមាន អ្នកតាទឹក អ្នកតាភ្នំ យាយតា កូនក្រមុំរបស់យាយតា ។ល។ |
| **២៧-តួអង្គបន្ទាប់បន្សំ** | តួអង្គក្រៅពីតួអង្គឯកនិងតួអង្គរងដែលមានវត្តមានក្នុងដំណើររឿងតែក្នុងមួយខណៈប៉ុណ្ណោះ។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ តួអង្គអ្នកស្រុកចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ម៉ឺនងួននិងនាងទាវជាតួអង្គបន្ទាប់បន្សំ។ |
| **២៨-តួអង្គតួយ៉ាង**<br>អ.type character<br>បារ. personnage type ( m. ) | តួអង្គដែលតំណាងក្រុមមនុស្សឬវណ្ណៈណាមួយក្នុងសង្គម។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ<br>-ទុំនិងទាវជាតួអង្គតួយ៉ាងរបស់យុវជនខ្មែរសម័យលង្វែកដែលមានទស្សនៈថ្មីក្នុងការទាមទារសិទ្ធិសេរីភាពជ្រើសរើសគូស្រករ។<br>-ម្ដាយទាវជាតួអង្គតួយ៉ាងរបស់អ្នកគ្រប់គ្រងគ្រួសារនាសម័យលង្វែកដែលប្រកាន់គោលការណ៍ ‹‹នំមិនធំជាងនាឡិ››។ |

| | |
|---|---|
| **២៩-តួអង្គរង**<br>អ. secondary character<br>បារ. personnage secondaire (m.) | តួអង្គបន្ទាប់ពីតួអង្គឯក។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ពេជ្រ នាងនោ ម៉ឺនងួន ម្ដាយទាវ អរជូន... ជាតួអង្គរង។ |
| **៣០-តួអង្គរំឭក** | តួអង្គដែលអ្នកនិពន្ធលើកយកមកនិយាយ ក៏ប៉ុន្តែ មិនមានវត្តមាននៅក្នុងរឿងទេ។<br>ឧទាហរណ៍ : នៅក្នុងរឿងព្រះអាទិត្យថ្មីរះលើ ដែនដីចាស់ តួអង្គសម្ដេចឪជាតួអង្គរំលឹក ព្រោះ តួអង្គនេះពុំមានវត្តមានឬសកម្មភាពអ្វីនៅក្នុងរឿង ទេ អ្នកនិពន្ធគ្រាន់តែលើកព្រះនាមនិងគោល នយោបាយរបស់ព្រះអង្គមកបង្ហាញតែប៉ុណ្ណោះ។ |
| **៣១-តួអង្គឯក**<br>អ. main Character<br>បារ. personnage principal (m.) | តួអង្គសំខាន់បំផុតនៃរឿង។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ទុំនិងទាវជា តួអង្គឯកក្នុងរឿងទុំទាវ។ |
| **៣២-ទសជាតក** | រឿងជប់ជាតិចុងក្រោយរបស់ព្រះសក្យមុនីគោតម បរមសម្ពុទ្ធ។ រឿងនេះប្រភពដើមជាភាសាបាលី មាននៅក្នុងគម្ពីរខុទ្ទកនិកាយ។<br>ឈ្មោះរឿងទាំងជប់មាន៖<br>១- រឿងតេមិយជាតក<br>២- រឿងមហាជនកជាតក |

| | |
|---|---|
| | ៣- រឿងសុវណ្ណសាមជាតក<br>៤- រឿងនេមិរាជជាតក<br>៥- រឿងមហោសថជាតក<br>៦- រឿងភូរិទត្តជាតក<br>៧- រឿងចន្ទកុមារជាតក<br>៨- រឿងនារទព្រហ្មជាតក<br>៩- រឿងវិធុរជាតក<br>១០- រឿងវេស្សន្តរជាតក។ |
| **៣៣-ទសបារមី** | បារមីទាំង១០ ដែលព្រះពោធិសត្វបានបំពេញដើម្បីបានត្រាស់ជាព្រះពុទ្ធ។<br>ទសបារមីមាន : នេក្ខម្មបារមី វីរិយបារមី មេត្តាបារមី អធិដ្ឋានបារមី បញ្ញាបារមី សីលបារមី ខន្តិបារមី ឧបេក្ខាបារមី សច្ចបារមី ទានបារមី។ |
| **៣៤-ទសពរ** | ពរដប់ប្រការ ដែលព្រះនាងសុបារសុប្បតីម្ដាយព្រះវេស្សន្តរសូមពរពីព្រះឥន្ទ្រ។ ពរទាំងនេះចែងក្នុងកណ្ឌទី១ ឈ្មោះកណ្ឌទសពរ ក្នុងរឿងមហាវេស្សន្តរជាតក គឺ<br>១- សូមឱ្យបានជាអគ្គមហេសី នៃព្រះបាទស្រីសញ្ជ័យសោយរាជ្យនៅនគរជេតុត្តរ។<br>២- សូមឱ្យមាននេត្រាមូលខ្មៅយង់ មានភមោ (ចិញ្ចើម) កោងទ្រទេសទ្រទ្ទួយដូចចង្កួយកៅ |

| | |
|---|---|
| | ទណ្ឌា(ធ្នូ)។<br>៣- សូមឱ្យមាននាមថា សុបារសុប្បតី (ផុស្សតី) ដដែល។<br>៤- សូមឱ្យមានបុត្រាដ៏ប្រសើរមួយអង្គ មានកិត្តិនាមល្បីល្បាញ ចូលចិត្តឱ្យទាន។<br>៥- ពេលទ្រង់គភ៌ សូមឱ្យមានឧទររាបស្មើល្អដូចប្រក្រតី។<br>៦- សូមកុំឱ្យមានដោះសណ្ដាយ។<br>៧- សូមកុំឱ្យមានសក់ស្កូវ។<br>៨- សូមឱ្យមានសាច់សម្បុរល្អិតល្អបីដូចពពិលមាស។<br>៩- សូមឱ្យអាចដោះទុក្ខទោសរបស់មនុស្សសត្វទាំងឡាយ។<br>១០-សូមឱ្យមានសព្វសត្វ គឺហង្ស ក្រៀល ក្ងាន សឹងហើរឆ្វាត់ឆ្វៀលបន្លឺនូវសព្ទនោះឮល្វេងល្វើយពីរោះឮដ៏ព្រះរាជមន្ទីរនិងសូមឱ្យមានអ្នកប្រាជ្ញរាជបណ្ឌិតចេះធម៌អាថ៌កុំបីឱ្យដាច់អំពីព្រះរាជមន្ទីរ។ |
| **៣៥-ទស្សនីយរស**<br>អ. picturesque<br>បារ. pittoresque<br>(m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះរៀបរាប់អំពីទេសភាពធម្មជាតិព្រៃព្រឹក្សា មច្ឆា បក្សាបក្សី បង្កើតជាសិល្បបរិយាកាស ដែលជាលម្អមួយចំពោះចក្ខារម្មណ៍និងសោតារម្មណ៍របស់អ្នកអាននិងអ្នកស្ដាប់។ |

| | |
|---|---|
| | ៤. ការរៀបរាប់ធម្មជាតិក្នុងរឿងក្រុងសុភមិត្រ៖<br>*(...) សម៉ពង្រងនូវផ្លែក ត្រៀលត្រាចប៉ប្រេក ខ្វាវខ្វិតខ្ទុរខ្ទារ។*<br>*ស្វាតស្វាយក្រូចក្រាយរកា ពពេលពពារ កប្បាសក្របៅ។*<br>*ផ្តុកផ្តៀកកង្រៀកតាត្រៅ ចាកចេកព្នុលព្នៅ ផ្នឹករាំងក្រកោះ។*<br>*គ្រើលគ្រង់លពង់លំពស់ រល្វយរលោះ[52] រលាយរលា។*<br>*ផ្កាវផ្ទុងផ្កាផ្ទង់ពុទ្រា ត្រួយត្រស់ត្រៀលស្វា ទ្រមូងទ្រមួច[53] ។ (...)* |
| **៣៦-ទានបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះវេស្សន្តរបានបំពេញដោយការឱ្យមហាទាន។ |
| **៣៧- ទារុណកថា**<br>អ. tragedy<br>បារ. tragédie ( f. ) | នាដកអក្សរសិល្ប៍មួយប្រភេទដែលកវី អ្នកនិពន្ធតាក់តែងជារឿងល្ខោន បង្កើតជាដំណើររឿងរឹកវរកម្សត់ព្រាត់ប្រាសធ្វើឱ្យអ្នកអាន អ្នកស្តាប់ញាប់ញ័រ រន្ធត់ចិត្ត អាណិតអាសូរតួអង្គទន់ខ្សោយ ដែលត្រូវតួអង្គខ្លាំងសង្កត់សង្កិន ធ្វើទុក្ខទារុណកម្មបំពារបំពាន។ |

[52] ពាក្យ «រលោះ» តាមវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ គ.ស. ១៩៦៧ គឺសរសេរ « **រលួស** »។

[53] ឧកញ៉ាកោសាធិបតី កៅ : ***រឿងក្រុងសុភមិត្រ***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥១៦, ទំព័រ៣៨។

| | |
|---|---|
| | ឧទាហរណ៍ : នៅក្នុងរឿង Romeo and Juliet របស់អ្នកនិពន្ធ សេកស្ពៀរ។ |
| **៣៨-ទារុណរស**<br>អ. tragic<br>បារ. tragique<br>(m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះបង្ហាញឱ្យឃើញនូវការជិះជាន់ ការព្យាបាទ ការរំលោភ ការធ្វើទុក្ខទោស ការដាក់ទណ្ឌកម្មយ៉ាងឃោរឃៅរបស់តួអង្គខ្លាំងទៅលើតួអង្គទន់ខ្សោយគ្មានសមត្ថភាពឱ្យរងទុក្ខភ័យរហូតបាត់បង់ជីវិតក៏សឹងមាន។<br>ឧទាហរណ៍ :<br>- នៅក្នុងរឿងកាកី ព្រះបាទព្រហ្មទត្ត បានដាក់ទណ្ឌកម្មនាងកាកី ដោយបណ្ដែតពោងពាយនាងក្នុងមហាសាគរ។<br>- នៅក្នុងរឿងទុំទាវ ការស្លាប់របស់ទុំទាវ តម្លៃទារុណស្ថិតនៅត្រង់ទុំស្លាប់គឺស្លាប់ដោយអំណាចអរជូននិងបក្សពួកចាប់យកទៅកាប់ចាក់ វាយប្រហាររហូតដល់ស្លាប់បាត់បង់ជីវិតយ៉ាងទារុណបំផុត។ |
| **៣៩-ទារុណហាសកថា**<br>អ.tragi-comedy<br>បារ. Tragi-comédie/ Mélodrame(m.) | នាដកអក្សរសិល្ប៍មួយប្រភេទដែលកវី អ្នកនិពន្ធតាក់តែងជារឿងល្ខោន ដោយបង្ហាញឱ្យឃើញនូវការឈឺចាប់ ព្រួយបារម្ភ កម្សត់ ព្រាត់ប្រាស អស់សង្ឃឹម លាយឡំនឹងការរំភើប សប្បាយរីករាយទៅតាមសកម្មភាពតួអង្គនៃរឿងធ្វើឱ្យអ្នកអាន អ្នកស្ដាប់មានអារម្មណ៍ញាប់ញ័ររន្ធត់ចិត្តអាណិតអាសូរផង និង មានអារម្មណ៍សប្បាយរីករាយផង។ |

| | |
|---|---|
| **៤០-ទំនាស់**<br>អ. conflict<br>បារ. conflit ( m. ) | ការប្រឈមគ្នារវាងកម្លាំងឬសភាវៈពីរផ្ទុយគ្នា។ ទំនាស់បង្កើតឱ្យដំណើររឿងមានភាពតានតឹងឬធូរស្រាល ធ្វើឱ្យអ្នកអានជក់ចិត្ត ដិតអារម្មណ៍ រំភើបសប្បាយ រីករាយ រំជួលចិត្ត។ ទំនាស់មានទំនាស់ក្នុងខ្លួន និង ទំនាស់ក្រៅខ្លួន។ |
| **៤១-ទំនាស់ក្នុងខ្លួន**<br>អ. inner conflict<br>បារ. conflit intérieur ( m. ) | ការប្រឈមរបស់តួអង្គណាម្នាក់នឹងអារម្មណ៍ ចិត្តរបស់ខ្លួនផ្ទាល់។ ទំនាស់ក្នុងខ្លួនច្រើនកើតមានឡើងនៅពេលតួអង្គជួបប្រទះនឹងបញ្ហាស្មុគស្មាញ។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ពេលព្រះវេស្សន្តរដាក់ទានជាលីក្រឹស្នាឱ្យទៅជូជក ព្រាហ្មណ៍ ពេលឃើញកូនត្រូវជូជកវាយធ្វើបាប ព្រះវេស្សន្តរក៏គិតថានឹងយកព្រះកៅទណ្ឌនូវព្រះខាន់សរថ្លា តាមទៅសម្លាប់ជូជកឱ្យក្ស័យជីវិតនឹងយកកូនមកវិញ។ |
| **៤២-ទំនាស់ក្រៅខ្លួន**<br>អ. outer conflict/ exterio conflict<br>បារ. conflit extérieur ( m. ) | ការប្រឈមមុខដាក់គ្នារវាងតួអង្គណាម្នាក់ជាមួយនឹងតួអង្គដទៃទៀត ឬ មជ្ឈដ្ឋានសង្គមខាងក្រៅ។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ព្រះបាទទសរថមានទំនាស់ជាមួយព្រះនាងកៃកេសីពីបញ្ហារាជបល្ល័ង្កដោយព្រះនាងកៃកេសីទាមទារឱ្យព្រះបាទទសរថគោរពពាក្យសច្ចៈ ដែលព្រះអង្គបានសន្យាថានឹងឱ្យព្រះភិរុតជាបុត្រព្រះនាងឡើងគ្រងរាជ្យ |

| | |
|---|---|
| | នៅពេលដែលព្រះអង្គច្បាំងឈ្នះព្រះអាទិត្យ។ តែក្រោយមក ព្រះបាទទសរថបែរជាចង់ឱ្យព្រះរាមគ្រងរាជ្យសម្បត្តិវិញ ដោយសំអាងលើប្រពៃណីក្សត្រថា បុត្រច្បងត្រូវសោយរាជ្យមុន។ |
| **៤៣-ទូន្មានកថា**<br>អ. advice<br>បារ. conseil (m.) | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធតាក់តែងជាអត្ថបទ(ភាគច្រើនជាពាក្យកាព្យ) សម្រាប់អប់រំណែនាំជននានុជន កុលបុត្រ កុលធីតាឱ្យដើរក្នុងផ្លូវល្អ មានសីលធម៌ គុណធម៌ ក្នុងជីវភាពរស់នៅ។<br>ឧទាហរណ៍ : នៅក្នុងច្បាប់ពាក្យចាស់ ច្បាប់ប្រុស ច្បាប់ស្រី...។ |
| **៤៤-នវកម្ម**<br>អ. innovation<br>បារ. innovation (f.) | ការកែប្រែថ្មី ការផ្លាស់ប្តូរថ្មី ការបញ្ចូលថ្មី ការកែច្នៃក្នុងអ្វីដែលមានពីមុនមក។<br>ឧទាហរណ៍ : រឿងរាមកេរ្តិ៍ខ្មែរ កើតចេញពីការកែច្នៃរឿងរាមាយណៈ។ |
| **៤៥- នាដករស**<br>អ. theatrical values<br>បារ. valeurs théâtrales | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ដោយកវី អ្នកនិពន្ធចេះតុបតែងរៀបរៀងដំណើររឿងឱ្យមានឆាក ឈុតដើម្បីសម្តែងជាសិល្បៈទស្សនីយភាព។ |
| **៤៦-នាដកអក្សរសិល្ប៍** | អត្ថបទអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធតែងឡើងដោយរៀបចំឱ្យមានឈុតនិងឆាក សម្រាប់យកទៅសម្តែងសិល្បៈល្ខោន។ |

| | |
|---|---|
| អ. literature of theatrical genre<br>បារ. littérature du genre théatral | នៅក្នុងនាដកអក្សរសិល្ប៍ មាន នាដ្យកថា ហាស-កថា ទារុណកថា។ |
| **៤៧-នាដ្យកថា** | នាដកអក្សរសិល្ប៍មួយប្រភេទដែលកវី អ្នកនិពន្ធ តាក់តែងជារឿងល្ខោន ដោយលើកយករឿងវិបត្តិ ទំនាស់របស់មនុស្សក្នុងសង្គមនៃសម័យកាល ណាមួយ ទោះជារឿងវិបត្តិទាំងនោះពិតក្តី មិនពិត ក្តីមកធ្វើជាប្រធានរឿង ដោយបង្កើតបរិយាកាស តឹងតែង ធូរស្រាល ជ័យជម្នះ បរាជ័យ ស្លាប់រស់ កម្សត់ ភិតភ័យ តក់ស្លុត កំប្លែង។<br>ឧទាហរណ៍ : រឿងសំបុកឥតមេបា របស់លោក ហង្ស ធន់ហាក់។ |
| **៤៨- នាដ្យរស**<br>អ. dramatic<br>បារ. Dramatique (m) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធចេះបង្ហាញទំនាស់វិបត្តិប្រឆាំងគ្នានៃតួអង្គ បដិបក្ខ នៅក្នុងដំណើររឿង ជួនកាលបង្ហាញពីភាព តានតឹង ភាពធូរស្រាល ទុក្ខសោក ដែលនាំឱ្យអ្នក អាន អ្នកស្តាប់ កម្សត់ ក្តុកក្តួល រន្ធត់ អាណិត អាសូរ...។<br>ឧទាហរណ៍ : នៅក្នុងរឿងផ្កាស្រពោន សកម្មភាព ទំនាស់វិបត្តិរបស់នាងវិធាវីនិងយាយនួនជាម្តាយ។ |
| **៤៩-និម្មិត** | បង្កើតដោយឫទ្ធិ កាឡាខ្លួន ដំណែងខ្លួន។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក |

| | |
|---|---|
| | ព្រះឥន្ទ្រនិម្មិតខ្លួនជាព្រាហ្មណ៍មកសុំនាងមទ្រីពីព្រះវេស្សន្តរធ្វើជាភរិយា។ |
| **៥០-និមិត្តរូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគដែលរំលេចឱ្យឃើញអំពីសញ្ញាភាព។<br>**ឧ.** រឿងចចក និង កូនចៀម គឺជាសញ្ញាភាពតំណាងសភាវៈខ្លាំង និង សភាវៈទន់ខ្សោយ។ |
| **៥១-និយមេតិវិធី**<br>អ.enjambement<br>បារ.enjambement<br>( m. ) | វិធីតែងកាព្យមួយបែបដែលកវីប្រើដោយធ្វើឱ្យព្យាង្គនៃពាក្យនៅចុងឃ្លាណាមួយទៅលោតទៅជាប់នឹងព្យាង្គដើមនៃឃ្លាបន្ទាប់ដើម្បីបន្តគំនិតកុំឱ្យដាច់គ្នា និងធ្វើឱ្យវិធីសាស្ត្រតែងកំណាព្យមានលក្ខណៈត្រឹមត្រូវក្នុងការរៀបចំឃ្លាឱ្យគ្រប់ចំនួនព្យាង្គ។<br>ឧ. *(...)ពាក្យពោលពុំពី- រោះរាប់នៃនី-*<br>*ទានតាមបទបា- លីលោកដើមអាទ៏*<br>*ត្បិតជាតិប្រាជ្ញា ចេះចងសាសនា*<br>*ពុំសូវគ្គួរសម*[54] ។*(...)* |
| **៥២- នេក្ខម្មបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះតេមិយបានបំពេញដោយការចេញទៅសាងព្រះផ្នួស។ |

[54] ព្រះអង្គ ឌួង : ***រឿង កាកី***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៤១, គ.ស. ១៩៩៧, ទំព័រ២។

| | |
|---|---|
| **៥៣- បដិពិម្ពកថា**<br>អ. portrait<br>បារ. portrait( m. ) | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធរៀបរាប់ ពណ៌នាពីរូបលក្ខណៈ (ខាងក្នុង និង/ឬខាងក្រៅ)របស់មនុស្ស(មនុស្សពិតប្រាកដ ឬ មនុស្សក្នុងរូបគំនូរ ក្នុងរូបថត រូបចម្លាក់ រូបសំណាក...។<br>ឧទាហរណ៍ :<br>- ការរៀបរាប់ពីព្រះបាទជ័យវរ្ម័នទី៧,<br>- ការរៀបរាប់ពីក្រឡាហោមគង់...។ |
| **៥៤- បារមី**<br>អ. perfection<br>បារ. Perfection ( f. ) | គុណជាតិដ៏ល្អដែលនាំឱ្យបានសម្រេចដល់ត្រើយគឺព្រះនិព្វាន។ |
| **៥៥-បុនរុត្តិវិធី**<br>អ. repetition<br>បារ. répétition( f. ) | វិធីតែងកាព្យដែលធ្វើឱ្យផ្ទួនពាក្យសម្តីឬផ្ទួនមតិដដែលៗ ដែលកវី អ្នកនិពន្ធប្រើ ដើម្បីធ្វើឱ្យមានចលនា សកម្មភាពរបស់តួអង្គកាន់តែជាក់ស្តែងឡើង។ បុនរុត្តិវិធីចែកជា៤ប្រភេទគឺ៖<br>១- ការផ្ទួនសូរស្រៈ និង ព្យញ្ជនៈ។<br>ឧ. *(...)ខុនខែងខឹងខួនខឹងខាំ មាត់ភ្លាងង៉ាំង៉ុាំ ត្របាសត្របែងផ្លែងកាំ*[55] *។(...)*<br>២- វិធីផ្ទួនពាក្យសម្គាល់លក្ខណៈ ដោយប្រើគុណនាមផ្ទួនគ្នា។ |

[55] អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស : ***រឿងរាមកេរ្តិ៍ ខ្មែរ៣***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, គ.ស. ១៩៩៥, ទំព័រ២០។

| | |
|---|---|
| | ឧ. *(...) ចិត្តគិតថាអេះ នាងនេះល្អម្ល៉េះ*<br>*នេះហៅល្អលន់ ត្រកាលឃើញម្តង*<br>*នេះហោងហៅបុណ្យ គ្មានស្រីណាប៉ុន*<br>*ល្អពន់ប្រមាណ*[56] ។ *(...)*<br>៣- វិធីផ្ទួនពាក្យសម្គាល់នូវសកម្មភាពឬចលនា។<br>ឧ. *(...) ស្តេចជំស្តេចជាន់ស្តេចជាក់*<br>*ស្តេចប្រទានស្តេចចាក់ ស្តេចហែក*<br>*រុះរាយបោះបង់*[57] ។ *(...)*<br>៤- វិធីផ្ទួនគំនិតនិងបញ្ហាដដែលៗ។<br>ឧ. *(...) កន្លង់មាសមង្គលថ្លៃ ឆ្ងៀលឆ្ងាត់វិលវៃ*<br>*ទ្រហឹងខ្វាយខ្វរ។*<br>*កន្លង់ត្រេចត្រង់កេសរ បងត្រេចចេរចរ*<br>*ត្រង់ឋានប្អូនរ័តន៍។*<br>*កន្លង់មាសមង្គលក្លាត់ ហិចហើរប្រវាត់*<br>*គ្រប់ដងសព្វសា។*<br>*កន្លង់ត្រេចត្រង់បុប្ផា បងត្រេលីលា*<br>*ដល់ឋានប្អូនស្រី។*<br>*កន្លង់មាសមង្គលថ្លៃ ប្រវាត់ឯព្វ*<br>*វេហាស៍នភី។* |

[56] ព្រះអង្គ ឌួង : ***រឿងកាកី***, ការផ្សាយ របស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៤១, គ.ស.១៩៩៧, ទំព័រ១៥។

[57] អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស ***: រឿងរាមកេរ្តិ៍ ខ្សែ៤***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ ព.ស. ២៥៣៩, គ.ស. ១៩៩៥, ទំព័រ៣២។

| | |
|---|---|
| | *កន្លង់ត្រេចត្រង់រកភ្ញី បងត្រេចរកស្រី ស្រីមាសបវរ*[58] ។ (...) |
| **៥៦-បុព្វនិមិត្ត** | ហេតុភេទ ប្រផ្នូល គ្រឿងសម្គាល់ ដែលនាំបណ្ដាលឱ្យឃើញមុន។<br>ឧទាហរណ៍ : ព្រះនាងសិរិមហាមាយាទ្រង់យល់បុព្វនិមិត្តឃើញថា មានដំរីសចុះមកជ្រៀតចូលក្នុងព្រះវរកាយព្រះនាង។ |
| **៥៧-បច្ចេករស**<br>អ. technical values<br>បារ. valeurs techniques (f.) | ផ្នែកមួយនៃអត្ថរស ដែលកវី អ្នកនិពន្ធប្រើដើម្បីជាវិធីពិសេសក្នុងការតែងនិពន្ធដើម្បីធ្វើឱ្យអត្ថបទមានសម្រស់សម្រាប់ផ្នែកឬប្រភេទនៃរឿងនីមួយៗ។ ក្នុងបច្ចេករស មាន កាព្យរស ប្រលោមរស នាដករស។ |
| **៥៨- បញ្ញាបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ដែលព្រះពោធិសត្វក្នុងជាតិជាព្រះមហោសថបានបំពេញដោយការប្រើបញ្ញាដើម្បីដោះស្រាយបញ្ហា។ |
| **៥៩- ប្រលោមរស**<br>អ. romantic<br>បារ. romantique (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ពិសេសអ្នកនិពន្ធ ប្រលោមលោកចេះរៀបរៀង តុបតែងរឿងរបស់ខ្លួនតាមរយៈការបង្កើតដំណើររឿង សកម្មភាពនៃតួអង្គឱ្យមានស្នេហា ការផ្សងព្រេង... ប្រកបដោយលក្ខណៈអណ្ដែតអណ្ដូង សោកសង្រេង សប្បាយ កម្សត់... ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ មានអារម្មណ៍រំភើប សង្វេគ |

[58] លាង ហាប់អាន : ***ព្រះរាជសម្ភារអ្នកនិពន្ធខ្មែរ***, បណ្ណាគារ សេង-ងួន-ហួត, បោះពុម្ពលើកទី៣, ភ្នំពេញ, ព.ស. ២៥០៩, គ.ស. ១៩៦៦, ទំព័រ៥៨។

សប្បាយ ព្រួយ ជាមួយតួអង្គនិងដំណើររឿង។

ឧ. *(...)ឱ ! ទាវអើយទៅពីព្រោះម្ដាយ*

*មិនដឹងប្រែក្លាយមានប្រើស្មៀត*
*ទាវអើយទុក្ខទុំធំចង្អៀត*
*ស្ពាត់ស្ពៀតដូចភ្នំរលំលើ។*
*ទាវអើយទាវស្រីប្រណីបង*
*មែនពិតជាម្ដងទើបហ៊ានធ្វើ*
*អក្ខរីទាវស្រីប្អូនចាត់ប្រើ*
*ដំណឹងដំណើរឱ្យឆាប់ដល់។*
*ប្អូនអើយទុក្ខបងម្ដងហ្នឹងធ្ងន់*
*ពេញពៀបទូរន់សូន្យស្រងល់*
*ស្រងាត់ដូចហាក់អកុសល*
*ខ្វាយខ្វល់ឡើនឡង់អង្គរាយមាយ។*
*ទាវអើយប្រសិនខ្លួនបានគេ*
*បងនៅទទេមិនឈប់ងាយ*
*ស៊ូបង់ជីវិតដូចសឹកនាយ*
*ស្លាប់ក្នុងបន្ទាយចំណោមធំ[59] ។(...)*

ឧទាហរណ៍ : នៅក្នុងរឿងផ្កាស្រពោន ការធ្វើដំណើរតាមរថភ្លើងរបស់ប៊ុនធឿនទៅស្រុកកំណើតដ៏កណ្ដោចកណ្ដែងម្នាក់ឯងក្នុងចំណោមមិត្តភក្តិដ៏សប្បាយ។

*(...)ពួកសិស្សវិទ្យាល័យ... យោលរិតតែញឹក*
*ញាប់ឡើង [60]។(...)*

[59] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ***,ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥១៤, ទំព័រ៨៧-៨៨។

[60] នូ ហាច : ***រឿងផ្កាស្រពោន,*** អគារបោះពុម្ពផ្សាយ វប្បធម៌, បោះពុម្ពឡើងវិញលើកទី១, ភ្នំពេញ, ឆ្នាំ១៩៨៩, ទំព័រ២-៦។

| | |
|---|---|
| **៦០- ពាហិរទាន** | ទានខាងក្រៅខ្លួន មានទ្រព្យសម្បត្តិ លុយកាក់ ឬរបស់របរផ្សេងៗ។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ព្រះវេស្សន្តរបានឱ្យទានដល់ស្មូមយាចក តាំងពីទ្រព្យសម្បត្តិរបស់របរប្រើប្រាស់ប្រចាំថ្ងៃ រហូតដល់ដំរីបច្ច័យនាគេន្ទ្រដែលជាដំរីមង្គលរបស់ប្រទេស។ |
| **៦១- ពិពណ៌នាកថា**<br>អ. descriptive genre<br>បារ. genre descriptif | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធរៀបរាប់ អធិប្បាយឱ្យអ្នកអាន អ្នកស្ដាប់បានឃើញពីលក្ខណៈខាងក្នុង ខាងក្រៅ គុណសម្បត្តិ គុណវិបត្តិ សារប្រយោជន៍ រូបលក្ខណៈ ចរិយា សកម្មភាព មុខងារ នៃវត្ថុ មនុស្ស សត្វ រុក្ខជាតិ... និងការថែរក្សាវត្ថុ មនុស្ស សត្វ រុក្ខជាតិទាំងនោះ។<br>ឧទាហរណ៍ :<br>- ពិពណ៌នាអំពីរូបសម្ផស្សរបស់មនុស្ស,<br>- ពិពណ៌នាអំពីដើមឈើ...។ |
| **៦២- ព្រះពោធិសត្វ** | អ្នកដែលកំពុងបំពេញបារមី ដើម្បីត្រាស់ដឹងជាព្រះពុទ្ធ។ |
| **៦៣-មនោ/បញ្ញារូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគដែលរំលេចឱ្យដឹងដោយបញ្ញាញាណ ការពិចារណា ការពិភាក្សា ការសង្កេត ការត្រិះរិះ។ |

| | |
|---|---|
| | ឧ. *(...) ស្តេចគិតសង្វេគអនិច្ចា រូបំអនត្តា*<br>*ឥតខ្លឹមសារសូន្យសោះ។*<br>*សង្ខារបណ្តាទោសស្មោះ ឥតត្រើយ*<br>*ឥតកោះពំនាក់ពំនឹងរូបបាន*[61] *។(...)* |
| **៦៤- មហត្តរស**<br>អ. grandiose<br>បារ. grandiose | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះរៀបរាប់ពីរូបរាង មហិទ្ធិឫទ្ធិ អំណាចរបស់តួអង្គណាមួយ ធ្វើឱ្យមានលក្ខណៈសម្បើមអស្ចារ្យ។<br>ឧទាហរណ៍: នៅក្នុងរឿងរាមកេរ្តិ៍ នៅពេលហនុមានទៅរកឱសថព្យាបាលព្រះលក្ស្មណ៍ ហនុមានពុំស្គាល់ដើមថ្នាំ ក៏លើកភ្នំទាំងមូលមកតែម្តង<br>ឧ.*(...)បានមូត្រឧសភរាជហោះខ្មី ទៅយកបុស្សរី*<br>*កេសរបទុមសោភា។*<br>*រីព្រះសង្គរណើនោះណា ហនុមានមហិមា*<br>*ពុំស្គាល់នៃដើមថ្នាំនោះ។*<br>*ជ្រងជ្រួយស្ទួយទាំងភ្នំហោះ នូវកម្លាំងនោះផ្ដោះ*<br>*រឹងដល់ពិភេកភរាជា។*<br>*ពិភេកទទួលទិព្វឱសថា បានគ្រប់តំរ៉ា*[62]<br>*សម្តែងនូវគុណថ្នាំនោះ។* |

[61] ឧកញ៉ាកោសាធិបតី កៅ : **ក្រុងសុភមិត្រ** , ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥១៦, ទំព័រ ១២។

[62] ពាក្យ ‹‹តំរ៉ា›› តាមវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ , គ.ស. ១៩៦៧ គឺសរសេរ ‹‹ **តម្រា** ››។

| | |
|---|---|
| | *ហនុមានស្រេចលើកភ្នំនោះ វិលវឹងទៅផ្ដោះ<br>ក៏លុះនៃស្ថានដើមនាយ* [63]។*(...)* |
| **៦៥- មេត្តាបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះសុវណ្ណសាមបានបំពេញដោយការផ្សាយមេត្តាធម៌។ |
| **៦៦- រចនាបថ**<br>អ. style<br>បារ. style (m.) | បែបផែនដោយឡែកៗ ដែលអ្នកនិពន្ធ សិល្បករ វិចិត្រករ យកមកប្រើប្រាស់ដើម្បីនិពន្ធ រចនា រៀបរាប់និងនិយាយដោយបញ្ចេញសំនួនវោហារសេចក្ដីគំនិត ទស្សនៈផ្ទាល់ខ្លួន ក្រោមរូបភាពជាអត្ថន័យ (គំនិត)និងអត្ថរូប(ភាសា)ទៅតាមសម័យកាលណាមួយច្បាស់លាស់។ |
| **៦៧-រូបារម្មណ៍** | រូបដែលកើតឡើងតាមរយៈអារម្មណ៍, អារម្មណ៍ដែលនាំឱ្យកើតជារូប។<br>ឧ.*(...)មកដល់វាលវែងត្រែងដួលដុះ<br>ផ្កាសត្រសុសផ្លេកភ្លឺថ្លា<br>ដូចរូបសម្បុរពណ៌កនិដ្ឋា<br>ដូចផ្កាត្រែងត្រស់ស្រណោះពេក។<br>មៀងមើលទឹកជ្រៅស្មៅត្រកៀត<br>ចិត្តបងចង្អៀតវឹងវិវេក<br>ត្រកួនដូចខ្លួនបងឈប់ដេក<br>ឈប់ដោយម្លប់មែកត្របែកព្រៃ។* |

[63] អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស, ***រឿងរាមកេរ្តិ៍ ខ្មែរ***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥៣៩, គ.ស.១៩៩៥, ទំព័រ២០។

| | |
|---|---|
| | *ឃាប្លងដូចបងភ្លាត់ឃ្លាតឆ្ងាយ*<br>*ព្រៃព្រួយមកអាយយូរឃ្លាតឃ្លៃ*<br>*ស្រងេះស្រងូតរហូតវៃ*<br>*ម៉្លេះសមប្អូនភ័យមមៃគិត* [64] *។(...)* |
| **៦៨-រូបារូបិយារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយ ដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគ ដែលរំលេចឱ្យដឹងអំពីជីវរូបារម្មណ៍ ឬ ឧបមារូបារម្មណ៍។<br>ឧ. - ជីវរូបារម្មណ៍ដែលក្លាយទៅជារូបារូបិយារម្មណ៍៖<br>*(...)បុប្ផាមែនហើយ មនុស្សបេះក្លៀកកើយ*<br>*ចិតស្ងួនសន្ធំ ស្រាប់តែមច្ចុរាជ*<br>*ហូរសោចសាយរំ- ពេចមកពីភ្នំ*<br>*ហូរទាញមនុស្សទៅ ។(...)*<br>- ឧបមានរូបារម្មណ៍ដែលក្លាយទៅជារូបិយារម្មណ៍៖<br>*(...)ក្តិបប៉ិចលេចពីទងវា ខ្ចីចាស់ផលា*<br>*ស្រគាលហើយទុំទៀងហោង។*<br>*ក្សិណធ្លាក់ចុះចាកលែងទង*<br>*ដូចកំណើតសត្វផង*<br>*អន្ទោលអន្ទាក់ភពស្ថាន* [65] *។(...)* |

---

[64] ព្រះបទុមត្ថេរ សោម ៖ ***រឿង ទុំទាវ***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥១៤, គ.ស.១៩៧១ ទំព័រ៤០

[65] អ្នកអង្គម្ចាស់ វឌ្ឍធាយាវង្ស : ***រាមកេរ្តិ៍ខ្សែ២***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, គ.ស. ១៩៩៥ ទំព័រ ៤២។

| | |
|---|---|
| **៦៩-លក្ខណៈជាតិ**<br>អ. national character<br>បារ. caractère national ( m. ) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធលើកយកតម្លៃពិសេសរបស់ជាតិមកបង្ហាញក្នុងដំណើររឿងដែលទាក់ទងនឹងសីលធម៌ ជំនឿ ទំនៀមទម្លាប់ សាសនា និង អ្វីៗដែលជាអត្តសញ្ញាណជាតិ ដើម្បីបណ្ដុះគំនិតស្រឡាញ់ អភិរក្ស ការពារ អភិវឌ្ឍ អរិយធម៌របស់ជាតិ។ |
| **៧០-លក្ខណៈប្រវត្តិសាស្ត្រ**<br>អ. historical character<br>បារ. caractère historique ( m. ) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធលើកយកដំណើររឿងទាក់ទងនឹងសម័យកាលខ្លះ ព្រឹត្តិការណ៍ផ្សេងៗខ្លះដែលមានក្នុងប្រវត្តិសាស្ត្រមកបង្ហាញ។<br>ឧទាហរណ៍ :<br>- នៅក្នុងរឿងទុំទាវ តាមប្រវត្តិសាស្ត្រ រឿងនេះកើតនៅសម័យលង្វែក។<br>- នៅក្នុងរឿងភូមិតិរច្ឆាន តាមប្រវត្តិសាស្ត្រ រឿងនេះកើតនៅសម័យអាណានិគមបារាំង។ |
| **៧១-លក្ខណៈមនុស្ស**<br>អ. human character<br>បារ. caractère humain ( m. ) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយនៅក្នុងដំណើររឿង ទោះបីអ្នកនិពន្ធលើកយកតួអង្គសត្វក្ដី ធម្មជាតិក្ដី តួអង្គអច្ឆរិយៈក្ដី ក៏តួអង្គទាំងនោះនៅតែជាតំណាងមនុស្សនៅក្នុងសង្គម។ |

| | |
|---|---|
| | ឧទាហរណ៍ : តួអង្គក្នុងអក្សរសិល្ប៍ខ្មែរ<br>-ទន្សាយ តំណាងមនុស្សមានបញ្ញា ស្រទន់ យុត្តិធម៌...។<br>-ខ្លា ក្រពើ តំណាងមនុស្សកាចសាហាវ រមិលគុណ...។<br>-ក្រុងរាពណ៍ តំណាងមនុស្សអាត្មានិយម ផ្តាច់ការ អត្តនោម័តិ...។<br>-ហនុមាន តំណាងមនុស្សមានសមត្ថភាព ស្មោះត្រង់...។ |
| **៧២-លក្ខណៈវណ្ណៈ**<br>អ. cast character<br>បារ. caractère de classe sociale (m.) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះ អ្នកនិពន្ធលើកយកការតស៊ូវណ្ណៈ ការការពារឧត្តមគតិ ចរិត គោលបំណងនៃវណ្ណៈណាមួយមកបង្ហាញ។<br>ឧទាហរណ៍ : នៅក្នុងរឿងធនញ្ជ័យ អ្នកនិពន្ធបង្ហាញពីបញ្ញាជនតំណាងវណ្ណៈថ្នាក់ក្រោមដែលប្រឆាំងនឹងវណ្ណៈថ្នាក់លើ។ |
| **៧៣-លក្ខណៈសង្គម**<br>អ. social character<br>បារ. caractère social (m.) | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈនោះអ្នកនិពន្ធលើកយកបញ្ហាសង្គមមនុស្សក្នុងសម័យកាលណាមួយមកបង្ហាញ ចោទនិងដោះស្រាយក្នុងដំណើររឿង។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវបង្ហាញពីលក្ខណៈសង្គមដែលប្រកាន់ប្រពៃណី‹‹នំមិនធំជាងនាឡិ››...។ |

| | |
|---|---|
| **៧៤-លក្ខណៈអក្សរសិល្ប៍**<br>អ. literature character<br>បារ. caractère littéraire ( m. ) | បញ្ហាផ្សេងៗជាគ្រឿងសម្គាល់ចរិតលក្ខណៈទាំងឡាយដែលមាននៅក្នុងអក្សរសិល្ប៍ ដូចជា៖ លក្ខណៈមនុស្ស លក្ខណៈសង្គម លក្ខណៈប្រវត្តិសាស្ត្រ លក្ខណៈវណ្ណៈ លក្ខណៈជាតិ លក្ខណៈអន្តរជាតិ។ |
| **៧៥-លក្ខណៈអន្តរជាតិ**<br>អ. international character<br>បារ. caractère international | លក្ខណៈអក្សរសិល្ប៍មួយប្រភេទដែលតាមរយៈអ្នកនិពន្ធបង្ហាញពីតម្លៃសាកលនៃស្នាដៃនិពន្ធណាមួយ។<br>ឧទាហរណ៍ :<br>- នៅក្នុងរឿង Romeo and Juliet របស់អ្នកនិពន្ធ Shakespeare។<br>- នៅក្នុងរឿងរាមាយណៈ របស់អ្នកនិពន្ធវាល្មិកិ។ |
| **៧៦-លោកិយសច្ចៈ** | ព្រឹត្តិការណ៍ ហេតុការណ៍ជាក់ស្តែងមានក្នុងសង្គមមនុស្សដែលអ្នកនិពន្ធលើកយកមកបង្ហាញនៅក្នុងស្នាដៃ។<br>ឧទាហរណ៍ : នៅក្នុងរឿងភូមិតិរច្ឆាន ព្រឹត្តិការណ៍បាតុកម្មរបស់ប្រជាជននៅថ្ងៃទី១៨ មេសា ឆ្នាំ ១៩២៥។ |
| **៧៧-ល្បើកកថា**<br>អ. fable<br>បារ. fable ( f. ) | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធតាក់តែងជារឿងនិទានដោយលើកយកគុណវិបត្តិមនុស្សនៅក្នុងសង្គមមកធ្វើជាប្រធានរឿង។ |

| | |
|---|---|
| | តួអង្គនៅក្នុងល្បើកកថាភាគច្រើនជាតួអង្គសត្វ ដែលជានិមិត្តរូបឬគំរូមនុស្សប្រភេទណាមួយក្នុងសង្គម។ ល្បើកកថាឆ្លុះបញ្ចាំងពីជីវភាព ទំនៀមទម្លាប់ បែបបទរស់នៅរបស់មនុស្ស និង បង្ហាញពីយុទ្ធវិធីផ្សេងៗក្នុងការដោះស្រាយបញ្ហាជីវិត។<br>ឧទាហរណ៍ :<br>- ល្បើកជុំចនិងត្រី របស់ហ្លួងវិសេសអក្ខរាជ្ញ,<br>- គតិលោក របស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទ។ |
| **៧៨- វឌ្ឍមានវិធី**<br>អ. progression<br>បារ. progression (f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ធ្វើឱ្យដំណើររឿងមានការរីកចម្រើនពីធូរស្រាលទៅតានតឹងឬពីតានតឹងទៅធូរស្រាលវិញ។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ស្នេហាទុំទាវចេញដំណើរពីភាពធម្មតាទៅរកភាពតានតឹងបន្តិចម្តងៗរហូតបណ្តាលឱ្យតួអង្គទាំងពីរស្លាប់។<br>ឧទាហរណ៍ : នៅក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ដំណើរជីវិតរបស់សម ចេញពីភាពតានតឹងខាងដើមរឿង ហើយធូរស្រាលនៅចុងបញ្ចប់នៃរឿង។ |
| **៧៩- វណ្ណនាកថា**<br>អ. narrative genre | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធសរសេរ អធិប្បាយរៀបរាប់ឡើងវិញនូវដំណើររឿងរ៉ាវជាក់ស្តែងនៃជីវភាពសង្គម (ពិធីបុណ្យ |

| | |
|---|---|
| បារ. genre narratif | ផ្សេងៗ ការធ្វើដំណើរ ឧបទ្ទវហេតុ ទំនាក់ទំនងរវាងគ្រួសារ រវាងខ្លួនឯង និង អ្នកដទៃ) ទោះជាដំណើររឿងទាំងនោះកន្លងផុតទៅក្ដីឬកំពុងប្រព្រឹត្តទៅក្ដីមករៀបរាប់ដើម្បីឱ្យអ្នកអានបានដឹង បានយល់ហាក់ឃើញនឹងភ្នែកផ្ទាល់។<br>ឧទាហរណ៍ : វណ្ណនាកថាស្ដីពី *បុណ្យផ្កា បុណ្យកឋិន ពិធីរៀបការ ការធ្វើដំណើរ ការទៅលេងស្រុកកំណើត ខ្យល់ព្យុះ ទឹកជំនន់ រញ្ជួយដី ...*។ |
| **៨០- វណ្ណនាវិធី**<br>អ. narration<br>បារ. narration (f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធប្រើដោយលើកយកតួអង្គមនុស្ស សត្វ រឿង ចម្បាំង ធម្មជាតិឬទេសភាពមកនិទានរៀបរាប់ឱ្យឃើញច្បាស់ដូចបានឃើញនឹងភ្នែកផ្ទាល់។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ការរៀបរាប់អំពីចម្បាំងរវាងទូភីនិងពាលី<br>*(...)សឹងសាញសោះសាដ៏ទីទៃ ទូភីនិរភ័យ*<br>*លលេលលាំងរួសរង់។*<br>*ធ្មៀលធ្មឹសធរណីជ្រួយជ្រង វ៉ៃវាត់ឈ្មៀងឈ្មង*<br>*រលើងរលំព្រឹក្សា។*<br>*ធ្លាយធ្លាក់បែកបាក់បព្វតា ងើយងួយងរងា*<br>*រលោស់ស្រួចស្រិង្គ[66]ម៉ាយមៀង។* |

[66] ពាក្យ «ស្រិង្គ» នេះ ក្នុងវចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧-៦៨ សរសេរ «ស្រឹង្គ»។

| | |
|---|---|
| | *វិលវេះវៃវាត់ខ្លាំងខ្លៀង ស្ទុះស្ទះឆាបឆៀង*<br>*ក្រឡេកក្រឡាស់ហាក់ហោះ។*<br>*ក្រុងពាលីលុះដាញឆ្ដោះ ខ្វាត់ដូចគេបោះ*<br>*ពុំដិតដល់អង្គមហិង្សា។*<br>*ស្នែងស្និទ្ធពីរពេជ្រផ្លាញផ្លា ពះលើសិល្ប៍ពាលី*<br>*រាជពុំអាចបីនូវមុត។*<br>*ដូចលំពែងពេជ្រមុតបីប្រាកដ*<br>*អ្នកចាក់ដ៏ចំហុតទំលុះ*[67]<br>*លើមហាពេជ្រឯង។*<br>*ព្រះខ័នពេជ្រពះពេជ្រស្នែង ពេជ្រនូវពេជ្រឯង*<br>*ប្រក្អួតប្រកឹងបេស្ដា។*<br>*ពាលីវៃវេះដ៏វេហាស៍ ទូកីរងរា*<br>*ទន្ទាំទន្ទួយវិលវាត់*[68] ។*(...)*<br><br>២. *(...)រទេះភ្លើងបោលលឿនដូចព្យុះកាត់ព្រៃខ្លុង និងព្រេច*[69] ។*(...)* |
| **៨១- វប្បធម៌**<br>អ. culture | មែកធាងនៃអរិយធម៌ដែលទាក់ទងនឹងការបណ្ដុះបណ្ដាលចំណេះវិជ្ជាប្រាជ្ញាស្មារតី ទំនៀមទម្លាប់ |

[67] ពាក្យ‹‹ទំលុះ›› នៅទីនេះសរសេរខុសពីវចនានុក្រខ្មែរ បោះពុម្ព គ្រាទី៥ ឆ្នាំ១៩៦៧-៦៨។ ពាក្យនេះត្រូវសរសេរ‹‹ទម្លុះ›› វិញ។

[68] អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស : ***រឿងរាមកេរ្តិ៍ ខ្សែ៤***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩ គ.ស. ១៩៩៥ ទំព័រ៥៥។

[69] នូ ហាច : ***រឿង ផ្កាស្រពោន***, ការផ្សាយពីក្រសួងសិក្សាធិការជាតិ, រោងពុម្ពរស្មី, ភ្នំពេញ, ឆ្នាំ១៩៦០,ទំព័រ ១។

| | |
|---|---|
| បារ. culture ( f. ) | សិល្បៈ វិទ្យាសាស្ត្រ អក្សរសាស្ត្រ... ឱ្យបានលូតលាស់រីកចម្រើន។<br>**<u>សង្កេត</u>** ៖ បើយើងមិនបែងចែកវប្បធម៌ឱ្យដាច់ពីសង្គមធម៌ យើងអាចឱ្យនិយមន័យតាមគណៈកម្មការវប្បធម៌និងវិចិត្រសិល្បៈដូចនេះ ការបណ្ដុះចំណេះវិជ្ជា ប្រាជ្ញា ស្មារតី និងរបៀបរស់នៅរបស់មនុស្សឱ្យបានលូតលាស់ចម្រើនដើម្បីសម្របសម្រួលទៅនឹងបរិស្ថាននិងការអភិវឌ្ឍសង្គមដោយវិទ្យាសាស្ត្របូដោយសិល្បៈផ្សេងៗ ជាដើម។ |
| **៨២-វិភាគតួអង្គ** | ការរកឱ្យឃើញនូវលក្ខណសម្បត្តិរបស់តួអង្គតាមរយៈសកម្មភាព កាយវិការ សម្លៀកបំពាក់របស់តួអង្គផ្ទាល់ ឬ តាមរយៈពាក្យសម្ដីតួអង្គដទៃទៀត។ |
| **៨៣-វិលោមត្ថវិធី**<br>អ. inversion<br>បារ. inversion<br>( f. ) | វិធីតែងនិពន្ធមួយបែបដែលកវី អ្នកនិពន្ធប្រើឃ្លាល្បះដោយផ្លាស់ត្រឡប់ពាក្យ ដើម្បីឱ្យអ្នកអាន អ្នកស្ដាប់ចាប់អារម្មណ៍។<br>ឧទាហរណ៍ : ( ... ) *ដែកដុលរនាំង **តូចបួនជញ្ជាំងធំសោអស្ចារ្យ***[70] ។( ... ) |
| **៨៤- វិសិដ្ឋរស**<br>អ. sublime<br>បារ. sublime | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ដោយកវីអ្នកនិពន្ធ ចេះបង្ហាញនូវសកម្មភាពដ៏អស្ចារ្យរបស់តួអង្គក្នុងការបំពេញកិច្ចការអ្វីមួយ ដែលមនុស្ស |

[70] កេង វ៉ាន់សាក់ *: **គុកកាមកិលេស***, ភ្នំពេញ, គ.ស. [?] ទំព័រ១។

| | |
|---|---|
| | លោកធម្មតានៅក្នុងសង្គមពុំអាចធ្វើដូចឡើយ។ ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ការធ្វើទានរបស់ព្រះវេស្សន្តរ។ |
| **៨៥- វិសេសរស**<br>អ. particular values<br>បារ. valeurs particulières | ផ្នែកមួយនៃអត្ថរសដែលកវី អ្នកនិពន្ធបង្កើតឡើងយ៉ាងប៉ិនប្រសប់ក្នុងការតែងនិពន្ធរឿងប្រលោមលោក ល្ខោន កំណាព្យ រឿងព្រេង រឿងល្បើក ឬអត្ថបទផ្សេងៗ។ ក្នុងវិសេសរសមាន សុន្ទររស វិហាសរូបរស មហត្ថរស វិសិដ្ឋរស វីររស ទារុណរស ហាសរស ទស្សនីយរស។ |
| **៨៦- វិហាសរូបរស**<br>អ. grotesque<br>បារ.grotesque(m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ បេះពណ៌នារូបអាក្រក់ សកម្មភាពចម្លែករបស់តួអង្គដើម្បីបង្កើតសោភ័ណ។<br>ឧទាហរណ៍ : នៅក្នុងរឿងមហាវេស្សន្តរជាតក ការពណ៌នារូបអាក្រក់របស់តាជូជក ៖<br>*(...)មានព្រាហ្មណ៍ម្នាក់ឈ្មោះជូជកព្រឹទ្ធាចារ្យរូបអន្ធការ ស្គមច្រដោងច្រមុះកោង ទ្រូងសឹងតែឆ្អឹង សក់រឹងក្រញាង ពោះធំកំប៉ោង លោងសំពៀតដំបារត្រចៀកយុរយារក្រាស់ដូចឃ្លង់ភ្លើង ជើងកោងដូចជើងសេក ភ្នែកស្រលៀងស្រលើ សាច់ពកដូចគេផ្ញើ រដិបរដុបយុរយារប៉ុនផ្លែក្រសាំង ផ្លែសម៉ផ្ដេញស ក្បាលវែងតូចម្ខាងដូចផ្លែល្ពៅ*[71]។*(...)* |

[71] ញ៉ុក ថៃម : ***មហាវេស្សន្តរជាតក***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥៣៩, ទំព័រ១៧៣-១៧៤។

| | |
|---|---|
| **៨៧-វិធីបំផ្លើស**<br>អ. hyperbole<br>បារ. hyperbole<br>(f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធប្រើដោយលើកយកពាក្យសម្ដីលើសហួសពីការពិតមករៀបរាប់ទិដ្ឋភាព សកម្មភាពអ្វីមួយក្នុងគោលបំណងបង្ហាញហេតុការណ៍ណាមួយធ្វើឱ្យមានកម្រិតខ្ពស់បំផុតឬទាបបំផុតដោយបង្កប់ន័យក្នុងការទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្ដាប់ឱ្យមានការពិចារណាទៅលើបញ្ហាដែលខ្លួនចង់បង្ហាញ។<br>ឧទាហរណ៍ : - នៅក្នុងកំណាព្យ «*មើលផែនដីខ្មែរសម័យ ប៉ុល ពត អៀង សារី*»<br>*(...)* អកទោចទួញយំ តាមដងព្រៃភ្នំ<br>ឃើញភាពទារុណ មនុស្សស្លាប់គរច្រើន<br>*កើនហួសបូកគុណ* *រុយមូសញ៉ាក់គ្រុន*<br>*ខ្លាចខ្មោចមនុស្សលេង*[72]។*(...)* |
| **៨៨-វិធីពង្វាង**<br>អ. detour<br>បារ. détour (m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធប្រើដើម្បីពង្វាងដោយមិនប្រើពាក្យ កន្សោមពាក្យចំៗត្រង់ៗសម្រាប់សម្គាល់បញ្ញត្តិណាមួយ។<br>ឧ. *(...)* *បិសាចក្អែកខ្មៅខ្លៅសាមាន្យ*<br>ចិត្តជួតិរច្ឆានខ្មៅចំបែង<br>សម្លាប់ជាតិខ្មែរគ្មានរអែង<br>បំផ្លាញជាតិឯងទៅជាផេះ ។*(...)* |

[72] ជួន ម៉េន : ***មើលផែនដីខ្មែរសម័យ ប៉ុល ពត អៀង សារី***, ក្រសួងឃោសនាការវប្បធម៌, បោះពុម្ពលើកទី១, ភ្នំពេញ, គ.ស.១៩៨០, ទំព័រ៥ ។

| | |
|---|---|
| **៨៩-វិធីត្រឡប់**<br>អ. regression<br>បារ.régression(f.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធប្រើដោយលើកយកពាក្យឆ្លុះគ្នាមកបង្ហាញ ដើម្បីឱ្យពាក្យទាំងនោះមានន័យសេចក្តីផ្សេងគ្នា។<br>ឧ.*(...)* ធ្វើបុណ្យបានបុណ្យ ធ្វើបាបពីមុន<br>បាបវិលមកសង *<u>ស្អប់គេ គេស្អប់</u>*<br>មិនចប់សំណង ប្រសិនស្នេហ៍ស្នង<br>គេស្នេហ៍វិញដែរ[73] ។*(...)* |
| **៩០- វីររស**<br>អ. heroic<br>បារ. Héroïque (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ បេះបង្ហាញនូវសកម្មភាពអាកប្បកិរិយា ចិត្តអង់អាចក្លាហាន មោះមុតរបស់តួអង្គក្នុងការប្រយុទ្ធតទល់ជាមួយគូបដិបក្ខដើម្បីការពារអំពើល្អ។<br>ឧទាហរណ៍: នៅក្នុងរឿងរាមកេរ្តិ៍ រាមលក្ស្មណ៍ ជបលក្ស្មណ៍ ក្មេងតូចៗច្បាំងយ៉ាងអង់អាចជាមួយទ័ពព្រះរាមដែលមានយុទ្ធសិល្ប៍ពូកែអស្ចារ្យ។ |
| **៩១- វីរិយបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះមហាជនកបានបំពេញដោយការព្យាយាម។ |
| **៩២- វុត្តន្តកថា**<br>អ. report<br>បារ. reportage(m.) | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធរៀបរាប់បញ្ជាក់ឡើងវិញនូវហេតុការណ៍ឬពិធីផ្លូវការអ្វីមួយដែលកំពុងប្រព្រឹត្តទៅក្តីឬកន្លង |

[73] កេង វ៉ាន់សាក់ : ***គុកកាមកិលេស***, ភ្នំពេញ, គ.ស. [?] ទំព័រ១៧។

| | |
|---|---|
| | ផុតទៅក្តី ដើម្បីផ្សព្វផ្សាយតាមរយៈទស្សនាវដ្តី វិទ្យុទូរទស្សន៍។<br>ឧទាហរណ៍ : ការរៀបរាប់ពីទស្សនកិច្ចរបស់ប្រមុខរាជរដ្ឋាភិបាលឬវរជនសំខាន់ណាម្នាក់។ |
| **៩៣-វេសម្មវិធី**<br>អ. opposition and contrast<br>បារ. opposition et contraste<br>( m. ) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធចេះលើកយកគុណភាពពីរ ចលនាឬសកម្មភាពពីរ សំនួនសេចក្តីពីរ មតិទស្សនៈពីរឬអត្តៈខាងក្នុងនិងខាងក្រៅរបស់តួអង្គណាមួយ ដែលមានភាពផ្ទុយគ្នាមកដាក់ប្រៀបគ្នាដើម្បីជាមធ្យោបាយពន្លេចឱ្យឃើញនូវតម្លៃអ្វីមួយ។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ការរៀបរាប់អំពីកូខ័ន បង្ហាញពីទំនាស់ខាងក្នុងនិងខាងក្រៅ<br>- *(...) សក្តិសួនជាអ្នកថ្មើរព្រៃ ខ្លួនខ្មៅក្រៅវិស័យ*<br>*នូវធ្មេញសស្នឹមភ្នែកប្រាល។*<br>*ខ្លួនខ្លោះខ្លាំងខែងពេញពាល ជាត់ជំមមារ*<br>*មម្លរមមុលព្រឹក្សព្រៃ*[74] ។*(...)*<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ការបង្ហាញទស្សនៈពីរផ្ទុយគ្នារវាងម្តាយនិងកូន<br>- *(...)អំណាចខ្លួបខ្លាចមានស័ក្តិយស*<br>*ចំពោះជាត្រូវបុណ្យកូនឡើង* |

[74] អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស : ***រឿងរាមកេរ្តិ៍ ខ្សែ១*** , ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, ទំព័រ ៤២។

| | |
|---|---|
| | *ម្ដាយប្រាប់ប្រដៅកូនកុំផ្ទើង<br>ចបេសចបើងណាថ្លៃម្ដាយ។<br>ទាវឮម្ដាយប្រាប់ចាប់ចាំទុក<br>ស្មើរផ្លាក់ថ្លើមក្ដុកពុំរសាយ<br>ទើបមានវាចាថាម៉ែអាយ<br>ខ្ញុំកូនដូចស្ដាយបាយចំណី។<br>ថាបើម៉ែព្រមល្មមនឹងគេ<br>កូនម៉ែទំនេរមានប្រុសស្រី<br>លើកឱ្យគេទៅទោះពីរបី<br>តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ*[75] ។*(...)* |
| **៩៤- សារកថា**<br>អ. letter<br>បារ. lettres ( f. ) | សន្ទស្សន៍អក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធសរសេរជាលក្ខណៈសំបុត្រឆ្លងឆ្លើយ( ក្នុងគ្រួសារ មិត្តភក្តិ អ្នកដទៃ )ដើម្បីលាតត្រដាងបង្ហាញនូវបញ្ហាអ្វីមួយទាក់ទងនឹងការរស់នៅ ពិធីអ្វីមួយ មនោសញ្ចេតនា... របស់មនុស្ស។<br>ឧទាហរណ៍ :<br>- សារកថារបស់លោកស្រី Sévigné,<br>- សារកថារបស់លោក Voltaire។ |
| **៩៥- សាស្ត្រា** | គម្ពីរ ឬ ក្បួនច្បាប់ប្រដៅ ដែលចារលើស្លឹករឹត។ |

[75] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥១៤, ទំព័រ៤៩។

| | |
|---|---|
| **៩៦- សាស្ត្រាក្បួន** | សាស្ត្រាដែលជាកម្រងក្បួនខ្នាតនានាមានក្បួនទាយ មន្តអាគម ក្បួនឱសថនិងចំណេះវិជ្ជាផ្សេងៗទៀត។ |
| **៩៧- សាស្ត្រាច្បាប់** | សាស្ត្រាដែលជាកម្រងសីលធម៌នានាសម្រាប់ប្រៀនប្រដៅមនុស្សឱ្យសាងអំពើល្អ និង យល់ត្រូវ។<br>ឧទាហរណ៍ : សាស្ត្រាច្បាប់កេរកាល, សាស្ត្រាច្បាប់ប្រុស, ច្បាប់ស្រី, ... ។ |
| **៩៨-សាស្ត្រាទេសន៍** | សាស្ត្រាដែលមានចែងអំពីការអប់រំប្រៀនប្រដៅទាក់ទងទៅនឹងសាសនា ហើយដែលគេយកទៅប្រើប្រាស់សម្រាប់សម្តែងធម៌ទេសនា។<br>ឧទាហរណ៍ : សាស្ត្រាទសជាតកជាសាស្ត្រាទេសន៍។ |
| **៩៩- សាស្ត្រាល្បែង** | សាស្ត្រាដែលជាកម្រងអត្ថបទរឿងរ៉ាវទាំងឡាយសម្រាប់អានកម្សាន្ត បំពេអារម្មណ៍ ឱ្យរីករាយ។<br>ឧទាហរណ៍ : សាស្ត្រារឿងក្រុងសុភមិត្រ, សាស្ត្រារឿងហង្សយន្ត, ... ។ |
| **១០០-សិប្បនិម្មិត**<br>អ. artificial<br>បារ. artificiel, elle ( adj. ) | ដែលតុបតែងរចនាឡើងដោយសិល្បៈដែលមិនមែនជាធម្មជាតិ។<br>ឧទាហរណ៍ : ជើងសិប្បនិម្មិត ផ្កាសិប្បនិម្មិត ផ្លែឈើសិប្បនិម្មិត ... ។ |

| | |
|---|---|
| **១០១-សិល្បវិជ្ជា**<br>អ. aesthetics<br>បារ. esthétique (f.) | វិទ្យាសាស្ត្រដែលសម្រាប់ណែនាំឬពិនិត្យវាយតម្លៃលើសោភ័ណនៅក្នុងស្នាដៃអក្សរសិល្ប៍ សិល្បៈ ច្បាប់ឧបទេស ជាដើម។ |
| **១០២-សិល្បវិធី** | សិល្បៈ វិធីសាស្ត្រឬមធ្យោបាយផ្សេងៗរបស់អ្នកនិពន្ធក្នុងការសរសេររឿងដើម្បីទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្តាប់ អ្នកទស្សនា ឱ្យជក់ចិត្ត ចាប់អារម្មណ៍ទៅតាមដំណើររឿង។ |
| **១០៣- សីលបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ដែលព្រះពោធិសត្វក្នុងជាតិជាព្រះភូរិទត្ត នាគរាជ បានបំពេញដោយការរក្សាឧបោសថសីល សូម្បីតែជីវិតក៏ហ៊ានលះបង់។ |
| **១០៤-សង្ខេបរឿង**<br>អ. summary<br>បារ. résumé (m.) | សេចក្តីបំប្រួញដំណើររឿងឱ្យខ្លី ឱ្យអស់សេចក្តីដោយរក្សាខ្លឹមសាររឿងឱ្យនៅដដែល។ |
| **១០៥-សង្គមដ្ឋាន**<br>អ. social milieu ?<br>បារ. milieu social (m.) | មជ្ឈដ្ឋានប្រកបដោយសម្ភារៈ បញ្ញាញាណ ផ្លូវចិត្តរបស់មនុស្សក្នុងសង្គម នាសម័យកាលនៃរឿងដែលអ្នកនិពន្ធលើកយកមកបង្ហាញក្នុងស្នាដៃណាមួយ។ ធាតុសំខាន់ៗរបស់សង្គមដ្ឋានគឺសង្គមបរិយាកាស សង្គមប្រវត្តិ និង សង្គមបញ្ហា។ |
| **១០៦-សង្គមធម៌**<br>អ. social<br>បារ. social (m.) | មែកធាងនៃអរិយធម៌ដែលទ្រទ្រង់ការរស់នៅនិងការបណ្តុះបណ្តាលតាមរយៈគ្រឿងសម្ភារៈ ប្រដាប់ប្រើប្រាស់ វិធីបច្ចេកទេស ការបង្កើតផលិតផល ការរៀបចំសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ...។ |

| | |
|---|---|
| **១០៧-សង្គមបញ្ហា**<br>អ. social problem<br>បារ. problème social ( m. ) | បញ្ហាទាំងឡាយដែលមានក្នុងសង្គម ដូចជា បញ្ហាជីវភាព បញ្ហាសុខុមាលភាព បញ្ហាគ្រប់គ្រងសង្គម... ដែលអ្នកនិពន្ធលើកមកបង្ហាញក្នុងដំណើររឿង។<br>ឧទាហរណ៍ : នៅក្នុងរឿងគូលីកំណែន ការបង្ហាញបញ្ហាមួយចំនួន ដូចជា អំណាចផ្តាច់ការ ការកេងប្រវ័ញ្ច ការជំរឹតទារពន្ធដារច្រើនហួសហេតុពីប្រជាជន...។ |
| **១០៨-សង្គមបរិយាកាស**<br>អ. social atmosphere<br>បារ. atmosphère sociale ( f . ) | ទិដ្ឋភាពនៃរឿង ដែលអ្នកនិពន្ធបានរៀបរាប់ពីការរស់នៅ ការប្រកបអាជីវកម្ម ជំនឿ ប្រពៃណី ទំនៀមទម្លាប់ ការគ្រប់គ្រង និង ទំនាក់ទំនងសង្គមក្នុងសម័យកាលណាមួយ។<br>ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ ការបង្ហាញពីការរស់នៅរបស់ប្រជាជន កាគោរពព្រះពុទ្ធសាសនា ការជឿលើមន្តអាគម ហោរាសាស្ត្រ ការប្រកាន់ប្រពៃណី‹‹នំមិនធំជាងនាឡិ›› ប្រពៃណីចូលម្លប់ ទំនាក់ទំនងរវាងអ្នកមាននិងអ្នកក្រ អ្នកធំនិងអ្នកតូច និង ទំនាក់ទំនងក្នុងគ្រួសារ។ |
| **១០៩-សង្គមប្រវត្តិ**<br>អ. social history/ social event / social fact | ព្រឹត្តិការណ៍នានា ដែលអ្នកនិពន្ធបានលើកឡើងតាមរយៈដំណើររឿងណាមួយ ដោយជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសង្គម។ |

| | |
|---|---|
| បារ. histoire sociale ? / evènement social / fait social | ឧទាហរណ៍ :<br>-នៅក្នុងរឿងទុំទាវ សង្គមប្រវត្តិនៃរឿងទុំទាវគឺទាក់ទងទៅនឹងសង្គមខ្មែរសម័យលង្វែក។<br>-នៅក្នុងរឿងភូមិតិរច្ឆាន សង្គមប្រវត្តិនៃរឿងភូមិតិរច្ឆានគឺទាក់ទងទៅនឹងសង្គមខ្មែរសម័យអាណានិគមនិយមបារាំង។ |
| **១១០-សង្គមារម្មណ៍** | ផ្នត់គំនិតដែលកើតឡើងតាមរយៈការច្នៃប្រឌិតរបស់អ្នកនិពន្ធដោយផ្សារភ្ជាប់ទៅនឹងព្រឹត្តិការណ៍ជាក់ស្ដែងរបស់សង្គម។<br>ឧទាហរណ៍ :<br>- នៅក្នុងរឿងទុំទាវ ទស្សនៈ «នំមិនធំជាងនាឡិ »,<br>- នៅក្នុងរឿងធនញ្ជ័យ ទំនាយហោរា។ |
| **១១១-សច្ចៈ** | ព្រឹត្តិការណ៍ ហេតុការណ៍ ដំណើរជាក់នឹងភ្នែក។ |
| **១១២- សច្ចបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះវិធុរបណ្ឌិតបានបំពេញដោយការកាន់ពាក្យសច្ចៈ។ |
| **១១៣-សញ្ច័យវិធី**<br>អ. accumulation<br>បារ. accumulation | វិធីដែលកវីឬអ្នកនិពន្ធប្រមូលផ្ដុំនូវភេទការណ៍ឬមតិផ្សេងៗក្នុងវគ្គឬប្រយោគតែមួយ។ ក្នុងវិធីនេះគេច្រើនផ្ដុំកិរិយាសព្ទ ប្រធានដើម្បីបង្ហាញឱ្យឃើញនូវចលនាឆាប់រហ័ស រំភើបញាប់ញ័រ។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ខ្សែទី៤ ចលនាប្រហាររបស់ព្រះរាមទៅលើក្រុងខរ ៖ |

| | |
|---|---|
| | *(...) ស្ដេចដំ ស្ដេចជាន់ ស្ដេចជាក់ ស្ដេចច្រាន ស្ដេចចាក់ ស្ដេចហែករុះរាយបោះបង់*[76] ។*(...)* |
| **១១៤- សន្ទស្សន៍ អក្សរសិល្ប៍ (អក្សរសិល្ប៍ អធិប្បាយ)** | អត្ថបទអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធ បង្ហាញរូបភាព វត្ថុ ព្រឹត្តិការណ៍ណាមួយដើម្បីឱ្យ អ្នកអាន អ្នកស្ដាប់បានឃើញ បានយល់ដឹងទៅ តាមដំណើររឿង។ ក្នុងសន្ទស្សន៍អក្សរសិល្ប៍មាន ពិពណ៌នាកថា វណ្ណនាកថា បដិពិម្ពកថា វុត្តន្តកថា សារកថា។ |
| **១១៥-សុន្ទរកថា** អ. discourse/ speech បារ. discours | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នក និពន្ធសរសេរអំពីអ្វីមួយសម្រាប់អាន ថ្លែងក្នុងពិធី អ្វីមួយ ដោយ ៖<br>- រៀបរាប់ពីលទ្ធផលការងារ,<br>- ណែនាំ តម្រែតម្រង់ ការអនុវត្តសកម្មភាពឬ គម្រោងការអ្វីមួយ និង បញ្ចូលគំនិតរិះគន់។ |
| **១១៦-សុន្ទររស** អ. pretty បារ. joli (m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយ កវី អ្នកនិពន្ធចេះពណ៌នារូបភាព លក្ខណៈសកម្ម ភាពនៃតួអង្គ ដំណើររឿង ធម្មជាតិឱ្យឃើញ លក្ខណៈល្អត្រឹមត្រូវតាមការពិត ឬ រូបលក្ខណៈ ពិត ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ពេញចិត្ត។ |

[76] អ្នកអង្គម្ចាស់ វឌ្ឍឆាយាវង្ស : ***រឿងរាមកេរ្តិ៍ ខ្សែ៤***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥៣៩, គ.ស. ១៩៩៥, ទំព័រ៣២។

| | |
|---|---|
| | ឧទាហរណ៍ : នៅក្នុងរឿងកាកី<br>*(...) កាយកើតអស្ចារ្យ អំពីផ្កាកា-*<br>*ណិកាសោភី ភក្ត្រាសោភ័ណ*<br>*ដូចចន្ទ្របូណ៌មី សក់ដូចភមរី*<br>*រលើបខ្មាញ់ខ្មៅ។*<br>*............... ..................*<br>*..............។*<br>*កបកាយក្រអូប ទោះទាំងរាងរូប*<br>*ប្រហើរពុំបាច់ រកផ្កាគ្រឿងអប់*<br>*ឈ្ងុយឈ្ងប់សព្វសាច់ ពិដោរបណ្ដាច់*<br>*បណ្ដូលអស់ស្រី*[77] ។*(...)* |
| **១១៧-សុភាសិត**<br>អ. proverb<br>បារ. proverbe(m.) | ឧបទេសអក្សរសិល្ប៍មួយប្រភេទ ដែលកវី អ្នកនិពន្ធតាក់តែងជាពាក្យឬកម្រង ពាក្យចួនរណ្ដំ (កម្រងកែវ) សម្រាប់អប់រំ ទូន្មាន ដោយលើកយកធម្មជាតិ ជីវភាព សង្គម ជាដើម មកប្រៀបធៀប។<br>ឧទាហរណ៍ :<br>- ចេះពីរៀន មានពីរក,<br>- ចង្កឹះមួយបាច់ កាច់មិនបាក់,<br>- តក់ៗពេញបំពង់។ |
| **១១៨-សោតរូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគដែលរំលេចឱ្យអ្នកអាន អ្នកស្ដាប់ឮសំឡេងនៅក្នុងអារម្មណ៍។ |

[77] ព្រះអង្គ ឌួង *: រឿង កាកី*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥៤១, ទំព័រ៨-១០។

| | |
|---|---|
| **១១៩-សំវាទវិធី**<br>អ. dialogue<br>បារ. dialogue(m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធប្រើដោយធ្វើឱ្យតួអង្គជជែកសន្ទនា ឆ្លងឆ្លើយគ្នាទៅវិញ ទៅមក។<br>ឧ.*(...)ថ្លែងដោយទំនង ដំណើរត្រីផងយាត្រា ពើបនឹងដុចណា ត្រីស្រែកថារុំយថៀសចេញ។ ដុចថាអីអើ បទអ្នកនេះតើម្ដេចមិញ ក៏មកប្រើអញ ចៀសចេញឱ្យអ្នកដាល្បែង[78]។(...)* |
| **១២០- សមន្តរត្តវិធី**<br>អ. parallelism<br>បារ.parallélisme (m.) | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធប្រើសម្រាប់អធិប្បាយពីសមត្ថភាព ឫទ្ធានុភាព កលល្បិច មធ្យោបាយ ប្រហាក់ប្រហែលគ្នារវាងតួអង្គបដិបក្សដើម្បីឱ្យមាននាដ្យភាព។<br>ឧទាហរណ៍: នៅក្នុងរឿងរាមកេរ្តិ៍ ខ្សែទី៣ ក្នុងចម្បាំងរវាងព្រះរាមនិងក្រុងខរ មួយផ្លែងសរកើតជានាគ មួយទៀតផ្លែងសរកើតជាគ្រុឌ ម្ខាងផ្លែងសរជាភ្លើង ម្ខាងទៀតផ្លែងសរឱ្យកើតជាទឹក។ |
| **១២១-សព្វរស**<br>អ. general values<br>បារ. valeurs générales | ផ្នែកមួយនៃអត្ថរស ដែលកវី អ្នកនិពន្ធបានលើកយកមកប្រើប្រាស់ក្នុងអត្ថបទរឿងរបស់ខ្លួន ដើម្បីបង្កើតតថរស អច្ឆរិយរស កុសលរស...។ |
| **១២២- សរជាតិ** | ដំណើរត្រឡប់ជាតិចេរវិលវិញពីជាតិមួយទៅជាតិមួយទៀត។ |

[78] ហ្លួងវិសេសអក្ខរា **ដួង** : ***ល្បើកដុច ក្អាម***, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, បោះពុម្ពលើកទី២ ព.ស. ២៥៤៥ គ.ស.២០០១ ទំព័រ១។

| | |
|---|---|
| | ឧទាហរណ៍: នៅក្នុងរឿងមហាវេស្សន្តរជាតក ការបញ្ចប់រឿងមហាវេស្សន្តរជាតកតួអង្គសរជាតិមានដូចតទៅ៖<br>- ព្រះបាទវេស្សន្តរ សរជាតិជាព្រះសម្មាសម្ពុទ្ធគោតម,<br>- នាងមទ្រី សរជាតិជានាងយសោធរា,<br>- ជាលីកុមារ សរជាតិជារាហុលកុមារ,<br>- នាងក្រឹស្នា(កណ្ហា) សរជាតិជានាងឧប្បលវណ្ណា។ |
| **១២៣-ស្ថានភាពតួយ៉ាង**<br>អ. type situation<br>បារ. situation type (f.) | ស្ថានភាពណាមួយដែលអ្នកនិពន្ធជ្រើសរើសយកមកជាតំណាងស្ថានភាពទូទៅនៃសង្គម។<br>ឧទាហរណ៍ : នៅក្នុងរឿងភូមិតិរច្ឆាន ស្ថានភាពនៃការជំរឹតទារពន្ធហួសហេតុពីប្រជាជនខ្មែររបស់បារាំងជាស្ថានភាពតួយ៉ាងនៃការជិះជាន់គាបសង្កត់របស់អាណានិគមបារាំងមកលើប្រជាជនខ្មែរ។ |
| **១២៤-ហាសកថា**<br>អ. comedy<br>បារ. comédie (f.) | នាដកអក្សរសិល្ប៍មួយប្រភេទដែលកវី អ្នកនិពន្ធតាក់តែងជារឿងល្ខោន ដែលដំណើររឿងប្រកបដោយឈុត ឆាក កំប្លុកកំប្លែង ធ្វើឱ្យអ្នកអាន អ្នកស្តាប់ផ្ទុះសំណើច។ |
| **១២៥-ហាសរស**<br>អ. comic<br>បារ. comique(m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះបង្ហាញសកម្មភាពកំប្លុកកំប្លែងធ្វើឱ្យអ្នកអាន អ្នកស្តាប់ សើចសប្បាយរីករាយ។<br>ឧទាហរណ៍ : នៅក្នុងរឿងធនញ្ជ័យ ធនញ្ជ័យរើស |

| | |
|---|---|
| | អាចម៍សេះច្រកថង់យាមយកទៅជូនសេដ្ឋី កណ្តាលចំណោមមន្ត្រី។<br>ឧទាហរណ៍ : នៅក្នុងរឿងអាឡេវ អាឡេវចាប់ ម៉ែឪវារៀបការដើម្បីបានស៊ីនំគម នំអន្សម...។ |
| **១២៦-អក្សរសាស្ត្រ**<br>អ. letters<br>បារ. lettres (f.) | វិទ្យាសាស្ត្រសង្គមមួយប្រភេទដែលសិក្សាពីភាសា អក្សរសិល្ប៍។ |
| **១២៧-អក្សរសិល្ប៍**<br>អ. literature<br>បារ. littérature(f.) | ផ្នែកមួយនៃអក្សរសាស្ត្រ ដែលអ្នកនិពន្ធលើកពី បញ្ហាមនុស្ស បញ្ហាសង្គមមកចោទនិងដោះស្រាយ ដោយប្រើសិល្បវិធី។ |
| **១២៨- អក្សរសិល្ប៍ ខ្មែរបែបខេមរ និយម** | អក្សរសិល្ប៍ខ្មែរ ដែលលើកឡើងនិងឆ្លុះបញ្ចាំងពី ជីវភាពរស់នៅរបស់ខ្មែរពិតៗ។<br>ឧទាហរណ៍ : រឿងទុំទាវ រឿងសូផាត...។ |
| **១២៩-អក្សរសិល្ប៍ ខ្មែរបែប បរទេស និយម** | អក្សរសិល្ប៍ខ្មែរ ដែលយកលំនាំតាមបរទេស។<br>ឧទាហរណ៍ :<br>- រឿងជីវិតឥតន័យ របស់អ្នកនិពន្ធ សុទ្ធ ប៉ូលីន។<br>- រឿងថៅកែចិត្តចោរ របស់អ្នកនិពន្ធ ពៅ យូឡេង និង អ៊ុំ ឈឺន។ |
| **១៣០- អក្សរសិល្ប៍ ខ្មែរបែបពុទ្ធ និយម** | អក្សរសិល្ប៍ខ្មែរដែលទទួលឥទ្ធិពលពុទ្ធសាសនា។ ស្នាដៃប្រភេទនេះតែងលើកយកសកម្មភាពព្រះ ពោធិសត្វក្នុងការកសាងបារមីឬទស្សនៈសំខាន់ៗ ក្នុងព្រះពុទ្ធសាសនា ដូចជា បញ្ហាកម្មផល បុណ្យ |

| | |
|---|---|
| បារ. littérature khmère à caractère buddhiste | បាបជាដើម។ អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមមាន អក្សរសិល្ប៍បែបពុទ្ធនិយមសុទ្ធសាធ និង អក្សរសិល្ប៍បែបពុទ្ធនិយមក្លាយ។<br>ឧទាហរណ៍ :<br>- រឿងព្រះវេស្សន្តរជាអក្សរសិល្ប៍បែបពុទ្ធនិយមសុទ្ធសាធ។<br>- រឿងក្រុងសុភមិត្រ ជាអក្សរសិល្ប៍បែបពុទ្ធនិយមក្លាយ។ |
| **១៣១-អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមក្លាយ** | អក្សរសិល្ប៍ខ្មែរ ដែលបញ្ហានៃរឿងមានជាប់ទាក់ទងទៅនឹងទ្រឹស្តីក្នុងព្រះពុទ្ធសាសនាតិចតួច។ តួអង្គនៃរឿងពុំមានកសាងបារមីអ្វីមួយច្បាស់លាស់ឡើយ។<br>ឧទាហរណ៍ : រឿងសព្វសិទ្ធិ រឿងសូរ្យវង្ស រឿងសុបិនកុមារ...។ |
| **១៣២-អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម** | អក្សរសិល្ប៍ខ្មែរ ដែលទទួលឥទ្ធិពលសាសនាព្រាហ្មណ៍។ ស្នាដៃប្រភេទនេះតែងលើកយកភាពអច្ឆរិយៈរបស់ទេវៈឬអាទិទេព និង អសុរៈមករៀបរាប់បង្ហាញ។<br>ឧទាហរណ៍ : រឿងរាមកេរ្តិ៍។ |
| **១៣៣- អច្ឆរិយរស**<br>អ. Marvellous<br>បារ.merveilleux(m.) | តម្លៃដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍ ដោយកវី អ្នកនិពន្ធ ចេះលើកយកតួអង្គអរូបី(ទេវៈ យក្ខ ខ្មោច ព្រាយ បិសាច...) តួអង្គសត្វឬសកម្មភាពអស្ចារ្យផ្សេងៗមកបញ្ចូលក្នុងស្នាដៃរបស់ខ្លួនដើម្បី |

| | |
|---|---|
| | ធ្វើឱ្យដំណើររឿងមានលក្ខណៈអស្ចារ្យហួសពីការពិត ដូចជា តួអង្គចេះជ្រែកទឹក ជ្រែកដី ហោះហើរដើរលើអាកាស បែងភាគ កាឡាខ្លួន...។<br>ឧទាហរណ៍ : នៅរឿងកាកី គន្ធ័នបានកាឡាខ្លួនជាស្រមើលហើយតោងរោមគ្រុឌ<br>*(...)យាត្រាត្រង់ព្រះជ្រៃ គន្ធ័នវៃរៀងសំដៅ*<br>*លបលាក់ដើរតាមទៅ មើលដំណើរនៃគ្រុឌា។*<br>*ដើរដល់ដើមព្រះជ្រៃ ប្រែប្រាណវៃវិលរឹងជា*<br>*ក្រុងគ្រុឌរាជបក្សា គន្ធ័នសោតនិម្មិតអង្គ។*<br>*ជាស្រមើលទំនា រោមគ្រុឌាឫទ្ធីវង្គ*<br>*ស្ទុះហោះហើរពុំផ្សង សំដៅដល់ដើម*<br>*សិម្ពលី*[79]*។(...)* |
| **១៣៤- អជ្ឈត្តិកទាន** | ទានខាងក្នុងខ្លួន ដូចជា សាច់ ឈាម បេះដូងថ្លើម ប្រមាត់ អវយវៈ (នៅក្នុងរឿង ព្រះវេស្សន្តរ អជ្ឈត្តិកទាន គឺរាប់ទាំងការដាក់ទានរហូតដល់ប្រពន្ធ កូន)។<br>ឧទាហរណ៍ : កាលព្រះពោធិសត្វយោនយកកំណើតជាសត្វទន្សាយ ព្រះអង្គបានលោតចូលភ្លើងដើម្បីប្រទានសាច់ព្រះអង្គឱ្យដល់ស្មូមដែលជាព្រះឥន្ទ្រកាឡាខ្លួន។ |
| **១៣៥- អត្ថរស**<br>អ. text values | តម្លៃល្អ មិនល្អ ពីរោះ ពុំពីរោះ ដែលមាននៅក្នុងអត្ថបទអក្សរសិល្ប៍។ ក្នុងអត្ថរស មាន បច្ចេករស វិសេសរស សព្វរស ។ |

[79] ព្រះអង្គ ឌួង ***: រឿងកាកី***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥៤១, ទំព័រ៤២។

| | |
|---|---|
| **១៣៦- អធិដ្ឋានបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះនេមិរាជ បានបំពេញដោយការតាំងចិត្តមាំថា អាត្មាអញដល់ពេលសក់ស្កូវនឹងចេញទៅសាងព្រះផ្នួស ។ |
| **១៣៧-អនុកម្ម**<br>អ. imitation<br>បារ. imitation(f.) | ការត្រាប់តាម ការចម្លងតាមស្នាដៃសិល្បៈ អក្សរសិល្ប៍ដែលមានរួចមកហើយមកពិពណ៌នាបង្ហាញ បញ្ចាំង គូរ ឆ្លាក់ ឱ្យឃើញឡើងវិញ។<br>ឧទាហរណ៍ :<br>- រឿងល្ខោន «អ្នកមានឃ្លានយស» ជាអនុកម្មស្នាដៃរបស់លោក Molière ក្នុងរឿង «Bourgeois gentil homme»។<br>- រឿងល្ខោន « កំណាញ់ក្រៀតក្រម ›› ជាអនុកម្មស្នាដៃរបស់លោក Molière ក្នុងរឿង « AVARE »។ |
| **១៣៨-អរិយធម៌**<br>អ. civilisation<br>បា. civilisation (f.) | បណ្តុំលក្ខណៈរួមរបស់សង្គមដែលក្នុងនោះមានទាក់ទងនឹងជំនឿ សាសនា សីលធម៌ សីលវិជ្ជា វិទ្យាសាស្ត្រ បច្ចេកទេស ការគ្រប់គ្រង... ហើយដែលផ្ទុយនឹងសភាពអន់ថយ។<br>មែកធាងសំខាន់ៗនៃអរិយធម៌ មានវប្បធម៌និងសង្គមធម៌។ |
| **១៣៩- អវេក្ខណវិធី**<br>អ. observation | វិធីតែងនិពន្ធមួយបែប ដែលកវី អ្នកនិពន្ធ ប្រើដោយលើកយកហេតុការណ៍ សកម្មភាពផ្សេងៗ |

| | |
|---|---|
| បារ. observation (f.) | មកបង្ហាញរៀបរាប់ លាតត្រដាងឱ្យឃើញជាក់ស្តែងហាក់ដូចជានៅនឹងភ្នែក។<br>ឧទាហរណ៍ : នៅក្នុងរឿងផ្កាស្រពោន<br>*-(...)នៅខែចេត្រនិងពិសាខ តាមផ្លូវពីក្រុងសៀមរាបទៅអង្គរវត្ត ផ្ការំដួលបញ្ចេញ រំភើយពិដោរក្រអូបឈ្ងុយ។ បើជួនជាមានវាយោបក់បន្តិចៗផងអ្នកដែលដើរយកអាកាសពេលល្ងាចតាមថ្នល់នេះនឹងមានចិត្តរសាប់រសាយអណ្តែតអណ្តូង ប្រហែលជានឹងលាន់មាត់ថា ទោះជាឋានតុសិតក៏មិនសប្បាយជាជាងនេះ មើលទៅ*[80]*។(...)* |
| **១៤០-ឥន្ទ្រិយរូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគដែលធ្វើឱ្យឥន្ទ្រិយនានា(ចាប់ពីពីរឡើងទៅ)របស់អ្នកអាន អ្នកស្តាប់ទទួលអារម្មណ៍រំភើប។<br>**ឧ.** *(...)ទុក្ខម្តោទោម្នេញភ្ញាញ់ធុរធាវ*<br>*កន្ត្រាក់បានដាវស្ទុះចូលជុំ*<br>*ចូលចាប់ចាក់កាប់ឥតជំនុំ*<br>*ចង់ទុំក្រញឹកស្មើតស្លាបសេក ។(...)*<br>*(...) គេចាប់វាយដំក្រំសព្វសាច់*<br>*ឈាមហូរមិនដាច់បែកសិរសី* |

[80] នូ ហាច : ***រឿងផ្កាស្រពោន***, ផ្សាយពីក្រសួងសិក្សាធិការជាតិ, រោងពុម្ពរស្មី, ភ្នំពេញ, គ.ស. ១៩៦០, ទំព័រ៦១។

| | |
|---|---|
| | *ឈាមកកខាន់ស្ទះបម្រះស្តី<br>ផ្តែផ្តាំវាស្រីប្តីលួបាន* [81] *។(...)* |
| **១៤១-ឧបកថាវិធី**<br>អ. episode<br>បារ. épisode (m.) | វិធីតែងនិពន្ធមួយបែបដែលកវី អ្នកនិពន្ធប្រើដោយនិយាយរៀបរាប់ព្រឹត្តិការណ៍អ្វីមួយមិនទាន់ចប់សេចក្តីផងក៏ផ្អាកមួយខណៈ ហើយក៏ចាប់និយាយរៀបរាប់ព្រឹត្តិការណ៍ថ្មីមួយទៀតបន្ត។<br>ឧទាហរណ៍ : នៅក្នុងរឿងរាមកេរ្តិ៍ ខ្សែទី៤ ដើមដំបូង អ្នកនិពន្ធនិយាយពីព្រះរាមត្រាច់ចររកនាងសីតា បន្ទាប់ពីក្រុងរាពណ៍ឆក់យកទៅ។ ដំណើររឿងនេះមិនទាន់ដឹងសេចក្តីអស់ផង ស្រាប់តែអ្នកនិពន្ធបែរទៅជានិយាយពីរឿងទូភីស្តេចក្របីបង្កើតចម្បាំងជាមួយនឹងពាលីស្តេចស្វាទៅវិញ។ |
| **១៤២-ឧបមានរូបារម្មណ៍** | រូបារម្មណ៍ក្នុងអត្ថបទកំណាព្យ អត្ថបទពាក្យរាយដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាប្រយោគដែលរំលេចឱ្យឃើញការប្រៀបធៀបពាក្យ *ដូច ដូចជា ហាក់ដូចជា ធៀបនឹង ប្រៀបបាននឹង រូបាន*,... ដែលអ្នកនិពន្ធបានលើកឡើង។<br>ឧ. *(...)ទុំថាខ្លួនបងដូចរាជសីហ៍<br>ខ្លួននាងទាវស្រីដូចគុហា* [82] *។ (...)* |

---

[81] ព្រះបទុមត្ថេរ សោម : ***រឿង ទុំទាវ***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស.២៥១៤, គ.ស.១៩៧១ ទំព័រ១០៤។

[82] ព្រះបទុមត្ថេរ សោម ***: រឿងទុំទាវ***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥១៤, ទំព័រ៥៣។

| | |
|---|---|
| **១៤៣-ឧបទេស អក្សរសិល្ប៍** <br> អ. literature of didactic genre <br> បារ. littérature du genre didactique | អត្ថបទអក្សរសិល្ប៍មួយប្រភេទដែលកវី អ្នកនិពន្ធរៀបរៀងឡើងសម្រាប់អប់រំ ទូន្មានប្រៀនប្រដៅជនានុជន កុលបុត្រ កុលធីតាឱ្យប្រព្រឹត្តតាមក្រឹត្យក្រមសីលធម៌។ ឧបទេសអក្សរសិល្ប៍ពុំមានលក្ខណៈជាច្បាប់ ជាបទបញ្ជាជាការដាក់កំហិត ជាការបង្ខិតបង្ខំនោះទេ។ ឧបទេសអក្សរសិល្ប៍មាន សុភាសិត ទូន្មានកថា ល្បើកកថា សុន្ទរកថា ឧបារម្ភកថា ។ |
| **១៤៤- ឧបារម្ភកថា** <br> អ. satire <br> បារ. satire ( f. ) | ឧបទេសអក្សរសិល្ប៍មួយប្រភេទដែលកវី អ្នកនិពន្ធសរសេរអត្ថបទជាពាក្យរាយឬជាពាក្យកាព្យរិះគន់គុណវិបត្តិនៃសីលធម៌ នយោបាយ ជាពិសេសរិះគន់បុគ្គលក្នុងសង្គម។ <br> ឧទាហរណ៍ : នៅក្នុងរឿងតាថេននិងចៅសន។ |
| **១៤៥-ឧបេក្ខាបារមី** | បារមីមួយក្នុងចំណោមបារមីទាំង១០ ដែលព្រះពោធិសត្វក្នុងជាតិជាព្រះនារទព្រហ្ម បានបំពេញដោយការតាំងចិត្តជាកណ្តាលបានដល់ឧបេក្ខាព្រហ្មវិហារ។ |
| **១៤៦-ឯកវាទវិធី** <br> អ. monologue <br> បារ. monologue ( m. ) | វិធីតែងនិពន្ធមួយបែបដែលកវី អ្នកនិពន្ធប្រើដោយធ្វើឱ្យតួអង្គនិយាយថ្លែងទុក្ខព្រួយឬរៀបរាប់អំពីអនុស្សាវរីយ៍អ្វីមួយតែម្នាក់ឯង គ្មាននរណាចូលលាយឡំឡើយ។ <br> ឧទាហរណ៍ : នៅក្នុងរឿងទុំទាវ នាងទាវក្រោយពេលទុំត្រឡប់ទៅវត្តវិហារធំវិញ នាងនឹកទុំ |

| | |
|---|---|
| | យ៉ាងខ្លាំង ហើយគិតម្នាក់ឯងថា៖<br>*(...)ថាអញស្តាយក្រហាយប្រាណ*<br>*មិនក្សាន្តធ្ងន់ខ្លួនប្រៀបហាក់ភ្នំ*<br>*រលើងបព្វតាផ្ការលំ*<br>*សង្កត់សៀតក្រំរណ្តំខ្លាំង។*<br>*ខ្លោចផ្សាក្តៅក្តួលខ្នួលក្នុងថ្លើម*<br>*ដង្ហើមផុតៗស្លុតភាន់ភាំង*<br>*ម្ល៉េះហើយលោកអើយប្អូនមរណំ*<br>*ខ្លួនស្លាំងស្គាំងស្គមទ្រមវេទនា*[83]។*(...)* |

[83] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ***, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ព.ស. ២៥១៤, ទំព័រ២៤។